# លក្ខណៈរូបសាស្ត្រ និងដំណាក់កាលលូតលាស់របស់ដំណាំស្រូវ

## ១. លក្ខណៈរូបសាស្ត្រ

លក្ខណៈរូបសាស្ត្រនៃដំណាំស្រូវ គឺជាមូលដ្ឋានដើមក្នុងការស្វែងយល់ពីដំណាំស្រូវ។ ការយល់ដឹងពីលក្ខណៈរូបសាស្ត្ររបស់ដំណាំស្រូវមានសារសំខាន់ណាស់ ក្នុងការងារជ្រើសរើសពូជ ការបង្កាត់ពូជ និងការងារគ្រប់គ្រងដំណាំស្រូវ ដើម្បីបង្កើនទិន្នផល ។ ជាទូទៅ ដើមស្រូវត្រូវបានបែងចែកជា ឫស ដើម ស្លឹក កួរ និងគ្រាប់ (រូបភាព១) ។

សរីរាង្គលូតលាស់ របស់ដំណាំស្រូវរួមមាន គ្រាប់ស្រូវ ឫសស្រូវ ដើមស្រូវ និងស្លឹកស្រូវ (រូបភាព ២) ។




**រូបភាពទី១ លក្ខណៈរូបសាស្ត្ររបស់ដើមស្រូវ**

### ១.១ - គ្រាប់ស្រូវ

គ្រាប់ស្រូវមួយ ផ្សំឡើងដោយសំបកគ្រាប់ គ្រាប់អង្ករសម្រូប ស្មែង និងទងគ្រាប់។ ។ គ្រាប់អង្ករសម្រូបត្រូវបានរុំព័ទ្ធដោយសំបកគ្រាប់ ដែលផ្នែកទាំងពីរនេះ ភ្ជាប់ជាមួយទងគ្រាប់ ។ សំបកគ្រាប់មានសភាពរឹងដែលស្រោបគ្រាប់អង្ករសម្រូបពីខាងក្រៅ។ កាលណាគេយកសំបកនេះចេញពីគ្រាប់អង្ករ គេហៅថា អង្កាម ។ សំបកគ្រាប់ចែកចេញជាពីរផ្នែកគឺ សំបកធំ ឫសំបកពោះ និងសំបកតូច ឫសំបកខ្នង ។សំបកធំ និង សំបកតូច មានមុខងារសំខាន់ណាស់សម្រាប់ការពារនូវជាលិការបស់គ្រាប់អង្ករ កំណត់ទម្រងទំហំនៃគ្រាប់ ព្រមទាំងរយៈពេលដុះពន្លកឫសនៃគ្រាប់។ កាលណាសំបកគ្រាប់មានកម្រាស់ស្តើង នោះការដុះពន្លកគ្រាប់បានឆាប់ តែផ្ទុយមកវិញប្រសិនបើសំបកគ្រាប់មានកម្រាស់ក្រាស់ នោះរយៈពេលនៃការដុះពន្លកគ្រាប់យូរ ។ គ្រាប់ស្រូវនៅពេលដែលគេបកយកសំបកគ្រាប់ ឫអង្កាមចេញ គេហៅថាអង្ករសម្រូប។ គ្រាប់អង្ករសម្រូបត្រូវបានហ៊ុំព័ទ្ធដោយស្រទាប់សម្រូបខាងក្រៅ និងស្រទាប់សម្រូបខាងក្នុង ដែលផ្ទុកទៅដោយខ្លាញ់ ប្រូតេអ៊ីន និងវីតាមីន។ នៅខាងក្នុងស្រទាប់ទាំងពីរនេះ គឺសាច់គ្រាប់ ជាផ្នែកសារធាតុចិញ្ចឹមនៃគ្រាប់ទុំ ហើយដែលអាចទ្រទ្រង់ការដុះលូតលាស់នៃពន្លកបាន ។ សារធាតុទាំងនោះជាអាហារធាតុបម្រុងចាំបាច់សម្រាប់ដំណើរការដំណុះគ្រាប់។

### ១.២ - ឫសស្រូវ

ឫសគឺជាបណ្តុំសរីរាង្គដែលប្រមូលផ្តុំឡើងដោយសសៃរចាក់ស្រេះចូលគ្នាដោយចៃដន្យ និងកំណត់ដោយសសៃតូចៗជាច្រើន ។ ឫសស្រូវចាប់កើតមានឡើង តាំងពីគ្រាប់ស្រូវចាប់ដុះពន្លក នៅពេលគេយកទៅធ្វើដំណុះ ហើយមានមុខងារក្នុងការជួយទ្រទ្រង់ដល់ការលូតលាស់របស់សំណាប និងបន្តបន្ទាប់មក ឫសស្រូវ

ចាប់ផ្តើមដុះចេញពីសរីរាង្គផ្សេងៗ ផ្នែកខាងក្រោមរបស់ដើមដូចជា គល់ខ្នែងបែកដំបូង និង ថ្នាំងរបស់ដើម ។ ឫសស្រូវ ចែកចេញជា ៣ គឺ ឫសកែវ ឫសព្រយោង និងឫសខ្យល់ (រូបភាព ៣.៦)។




**រូបភាពទី២ លក្ខណៈរូបសាស្ត្រនៃឫសរបស់ដំណាំស្រូវ**

- **ឫសកែវ**

ឫសកែវ គឺជាឫសដំបូងបង្អស់ដែលដុះចេញពីគ្រាប់ស្រូវ នៅពេលដែលស្រូវចាប់ផ្តើមដុះពន្លកដំបូង ហើយឫសនេះមានអាយុពី ១ ទៅ ៣០ ថ្ងៃ ប៉ុណ្ណោះ។ ឫសកែវដុះចេញក្នុងរយៈពេល ២ ទៅ ៣ ម៉ោង បន្ទាប់ពីស្រោមពន្លកឫសលេចឡើង (ដុះចេញ) ។ ឫសកែវនឹងងាប់ទៅវិញក្នុងរវាងអាយុ ១ ខែ នៅក្រោយពេលដែលឫសព្រយោងចាប់ផ្តើមដុះ និងកើនឡើងជាបន្តបន្ទាប់ ។ ឫសកែវមានមុខងារ ស្រូបយកទឹក សម្រាប់ផ្តល់ឱ្យគ្រាប់ធ្វើប្រតិកម្មបំលែងម្សៅអាមីដុង បង្កើតទៅជាស្ក រ និងបំលែងសារធាតុចិញ្ចឹមផ្សេងៗទៀត ដើម្បីផ្តល់ឱ្យពន្លកដើមអាចរស់រានមានជីវិត ។

- **ឫសព្រយោង**

ឫសព្រយោងជាប្រភេទឫសដែលដុះចេញពីគល់ថ្នាំងនៃដើមស្រូវកប់ក្នុងដី វាមានតួនាទីសម្រាប់ជាជំនួយដល់ឫសកែវ ។ នៅពេលដែលស្រោមពន្លកឫសចាប់ផ្តើមដុះ ស្រោមពន្លកស្លឹកក៏ដុះចេញដែរ។ បន្ទាប់មកថ្នាំងពន្លកបានដុះចេញ ដែលថ្នាំងនេះជាថ្នាំងដំបូងបង្អស់របស់ដើមស្រូវ ។ នៅពេលដែល ដើមស្រូវដុះស្លឹកទី ៣ នៅផ្នែកខាងចុងនៃថ្នាំងពន្លក ឫសព្រយោងក៏ចាប់ផ្តើមដុះឡើង។ ការលូតលាស់របស់ឫសព្រយោង និងស្លឹកមានទំនាក់ទំនងជាមួយគ្នា គឺមានន័យថាប្រសិនបើប្រវែងនៃស្លឹកស្រូវលូតបានប្រវែងត្រឹមណា នោះឫសព្រយោងក៏លូតលាស់បានដល់ត្រឹមនោះដែរ ។ ឫសនេះមាន មុខងារ សម្រាប់ទ្រទ្រង់ជំហរដើមស្រូវមិនឱ្យដួល ស្រូបយកទឹក និងសារធាតុចិញ្ចឹម ជាពិសេសសារធាតុអាសូត ផូស្វ័រ ប៉ូតាស្យូមពីក្នុងដី។ នៅខាងក្បាលឫស មានស្រោមរឹងព័ទ្ធជុំវិញដើម្បីការពារឫស និងជាជំនួយដល់ឫសក្នុងការទម្លុះចូលក្នុងដី ដែលស្រោមនេះគេហៅថាលលាដឫស ។

- **ឫសខ្យល់**

ឫសនេះដុះចេញពីថ្នាំងនៃដើមស្រូវនៅផ្នែកក្រោម (ឫសដែលនៅលើផ្ទៃដី) ហើយការបែកខ្នែង គឺកើតឡើងដោយឯកឯង ។ ចំពោះពូជស្រូវឡើងទឹក គេសង្កេតឃើញវាកើតចេញពីថ្នាំងខាងលើបំផុត តែនៅក្រោមស្រទាប់សើ ៗ នៃផ្ទៃទឹក ។ ឫសខ្យល់មាន ២ ប្រភេទគឺ ឫសខ្យល់ទី ១ និងឫសខ្យល់ទី ២ ។ ចំពោះពពួកស្រូវឡើងទឹក គឺមានឫសខ្យល់ទាំងពីរប្រភេទ ហើយដែលឫស់ខ្យល់ទាំងពីរនឹងចាក់ចូលទៅក្នុងដី ពេលទឹកស្រក ។ ចំពោះពពួកស្រូវដ៍ទៃទៀត គឺភាគច្រើនមានតែឫសខ្យល់ទី ១ ប៉ុណ្ណោះ ។

## ១.៣ ដើមស្រូវ

ដើមស្រូវមានតួនាទីសម្រាប់ទ្រទ្រង់ស្លឹក និងកួរស្រូវ បង្កើតដើមបែកថ្មីនិងឫស ភ្ជាប់សកម្មភាពនៃការធ្វើរស្មីសំយោគ ផ្ទុក និងដឹកជញ្ជូនជាតិទឹក សារធាតុចិញ្ចឹមផ្សេងៗ និងសម្រាប់ធ្វើការផ្គត់ផ្គង់ខ្យល់ទៅកាន់ឫស ។ ដើមស្រូវត្រូវបានចែកចេញជា ២ ផ្នែកគឺ ថ្នាំង និងចន្លោះថ្នាំង ។

- **ថ្នាំង** គឺជាផ្នែករឹងនៃដើមស្រូវដែលមានភាពតាន់ និងគ្មានប្រហោង ហើយជាកន្លែងសម្រាប់បង្កើតស្លឹក និងពន្លកខ្នែងនៃដើមស្រូវ ។ ពន្លកខ្នែងមានទីតាំងនៅចន្លោះរបស់ថ្នាំង និងគល់ស្រទបស្លឹក។ ចំណែកថ្នាំងដែលនៅខាងចុងនៃដើម ជាថ្នាំងដែលបង្កើតកួរស្រូវ ។
- **ចន្លោះថ្នាំង** ជាផ្នែករលោងហើយមានលក្ខណៈរឹង និងតាន់នៅពេលដែលវានៅខ្ចី ប៉ុន្តែប្រែក្លាយទៅជាមានប្រហោងនៅពេលវាកាន់តែចាស់ ។ ចន្លោះថ្នាំងខាងក្រោមជាទូទៅខ្លីៗខុសពីចន្លោះថ្នាំងខាងលើដែលវែងៗ ។ ចន្លោះថ្នាំងនេះតភ្ជាប់គ្នាបានពីមួយទៅមួយដោយសារថ្នាំង ។ ចំពោះចន្លោះថ្នាំងរបស់ស្រូវមានច្រើន ឬតិច គឺអាស្រ័យទៅតាមប្រភេទពូជផ្សេងៗគ្នា ដោយសារពូជខ្លះមានចន្លោះថ្នាំងច្រើនដែលធ្វើឱ្យដើមមានកម្ពស់ខ្ពស់ និងពូជខ្លះទៀតមានចន្លោះថ្នាំងតិចដែលធ្វើឱ្យដើមមានកំពស់ទាប។ ជាទូទៅចន្លោះថ្នាំងចាប់ផ្តើមលូតបណ្តោយ ឬលូតប្រវែង ចាប់ពីផ្នែកខាងក្រោមទៅ ផ្នែកខាងលើនៃដើមស្រូវ ។ ចន្លោះថ្នាំងដែលនៅផ្នែកខាងលើបំផុតនៃដើមស្រូវ តែងតែមានទំហំតូច ជាពិសេសចន្លោះថ្នាំងដែលផ្ទុកផ្កា និងគ្រាប់ ។

## ១.៤ ស្លឹកស្រូវ

ស្លឹកស្រូវទាំងអស់ត្រូវបានទ្រដោយដើម ហើយតំរៀបជាពីរជួរ ។ គេសង្កេតឃើញថា នៅផ្នែកខាងលើនៃថ្នាំងមួយ គឺមានដុះស្លឹកមួយ ដែលមានពីរផ្នែកគឺស្រទបស្លឹក និងបន្ទះស្លឹក (រូបភាពទី៣)។ ក្នុងមួយវដ្ដជិវិតរបស់ដើមស្រូវមានស្លឹកពី ១០ ទៅ ២០ ប៉ុន្តែមានតែស្លឹកពី ៥ ទៅ ១០ ប៉ុណ្ណោះ ដែលនៅរស់រហូតដល់ពេលប្រមូលផលគ្រាប់។ ចំណែកស្លឹកដទៃទៀត ចាប់ផ្តើមស្វិត និងងាប់បន្តបន្ទាប់ទៅតាមការអភិវឌ្ឍន៍ នៅក្នុងវគ្គនីមួយៗនៃដំណាំស្រូវ។ ស្លឹកខាងលើបំផុតដែលស្ថិតនៅខាងក្រោមកួរគឺជា **ស្លឹកទង់ជ័យ ឬស្លឹកអមកួរ** ។ ស្លឹកនេះមានមុខងារសម្រាប់ទទួលពន្លឺ និងដឹកនាំការធ្វើរស្មីសំយោគ សកម្មភាពដំណកដង្ហើម បំភាយចំហាយទឹក សម្រាប់ផ្ទុកអាហារចិញ្ចឹមផ្សេងៗ សម្រាប់នាំខ្យល់ទៅឱ្យឫស ដើម និងស្រទបស្លឹក ដែលស្ថិតនៅក្នុងទឹក។ នៅផ្នែកតភ្ជាប់ និងបន្ទះស្លឹក មានសរីរាង្គបីទៀតគឺ ចង្កុំស្លឹក អណ្តាតស្លឹក និងត្រចៀកស្លឹក ។

**រូបភាព ៧**
**ស្លឹកស្រូវ**




### ស្រទបស្លឹក និងបន្ទះស្លឹក

ស្រទបស្លឹក ស្ថិតនៅផ្នែកខាងក្រោមនៃស្លឹក ដែលស្រោបរុំព័ទ្ធជុំវិញដើម។ ជួនកាលស្រទបស្លឹក និងបន្ទះស្លឹកតភ្ជាប់គ្នានៅចន្លោះថ្នាំង ។ ស្រទបស្លឹកដែលស្ថិតនៅត្រង់គល់ថ្នាំង មានរាងប៉ោងចេញ ដែលគេឱ្យឈ្មោះថា ផ្នែកប៉ោងនៃស្រទបស្លឹក ។ បន្ទះស្លឹក គឺជាផ្នែកខាងលើនៃស្លឹក មានរាងជាបន្ទះស្រួច ហើយរាបស្មើ។ នៅផ្នែកខាងក្រោមនៃផ្ទៃស្លឹកចំកណ្តាល មានទ្រនុងធំមួយ លយចេញជាងគេ គឺជាទ្រនុង កណ្តាលនៃស្លឹក។ ផ្ទៃខាងលើនៃបន្ទះ ស្លឹកមានជួរ ឆ្នូតៗ ជាច្រើន ដែលស្របគ្នាជាមួយទ្រនុងស្លឹក។ ស្លឹក ដុះចេញមកឆ្លាស់គ្នានៅលើដើម។

### ចង្កំស្លឹក អណ្តាតស្លឹក និងត្រចៀកស្លឹក

ចង្កំស្លឹក គឺជាផ្នែកមួយសម្រាប់តភ្ជាប់រវាងស្រទបស្លឹក និងបន្ទះស្លឹក ឬជាផ្នែកដែលខណ្ឌស្រទ បស្លឹក និងបន្ទះស្លឹក។ អណ្តាតស្លឹក គឺជាភ្នាសស្តើងឈរត្រង់ទៅលើ ហើយស្ថិតនៅខាងក្នុងបន្ទះស្លឹក ពោលគឺនៅកន្លែងណាដែលបន្ទះស្លឹកតភ្ជាប់នឹងស្រទបស្លឹក ។ ទំរង់របស់វាមានសភាពស្តើងស្រួចចុង ដែលចុងនោះអាចបែកជាពីរ ឬមិនបែកអាស្រ័យដោយពូជ ។ ត្រចៀកស្លឹកគឺជា ព្រុយមួយគូរដែលចិតនៅគែមសងខាងផ្នែកគល់ខាងក្រោយនៃបន្ទះស្លឹកស្រូវ ។ ជាធម្មតាត្រចៀកស្លឹកលូតឡើងនៅផ្នែកចំហៀង ពោលគឺ កន្លែងដែលអណ្តាត និងគល់នៃចង្កំស្លឹកតភ្ជាប់គ្នា ។ អណ្តាតស្លឹក និងត្រចៀកស្លឹក ជាសរីរាង្គដែលសំខាន់ បំផុតក្នុងការកំណត់ពីភាពខុសគ្នារវាងដំណាំស្រូវ និងស្មៅក្នុងដំណាក់កាលលូតលាស់ ។ ជាទូទៅស្លឹករបស់ពូជស្រូវទាំងអស់ គឺមានសរីរាង្គទាំងពីរនេះ ផ្ទុយទៅវិញស្លឹកស្មៅ គឺអាចគ្មានមានសរីរាង្គទាំងពីរនេះ ឬក៏មានតែមួយប៉ុណ្ណោះ ។

## ២. វដ្តជីវិតដំណាំស្រូវ

ក្នុងមួយវដ្តជីវិតដំណាំស្រូវគឺចាប់ពីគ្រាប់ដុះពន្លករហូតដល់ទុំ ចែកចេញជា ៣វគ្គធំៗ គឺ ៖

- វគ្គលូតលាស់ ៖ ចែកចេញជា ៤ ដំណាក់កាល គឺដំណាក់កាលដុះ ពន្លក ដំណាក់កាលសំណាប ដំណាក់កាលបែកគុម្ព និងដំណាក់កាលពន្លូតដើម ។ នៅក្នុងវគ្គនេះ មានរយៈពេលមិនកំណត់ គឺអាស្រ័យទៅតាមប្រភេទពូជ។
- វគ្គបង្កបង្កើតផល ៖ មាន ៣ដំណាក់កាល គឺដំណាក់កាលកកើតកួរដំបូង ដំណាក់កាលដើម និងដំណាក់កាលចេញផ្កា ដែលមានរយៈពេលប្រហែល ៣៥ថ្ងៃ ។ វគ្គនេះមានសារៈសំខាន់ណាស់ក្នុងការប្រើ ប្រាស់ជីឱ្យចំពេលវេលា និង តម្រូវការរបស់ដំណាំស្រូវ ។
- វគ្គទុំ ៖ ចែកចេញជា ៣ ដំណាក់កាល គឺ ដំណាក់កាលដាក់ទឹកដោះ ដំណាក់កាលដាក់ម្សៅ និងដំណាក់កាលទុំ ដែលមានរយៈពេលប្រហែល ៣០ថ្ងៃ ។

## ២.១. វគ្គលូតលាស់

### ដំណាក់កាលដុះពន្លក

ដំណាក់កាលដុះពន្លកជាដំណាក់កាលដំបូងនៃវគ្គលូតលាស់ គឺចាប់ពីគ្រាប់ដុះពន្លករហូតដល់ចេញស្លឹកទីមួយ ដែលមានរយៈពេល ពី ៥-៧ថ្ងៃ។ នៅដំណាក់កាលនេះ មានសកម្មភាពជាច្រើន មុនពេលយកគ្រាប់ពូជទៅសាប ព្រោះ ដូចជាការត្រាំ ការផ្អាប់ឱ្យមានកំដៅ ការស្រោចទឹកពេលស្ងួ តខ្លាំងជាដើម។ ពេលសាបព្រោះត្រូវធ្វើដីឱ្យរាបស្មើ ជំរៅទឹកទាបបំផុត ។ បើសិនគ្រាប់លិចក្នុងទឹកជ្រៅពេក អំប្រីយ៉ុងលូតលាស់យឺតធ្វើឱ្យដើមសំណាបរាវ តូច ខ្សោយ ពេលយកទៅ ស្ទូងលូតលាស់យឺត។ កត្តាដែលនាំ ឲ្យគ្រាប់ដុះពន្លកមានៈ កត្តាទឹក ពន្លឺ ខ្យល់ សីតុណ្ហភាព ហើយពន្លកមានតួនាទី ស្រូបយកទឹក និងវិវឌ្ឍន៍ទៅជា ដើម ឬស ដែលចិញ្ចឹមដោយអង់ដូស្ពែម ។

### ដំណាក់កាលសំណាប

ដំណាក់កាលសំណាប គឺចាប់ពីចេញស្លឹកទីមួយរហូតដល់បែកក្លៀងទីមួយ ដែល មានរយៈពេលប្រហែល ១០-១៥ ថ្ងៃ អាស្រ័យតាមពូជ វិធីសាស្រ្តដាំដុះ និងកត្តាផ្សេងៗទៀត ។ នៅក្នុងថ្នាលសំណាបជៀសវាងកុំឱ្យមានទឹកជ្រៅពេក ជា ហេតុធ្វើឱ្យដើមសំណាបវែងពុំមាំមួន និងដួលបាក់នៅពេលស្ទូង ។ ការលូតលាស់ មាំមួនរបស់ដំណាំស្រូវ ជាប្រការមួយដែលអាចជួយ បន្ថយ នូវឥទ្ធិពលនៃការខូចខាតស្លឹកស្រូវ ។ ដើមនិមួយៗផលិតស្លឹកជាច្រើន ដែលជាទូទៅស្លឹកអាចកើតមាន ១៦សន្លឹកយ៉ាងឆាប់រហ័ស តែស្លឹកងាប់ និងកើតស្លឹកថ្មីជំនួសវិញយ៉ាងឆាប់ដែរ ។ នៅសប្តាហ៍ដំបូង រឺសប្តាហ៍ទី ២ ឬ ទី ៣ ក្រោយស្ទូងការខូចខាតផ្នែកខ្លះនៃដំណាំស្រូវ វាមិនបង្កឱ្យបាត់បង់ទិន្នផលទេ ។ ដំណាំស្រូវលូតលាស់បំពេញសងវិញដោយស្លឹកដើមថ្មី នឹងកើតយ៉ាងឆាប់រហ័សដែរ ។ ក្រោយពេលស្ទូង ជីជាតិក្នុងដីដែលបានមកពីការប្រើជីទ្រាប់បាត និងការផ្តល់ទឹកបានល្អ គឺជាត ម្រូវការចាំបាច់សម្រាប់រក្សាការលូតលាស់បន្តរបស់ដំណាំស្រូវ។ ការ ដាំដុះដំណាំរឹងមាំល្អ អាចបន្ថយឥទ្ធិពលនៃការខូចខាតដោយជំងឺ និងសត្វ ចង្រៃ ។ នៅក្នុងដំណាក់កាល នេះយើងតែងជួបប្រទះ សត្វ ល្អិតជាច្រើនដូចជា ៖ ទ្រីប ដង្កូវមូរស្លឹក មមាច ដង្កូវបំពង់កាត់ស្លឹកជាដើម។

### ដំណាក់កាលបែកគុម្ព

ដំណាក់កាលបែកគុម្ពចាប់ពីបែកក្លៀងទី១រហូតដល់បែកក្លៀងច្រើនបំផុត មានរយៈពេលប្រហែល ២០-៣០ថ្ងៃ ។ ស្រូវ គឺជាដំណាំដែលមានលទ្ធភាពក្នុងការបែកគុម្ពខ្លាំង ។ បែកគុម្ព គឺជាដំណើរការមួយដែលក្នុងនោះ ដើមបែកថ្មីៗ បានដុះលូតលាស់ចេញពីដើមមេ ឬដើមបែកចាស់ៗ ។ លទ្ធភាពនៃការបែកគុម្ព គឺជាលក្ខណៈដ៏មានសារៈសំខាន់មួយនៃពូជទំនើប ។ ជាទូទៅ ជីជាតិជាច្រើនបានប្រើសំរាប់តែពីរ ឬបីដើមប៉ុណ្ណោះ ចំពោះ ពូជប្រពៃណី ។ ចំពោះពូជទំនើប លទ្ធភាព បង្កើតដើមច្រើន ទាក់ទងទៅនឹងលទ្ធភាពនៃការប្រើប្រាស់ជីអាសូតច្រើន ។ ចំពោះពូជប្រពៃណី អាសូតច្រើនធ្វើឱ្យដើមខ្ពស់ ហើយ អាចដួលនៅពេលស្រូវទុំ ។

ដើមបែករបស់ ដំណាំស្រូវ ត្រូវបានចែកជាដើមមេ ដើមបែកទីមួយ ដើមបែកទីពីរ និងដើមបែកទីបី ។ ដើមមេគឺជាដើមដែលដុះចេញពីគ្រាប់ ហើយចេញពីដើមមេនេះមានដើមបែកទីមួយជាច្រើន ដុះចេញមកតាមលំដាប់លំដោយនៃថ្នាំង ។ ដើមបែកទីពីរ គឺជាដើមបែកដែលដុះចេញពីដើមបែកទីមួយ ហើយដើមបែកទីបី គឺជាដើមបែកដែលដុះចេញពីដើមបែកទីពីរ ។ ចំនួនដើមបែក គឺអាស្រ័យទៅលើពូជ រយៈពេលលូតលាស់ លក្ខខណ្ឌដាំដុះ (ពន្លឺ និងសារធាតុចិញ្ចឹម) និងវិធីសាស្ត្រដាំដុះ ។ ដើមមេ និងដើមបែកទី ១ ផ្តល់ផលច្រើនជាងគេនៅក្នុងគុម្ព ជាពិសេសចំពោះពូជដែលមានអាយុកាលខ្លី ។ ដើ មបែកទី ២ ផ្តល់ផលល្អដែរ ប៉ុន្តែផ្នែកខ្លះមានពណ៌បៃតងនៅពេលច្រូតកាត់ ។ ភាគច្រើនដើមបែកទី ៣ មិនអាចបង្កើតកួរបាន បើសិនជាជីជាតិ ពន្លឺ ថ្ងៃ និងទឹកមិន គ្រប់គ្រាន់ ។




**រូបភាព ៤ ប្រព័ន្ធបែកគុម្ពនៃដំណាំស្រូវ**

ការបំផ្លាញដោយដង្កូវស៊ីរូងដើមនៅដំណាក់កាលដំបូង គេ ពុំឃើញ មានឥទ្ធិពលអ្វីទៅលើទិន្នផលទេ ពីព្រោះដើមងាយស្រួលបែកជំនួសវិញ ។ ការពិសោធន៍នៅ IRRI បង្ហាញឲ្យឃើញថា មិនបាត់បង់ទិន្នផលទេ

នៅពេលដើមស្រូវ ៣០% ត្រូវបានបំផ្លាញដោយដង្កូវស៊ីរូងដើម នៅក្នុងវគ្គលូតលាស់ ។ ការដុះលូតលាស់នៃដើម និងស្លឹកថ្មី គឺកំណត់ដោយចន្លោះគុម្ព ពន្លឺថ្ងៃ ទឹក និ ងជីជាតិ ផ្តល់ឱ្យដំណាំ ។ នៅដំណាក់កាល នេះ មានសត្វល្អិតបំផ្លាញជាច្រើនដូចជា ដង្កូវមូរស្លឹក មមាចគ្រប់ប្រភេទ ដង្កូវស៊ីរូងដើម ដង្កូវបំពង់កាត់ស្លឹក ។

**ដំណាក់កាលពន្លូតដើម**

ដំណាក់កាលពន្លូតដើមជាដំណាក់កាលមួយមិនច្បាស់លាស់ទេ វាអាចពន្លូតដើមតទៅទៀតនៅដំណាក់កាលកកើតកួរ តែគេត្រូ វគិតពីបែកគុម្ពពេញទំហឹង រហូតដល់កកើ តកួរដំបូង ។ ដំណាក់កាលនេះមានតួនាទីពន្លូតដើមឱ្យវែង ដោយការ ពន្លូតចន្លោះថ្នាំង ។ ដំណាក់កាលនេះត្រូវការថែទាំឱ្យ បានជិតដល់ដូចជាការ បោចស្មៅ ការ បញ្ចូលទឹក ការបាច ជីបំប៉ន និងការគ្រប់គ្រងសត្វល្អិត ជំងឺ ។ ដំណាក់កាល នេះ យើងតែងតែ ជួបប្រទះសត្វល្អិតជាច្រើន ដូចនៅដំណាក់កាលបែកគុម្ពដែរ ។

**២.២ វគ្គបង្កើតផល**

**ដំណាក់កាលករកើតកួរ**

ដំណាក់កាលករកើតកួរ ចាប់ពីស្រូវកកើតកួរដំបូងមានរាងជារោមសំឡី រហូតដល់មានរាងជាកោណប្រវែងប្រហែល១.៥សម ដែលមានរយៈពេលប្រហែល ១០ថ្ងៃ និងមានតួនាទីបង្កើតកួរដំបូង ដែលមានលក្ខណៈសៗ ដូចសំឡី ។ នៅ ក្នុងដំណាក់កាលនេះ ត្រូ វការថែទាំឱ្យបានជិតដល់ដូច ជាការបោចស្មៅ ការបញ្ចូលទឹក ការបាចជីបំប៉ន ការគ្រប់គ្រងសត្វល្អិត និងជំងឺ ។ ចំពោះការថែទាំទឹក ត្រូវរក្សាទឹកត្រឹ មពាក់កណ្តាលដើម ឬក្រោមបន្តិច ជៀសវាងបញ្ចូលទឹករហូតដល់បង្គាប ។ ដំណាក់កាលនេះជា ដំ ណាក់កាលសំខាន់បំផុតក្នុងការប្រើប្រាស់ជីបំប៉ន ព្រោះវាចំ និងតំរូវការជីជាតិរបស់ស្រូវ ស ម្រាប់បង្កើតកួរឲ្យបានធំចំនួនគ្រាប់ច្រើន ។ យើងតែង ជួបប្រទះបញ្ហា ជាច្រើនដូចជា ដង្កូវស៊ីរូងដើម ដង្កូវបំពង់កាត់ស្លឹក ដង្កូវមូរស្លឹក ដង្កូវស្នែង ដង្កូវ ភ្នែកឆ្មា មមាចត្នោត មមាចខៀវ .... ។

**ដំណាក់កាលផើម**

ដំណាក់កាលស្រូវផើម គឺពេលដែលកួររីកធំក្នុងស្រទបស្លឹក ប៉ុន្តែវាមិនទាន់ចេញមកក្រៅទេ ។ ដើមស្រូវឡើងមូល ហើយប៉ោងធំដូចផើម ។ ផ្កានៅក្នុងដើមនៅតូច និងផុយ ប៉ុន្តែមិនទាន់ បង្កាត់នៅឡើយទេ ។ ដំណាក់កាលនេះមានរយៈពេលប្រហែល ១២ ថ្ងៃ ។ ដំណាក់កាលស្រូវផើម គឺឆាប់ទទួលរងនូវជម្ងឺ និងការបំផ្លាញដោយសត្វល្អិតចង្រៃនៅលើស្លឹកទង់ជ័យណាស់ ។ គុណភាពនៃផ្កា និងការបង្កើតលំអង គឺត្រូវ កំណត់នៅក្នុងដំណាក់កាលនេះ។ ទឹក ត្រូវតែមាននៅក្នុងស្រែជានិច្ច ។ ដង្កូវស៊ីរូងដើម អាចមានសកម្មភាព នៅពេលស្រូវផើម វាងាយចោះចូលទៅក្នុងដើមស្រូវ ។

**ដំណាក់កាលចេញផ្កា**

ចេញផ្កាគឺជាដំណាក់កាលមួយ ដែលកួរចេញផុតពីស្រទបស្លឹក ហើ យផ្កាញី និងផ្កាឈ្មោលទុំអាច បង្កកំណើតបាន ។ ដំណាក់កាលចេញផ្កាជាការពិតមានរយៈពេលខ្លីណាស់ សំរាប់គ្រាប់ស្រូវមួយគ្រាប់ ប៉ុន្តែ វាមានរយៈពេលវែងសំរាប់ដំណាំទាំងមូល ។ ផ្នែកផ្កាបានរីកចំរើនរួចជាស្រេចទើបចេញកួរ ។ ជាទូទៅ ដំណាំស្រូវបើកផ្កាសំរាប់ពេលបង្កាត់ គឺនៅពេលព្រឹក ៩៨ ភាគរយនៃគ្រាប់ នឹងបង្កាត់ដោយខ្លួនឯងសិន មុននឹងបើកផ្កា ។ ការបង្កាត់ប្រភេទនេះ បានន័យថាពូជស្រូវមានលំនឹងច្រើនជំនាន់ អាចឱ្យកសិករ ទុកពូជ បាន។ ដំណាក់កាលនេះមានរយៈពេលប្រហែល ១០ថ្ងៃ ហើយនៅក្នុងដំណាក់កាល នេះដែរ វាងាយនឹង ទទួលរងនូវការបំផ្លាញណាស់ ដូច ជាដង្កូវមូរស្លឹកលើស្លឹកទង់ជ័យ វាធ្វើ ឲ្យទិន្នផលថយចុះ បើសិនកើតធ្ងន់ ធ្ងរ ដង្កូវស៊ីរូងដើម និងទទួលការបំផ្លាញខ្លាំងពីសត្វកណ្តុរ ។

## ២.៣ វគ្គទុំ

### ដំណាក់កាលដាក់ទឹកដោះ

ដំណាក់កាលស្រូវដាក់ទឹកដោះ គឺបន្ទាប់ពីដំណាក់កាលចេញផ្កា ។ គ្រាប់ស្រូវចាប់ផ្តើមបំពេញ ដោយជាតិម្សៅរាវ ដែល ផលិតដោយស្លឹកទង់ជ័យ ។ គ្រាប់ស្រូវ និងបន្តបំពេញពេញទំ ហំធំបំផុតនៃគ្រាប់ ទោះបីជាមិនពេញទំហំគ្រប់គ្រាប់ទាំងអស់ក៏ដោយ ។ នៅក្នុងដំណាក់កាលគ្រាប់ស្រូវដាក់ទឹកដោះ គឺជា ដំណាក់កាលមួយ ដែលកំណត់នៃគ្រាប់ពេញ ។ ពូជខ្លះអាចនឹងដាក់គ្រាប់ពេញទាំង អស់ ហើយពូជខ្លះទៀត មិនអាចដាក់គ្រាប់ពេញទាំងអស់បានទេ គឺស្កុកនៅផ្នែកខាងក្រោមនៃកួរ ។ ពេលខ្លះ គ្រាប់ស្រូវមិនអាចដាក់ គ្រាប់នៅផ្នែកខាងចុង និងរហូតមកដល់ផ្នែកខាងក្រោមនៃកួរ ដោយសារតែខ្វះទឹក ជីជាតិ ដី ពន្លឺ និងកត្តា ផ្សេងៗទៀត ។ គ្រាប់ស្រូវដាក់ទឹកដោះ គឺងាយបំផ្លាញយ៉ាងខ្លាំង ពីស្រឹងបំផ្លាញគ្រាប់ ។ នៅក្នុងដំណាក់ កាល នេះសត្វល្អិតចង្រៃនេះវាជញ្ជក់យកទឹកដោះពីគ្រាប់ស្រូវ ។ នៅពេលគ្រាប់ស្ថិតក្នុងដំណាក់កាលដាក់ ម្សៅ ស្រឹងមិនអាចបំផ្លាញបានទេ ។ កួរស្រូវមិនធន់ផងដែរ ចំពោះដង្កូវស៊ីរូងដើម ។ បើសិនជាផ្នែកខាង ក្រោមនៃកួរ ស្រូវត្រូវកាត់ផ្តាច់នោះ កួរស្រូវនឹងទៅជាកួរស គ្រាប់ស្កុទាំងអស់ ។ ឯកណ្តុរក៏ជាបញ្ហាធំមួយដែរ នៅក្នុងដំណាក់ កាលនេះ ព្រោះជាដំណាក់កាលដែលវាចូលចិត្ត ។

### ដំណាក់កាលដាក់ម្សៅ

ដំណាក់កាលស្រូវដាក់ម្សៅ គឺជាដំណាក់កាលស្វាគមន៍មួយរបស់កសិករភាគច្រើន ពីព្រោះតាមកត់ សំគាល់ នេះជាទីបញ្ចប់នៃកត្តាចង្រៃសំខាន់ៗរបស់ដំណាំស្រូវ ។ ប៉ុន្តែនៅដំណាក់កាលនេះ អាចនឹ ងជួប បញ្ហាមួយចំនួនដូចជាដង្កូវស្នែងកាត់បំផ្លាញកួរស្រូវ រី ពួកជម្ងឺផ្សិតខ្លះ ធ្វើ ឲ្យគុណភាពគ្រាប់ស្រូវថយចុះ ។ ចំនុចសំខាន់ នៅដំណាក់កាលនេះ គឺជាការព្យាយាមថែរក្សារហូតដល់គ្រាប់ស្រូវទុំ ។ ទោះបីយ៉ាងណា យើងតែងសង្កេតឃើញ គ្រាប់ខ្លះស្ទើរតែស្ថិតក្នុងដំណាក់កាលដាក់ម្សៅ ខ្លះស្ថិតក្នុង ដំណាក់កាលដាក់ទឹកដោះ និងខ្លះទៀតនៅចេញផ្កានៅឡើយ ។ ពេលប្រមូលផល យើងចង់បានស្រែស្ថិតក្នុងដំណាក់កាលតែមួយគត់ ។ ចំណុចសំខាន់ពីដំណាក់កាលដាក់ម្សៅរហូតដល់ស្រូវទុំ គឺជាការចង់បានអោយស្រូវទុំបានល្អ ដោយការគ្រប់ គ្រងទឹកបានល្អ និងពេលជាមួយគ្នានោះ ជៀសវាងការបំផ្លាញរបស់ សត្វកណ្តុរ ។ ការបង្ហូរទឹកចេញ ពីស្រែ

១០ថ្ងៃ មុនពេលប្រមូលផល គឺជាការអនុវត្តន៍ជាទូទៅ ។ តំបន់ទំនាបខ្លះ ការ បង្ហូទឹកមានការលំបាក ឬពុំអាចធ្វើទៅបាន ត្រូវធ្វើតាមកូនប្រឡាយតូចៗ ។ ទោះជាយ៉ាងណាក៏ដោយ ការបង្ហូ រទឹកចេញពីស្រែ អាចបង្កើននូវការបំផ្លាញពីកណ្ដុរផងដែរ ។ បើសិនជាការ ទុំនៅស្រែមិនស្រុះ ពេលនោះទិន្នផលនឹងបានទាប ។

**ដំណាក់កាលទុំ**

នៅដំណាក់កាលស្រូវទុំ យើងពិនិត្យឃើញដើមស្រូវនៅក្នុងស្រែមានពណ៌លឿង ឬពណ៌ត្នោត ។ ស្លឹកស្រូវមានពណ៌លឿង ពីព្រោះនៅ ដំណាក់កាលនេះ ជាតិបៃតងរបស់ស្លឹកផ្អាក សកម្មភាពក្នុងការធ្វើរស្មីសំយោគ ។ សារធាតុដែលឬស ដើម ស្លឹកស្រូ បយកបានទាំងអស់ នៅដំណា ក់កាលនេះ គឺត្រូវប្រមូលផ្តល់ទៅឲ្យគ្រាប់ស្រូវ ។ នៅពេលស្រូវទុំ គ្រាប់វាដាក់ម្សៅពេញ ។ ជា ការពិតណាស់ ទ ម្ងន់របស់គ្រាប់ត្រូវថយចុះជារៀងរាល់ថ្ងៃ ព្រោះគ្រាប់ស្ងួត សំណើមថយចុះ ។ យើងអាចច្រូតកាត់ នៅពេលដែលស្រូវ ភាគច្រើនមានពណ៌លឿង និងគ្រាប់ស្រូវនៅផ្នែកក្រោមនៃកួររឹង។ នៅដំណាក់កាលនេះ សំណើមគ្រាប់មាន ពី ២០–៣០ % ។ ដូចច្នេះទិន្នផលស្រូវជាគំរូ ត្រូវគិតយ៉ាងដូចម្ដេច បើចង់ ប្រៀបធៀបទិន្នផលស្រូវកន្លែងមួយ ធៀបទៅនឹងកន្លែងមួយទៀត ហើយបើមួយស្ងួត និងមួយសើម ? ចំលើយគឺត្រូវពិនិត្យសំណើមក្នុងគ្រាប់ ។ មធ្យោបាយមួយសម្រាប់វាស់សំណើម គឺថ្លឹងគ្រាប់មុនពេលហាល ហើយ ហាលសំងួតជាច្រើនម៉ោងច្រើនថ្ងៃ អាស្រ័យទៅតាមកំដៅ ។ បន្ទា ប់ពីគ្រាប់ស្រូវស្ងួតល្អហើយ ត្រូវថ្លឹងគ្រាប់ ម្ដងទៀត ។ ការខុសគ្នារវាងទំងន់មុន ពេលហាល និងក្រោយហាលជាបរិមាណទឹកដែលបាត់បង់នៅពេលហាលស្ងួត ។ ការហាលសំងួតឲ្យកំរិតសំណើមនៅទាប យើងអាចស្តុកទុកបានជាច្រើនខែ ។ កំរិតសំ ណើមនៅក្នុងឃ្លាំងល្អ ត្រូវតិចជាង ១០ % ពីព្រោះសត្វល្អិតមិនអាចបំផ្លាញបាន ។

ការគណនាសំណើមមានដូចខាងក្រោម៖

$$\% \text{ សំណើម} = ១០០ \times \frac{\text{ទំងន់គ្រាប់មុនពេលហាល} - \text{ទំងន់គ្រាប់ស្ងួត}}{\text{ទំងន់គ្រាប់មុនហាល}}$$

ការសរសេររបាយការណ៍ពីទិន្នផលគំរូ ជា ទូទៅទិន្នផលត្រូវគិតនៅកំរិតសំណើម ១៤% ។ ដើម្បី សម្រួលទំងន់នៅកំរិតសំណើមផ្សេងៗមកទម្ងន់នៅកំរិតសំណើម ១៤% យើងត្រូវគណនា ដូចខាងក្រោមនេះ :

$$\text{ទម្ងន់នៅកំរិតសំណើម ១៤ \%} = \frac{(១០០ - \text{សំណើមពេលថ្លឹងទម្ងន់}) \times \text{ទម្ងន់ពេលវាស់សំណើម}}{}$$

## ប្រភេទពូជស្រូវ និងការជ្រើសរើសពូជស្រូវសម្រាប់ដាំដុះ

### ១. ប្រភេទពូជស្រូវ

ជាទូទៅពូជស្រូវ មានភាពខុសៗគ្នាទៅតាមលក្ខណៈវិនិច្ឆ័យពីរធំៗគឺ ភាពប្រកាន់រដូវ ឬពេលវេលាចេញផ្កា និងអាយុកាល ឬរយៈពេលពីដុះ ពន្លកដល់ទុំ ។ យោងតាមលក្ខណៈវិនិច្ឆ័យអំពីភាពប្រកាន់រដូវ ពូជស្រូវត្រូវបានបែងចែកជាពូជ ស្រូវប្រកាន់រដូវ និងពូជស្រូវមិនប្រកាន់រដូវ ។ យោងតាមលក្ខណៈវិនិច្ឆ័យអាយុកាល ក្រុមស្រូវប្រកាន់រដូវ និងមិនប្រកាន់រដូវ ត្រូវបានបែងចែកជាពូជស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់ ។

ពូជស្រូវប្រកាន់រដូវ គឺជាប្រភេទពូជស្រូវ ដែលចេញផ្កាក្នុងកំឡុងពេលចាប់ពីខែតុលា ដល់ខែធ្នូ ដែលនៅពេលនោះរយៈពេលថ្ងៃខ្លីជាងពេលយប់ ។ ភាពប្រកាន់រដូវរបស់ពូជស្រូវ គឺជាលក្ខណៈចាំបាច់សម្រាប់ពូជស្រូវដាំដុះក្នុងរដូវវស្សា ពីព្រោះពូជស្រូវប្រកាន់រដូវ អាចសម្របសម្រួលជាមួយ របបទឹកភ្លៀងបានងាយស្រួលជាងពូជមិនប្រកាន់រដូវ ដោយអាចពន្យាពេលវេលាដកស្ទូងនៅពេលមានកូនរដូវប្រាំង ឬពេលវេលាសាបព្រោះ ដើម្បីគេចផុតពីការបំផ្លាញរបស់សមាសភាគចង្រៃផ្សេងៗ ដោយរក្សាបាននូវពេលវេលាចេញផ្កា និងទុំនៅដដែល ឬយឺតយូរបន្តិចបន្តួច ទៅតាមភាពប្រកាន់រដូវរបស់ពូជ ។

ក្រុមពូជស្រូវស្រាលប្រកាន់រដូវ គឺសំដៅទៅលើពូជស្រូវប្រកាន់រដូវណា ដែលចេញផ្កាមុនថ្ងៃទី ១៥ ខែតុលា ។ ក្រុមពូជស្រូវកណ្តាលប្រកាន់រដូវ គឺសំដៅទៅលើពូជស្រូវប្រកាន់រដូវណា ដែលចេញផ្កាពីថ្ងៃទី ១៥ ខែតុលា ដល់ ០៧ វិច្ឆិកា ។ ក្រុមពូជស្រូវធ្ងន់ប្រកាន់រដូវ គឺសំដៅទៅលើពូជស្រូវប្រកាន់រដូវណា ដែលចេញផ្កាពីថ្ងៃទី ០៧ វិច្ឆិកា ដល់ចុងខែធ្នូ ។

ពូជស្រូវមិនប្រកាន់រដូវ គឺជាប្រភេទពូជស្រូវដែលចេញផ្កា ឬទុំក្នុងរយៈពេលកំណត់ មួយច្បាស់លាស់ បន្ទាប់ពីដុះពន្លកមក ដោយមិនអាស្រ័យទៅនឹងរយៈពេលថ្ងៃ និងយប់ទេ ។ គេបែងចែកពូជស្រូវមិនប្រកាន់រដូវនេះ ទៅតាមរយៈពេលពីដុះពន្លក រហូតដល់ទុំ ឬហៅថាអាយុកាល ។ យោងតាមអាយុកាលនេះ ស្រូវមិនប្រកាន់រដូវត្រូវបានបែងចែកជា ៣ ក្រុម ។ ក្រុមពូជស្រូវស្រាលមិនប្រកាន់រដូវ គឺសំដៅលើពូជស្រូវមិនប្រកាន់រដូវណា ដែលមានអាយុកាលមិនលើសពី ១២០ ថ្ងៃ ។ ក្រុមពូជស្រូវ

កណ្តាលមិនប្រកាន់រដូវ គឺសំដៅលើពូជស្រូវមិនប្រកាន់រដូវណា ដែលមានអាយុកាលចាប់ពី ១២០ ទៅ ១៥០ ថ្ងៃ ។ ក្រុមពូជស្រូវធ្ងន់មិនប្រកាន់រដូវ គឺសំដៅលើពូជស្រូវមិនប្រកាន់រដូវណា ដែលមានអាយុកាលលើសពី ១៥០ ថ្ងៃ ។

## ២. ការជ្រើសរើសពូជស្រូវសំរាប់ដាំដុះ

មុននឹងសម្រេចចិត្តជ្រើសរើសពូជស្រូវយកទៅដាំដុះ កសិករគួរគិតទៅលើចំនុចមួយចំនួនដូចខាងក្រោម ៖

- ពូជត្រូវមានគុណភាពល្អ (ជាពិសេសលក្ខណៈសម្បត្តិពេលចម្អិនដូចជាៈពណ៌ រូបរាង រសជាតិ និងក្លិន ទទួលស្គាល់ពីកសិករភាគច្រើន និងទីផ្សារក្នុងស្រុកឲ្យសមទៅនឹងតម្លៃដែលកសិករចង់បាន)
- ទិន្នផលខ្ពស់ និងមានលក្ខណៈបិតថេរនៅរដូវដាំដុះក្រោយៗ
- ធន់ទ្រាំនឹងសត្វល្អិត ជំងឺផ្សេងៗ ហើយធ ន់នឹងបរិយាកាសជុំវិញ ដែលមានការបំរែបំរួល ខ្លាំង (ដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់ជាដើម)
- កំឡុងពេលលូតលាស់ដែលទន្ទឹមទៅនឹងរដូវកាល កុំប្រើពូជណាដែលត្រូវដាំ និងប្រមូលផល ឆាប់ ឬយឺត បើធៀបទៅនឹងវាលស្រែផ្សេងៗទៀត នៅក្នុ ងតំបន់ជុំវិញវា ។ ស្រូវដែលមានរយៈ ពេលមិនសមស្របអាចបណ្តាលឲ្យៈ
    - បង្កើនការខូចខាតដោយសារសត្វ (ដូចជា សត្វស្លាបស៊ីនៅពេលស្រូវទុំ ) ឬ
    - បញ្ហាក្នុងការលូតលាស់នៅពេលដែលមានលក្ខខណ្ឌបរិយាកាសជុំវិញអាក្រក់ (ដូចជាគ្រាប់ទុំ ក្រោយគេអាចមកពីទទួលទឹកមិនបានគ្រប់គ្រាន់)
- សមត្ថភាពគ្រប់គ្រាន់ក្នុងការដាក់គ្រាប់ ដោយមិនទទួលរងឥទ្ធិពលឬម្លប់ពីស្មៅ ឬរុ ក្ខជាតិដទៃ និងមានសមត្ថភាពបែកគុម្ពបានគ្រប់គ្រាន់ដើម្បីទទួលបានទិន្នផលសមស្រប
- ធន់ទៅនឹងការដួលរលំ ។

### ការវាយតម្លៃទៅលើប្រភេទពូជថ្មី

- ដើម្បីធានាថាពូជមានលក្ខណៈសមស្រប យ៉ាងតិចបំផុតត្រូវធ្វើការសាកល្បងលើសពី ៣រដូវ នៅក្នុងស្រែកសិករ ។ ពូជសមស្របផ្តល់ទិន្នផលថេរ ហើយធន់ទៅនឹង សត្វចង្រៃក្នុងតំបន់ ព្រមទាំងសមស្របទៅនឹងលក្ខខណ្ឌ ក្នុងតំបន់ផងដែរ
- វាយតម្លៃពូជថ្មីដោយការប្រើប្រាស់ ការគ្រប់គ្រងស្រូវ ដែលវាស្រដៀងគ្នាទៅនឹងការ អនុវត្តន៍របស់កសិករ ដូចជាបើកសិករប្រើជីតិច ពេលសាកល្បងត្រូវប្រើជីតិចដែរ បើកសិករព្រោះ ពេលសាកល្បងត្រូវធ្វើស្រូវពង្រោះ មិនត្រូវធ្វើទៅលើស្រូវសន្ទូងទេ
- ពិគ្រោះជាមួយកសិករ ដើម្បីធានាថាពូជមានលក្ខណៈសមស្របមុនពេលបញ្ចេញវា
- ធានាឲ្យបានថា គុណភាពគ្រាប់ពូជថ្មីនេះមានការទទួលស្គាល់នៅលើទីផ្សារ និងតម្លៃសមរម្យ

- កសិករអាចកាត់បន្ថយភាពប្រថុយប្រថាន ដោយគ្រាន់តែសាកល្បងធ្វើវានៅក្នុងផ្ទៃកមួយ នៃផ្ទៃដីទាំងអស់របស់គាត់បានហើយ ។

## ការប្រើប្រាស់គ្រាប់ពូជល្អ

- ការប្រើប្រាស់គ្រាប់ពូជល្អ ធ្វើឲ្យយើងចំណាយគ្រាប់ពូជតិច ដំណុះនៅក្នុងស្រែខ្ពស់ (ជាង ៧០ ភាគរយ) កាត់បន្ថយការជួសឡើងវិញ ស្រូវដុះស្មើល្អ និងសន្ទុះលូតលាស់ខ្លាំងពេលចាប់ ផ្តើមដាំដុះ អាចកាត់បន្ថយការដុះលូតលាស់របស់ស្មៅ ហើយបង្កើនភាពធន់ទប់ទល់ទៅនឹងសត្វល្អិត និងជំងឺ ។ កត្តារួមផ្សំទាំងនេះធ្វើឲ្យទិន្នផលស្រូវកើនឡើងពី ៥ ទៅ ២០ ភាគរយ ។
- គ្រាប់ពូជល្អជាភាពសុទ្ធរបស់ពូជ រាល់គ្រាប់ពូជទាំងអស់ ជាគ្រាប់ពូជតែមួយមិនមានលាយឡំជាមួយគ្រាប់ពូជផ្សេងទៀត គ្រាប់ពេញមានរូបរាងប៉ុនៗគ្នា ហើយមានលក្ខណៈដំណុះខ្ពស់ (អត្រាដំណុះខ្ពស់ជាង៨០ ភាគរយ និងសំណាបលូតលាស់បានល្អ ) ។ គ្រាប់ពូជល្អគួរតែបានបិទ សញ្ញាឲ្យបានត្រឹមត្រូវ និងមិនមានគ្រាប់ស្មៅចូលលាយឡំ គ្រាប់ដែលមានជំងឺ ភ្នាក់ងារបង្កជំងឺ សត្វល្អិត ឬក៏សារធាតុលាយផ្សេងៗ ទៀត ។ គ្រាប់ពូជពេញល្អអាចត្រូវបានជ្រើសរើស តា មរយៈការអុំដោយប្រើខ្យល់ធម្មជាតិ ឬកង្ហារ ដោយអុំយកចេញផងដែរនូវគ្រាប់ស្មៅស្រាលៗ និងសារធាតុលាយ ឡំផ្សេងៗ ។
- ត្រូវជ្រើសរើសគ្រាប់ពេញល្អ និងសម្ងួតឲ្យដល់សំណើម១២ ទៅ១៤ ភាគរយ ។ ទុកដាក់ក្នុងធុងបិទជិតរហូតដល់រដូវដាំដុះ (គ្រាប់ពូជនៅតែមានគុណភាពល្អក្នុងរយៈពេល១ឆ្នាំ បើយើងទុកដាក់បានសមស្រប ) ។ គ្រាប់ពូជ ដែលទុកដាក់នៅក្នុងធុងបិទមិន ជិត ធ្វើឲ្យគ្រាប់ពូជអាចស្រូបសំណើមពីខាងក្រៅ ជាហេតុបណ្តាល ឲ្យគ្រាប់ពូជបាត់បង់ គុណភាពមុនពេល កំណត់ (ឆាប់ខូច) ។

## ការធ្វើសាកល្បងដំណុះគ្រាប់ដើម្បីធានាពីគុណភាពគ្រាប់ពូជ

- ជ្រើសរើសសំណាកតិចតួចមួយចំនួនដោយចៃដន្យពីគ្រាប់ដែលនឹងត្រូវយកទៅដាំដុះ ។ ច្របល់សំណាកទាំងអស់នេះបញ្ចូលគ្នា បន្ទាប់មកត្រូវជ្រើ សរើសចំនួន ២០០គ្រាប់ រួចត្រាំ គ្រាប់ទាំងនេះក្នុងទឹករយៈពេល២៤ម៉ោង។
- រៀបចំគ្រាប់ដែលបានត្រាំនោះចំនួន១០០គ្រាប់ នៅក្នុងប្រដាប់គំរូដំណុះគ្រាប់ពីលើក្រណាត់ ឬ កន្សែងសើម ។ ដាក់ក្រដាស់នៅពីលើប្រអប់ដែលបិទជិត ឬ គ្របគ្រាប់ទាំងនោះដោយ ក្រណាត់ ឬកន្សែងសើមផ្សេងទៀត រួចមូរុំវា ហើយដាក់សំណាកនេះទៅក្នុងថង់ប្លាស្ទិក ។
- រក្សាក្រដាស់ឲ្យនៅសើមរហូត ប៉ុន្តែមិនឲ្យសើមពេកទេ (បើសើមពេកគ្រាប់នឹងរលួយ)
- ត្រូវរាប់គ្រាប់ពូជដែលដុះរៀងរាល់៣ថ្ងៃ និង ៥ថ្ងៃក្រោយដំណុះ និងកត់ត្រាភាគរយដំណុះ ទាំងនោះ។ ចំពោះគ្រាប់ពូជល្អគួតែមានដំណុះទាបបំផុត ៨០ភាគរយ ។

## ការសាកល្បងដំណុះជាក់ស្តែងក្នុងមន្ទីរពិសោធន៍

ការសាកល្បងដំណុះ គឺត្រូវពិនិត្យដំណុះគ្រាប់ នៅលើដីស្រែផងដែរ ដោយធ្វើលើសំណាក ចំនួន ២ ដែលក្នុងមួយសំណាកៗមានចំនួន ១០០គ្រាប់ដាក់នៅក្នុងថាសដែលចាក់ដីស្រែបំពេញ ។ គ្របដី ពីលើគ្រាប់ពូជ (ប្រហែល ៥មីលីម៉ែត្រ) រក្សាភាពសើម និងរាប់ដំណុះគ្រាប់ក្រោយរយៈពេល ៧ថ្ងៃ ។ ចំពោះគ្រាប់ពូជល្អ គួរតែមានដំណុះទាបបំផុតត្រឹម ៧០ភាគរយ ។ ចូរចាំថាជាធម្មតាគ្រាប់ ពូជដែលធំជាងដុះបានល្អជាងគ្រាប់ពូជតូចជាង។

## ការរៀបចំគ្រាប់ពូជសម្រាប់សាបព្រោះ

ត្រាំគ្រាប់ពូជក្នុងទឹករយៈពេល១២ ទៅ២៤ម៉ោង មុនយកទៅសាបព្រោះក្នុងវាលស្រែ ។ ប្រសិនបើ យើងពន្យាពេលសាបព្រោះ គ្រាប់ពូជដែលបានត្រាំនោះត្រូវធ្វើការសម្ង តនៅក្នុងម្លប់ ហើយទុកដាក់រហូត ដល់ពេលយើងត្រូវដាំដុះនៅរដូវក្រោយទៀត ។ នៅក្នុងប្រទេសមួយចំនួន វិធីសាស្ត្រ សំអាតគ្រាប់មួយចំនួនទៀត ត្រូវបានគេប្រើម្តងម្កាលដែរ ដើម្បីជួយការពារគ្រាប់ពីជំងឺ និង បង្កើនកម្រិតនីត្រូសែនផងដែរ ។

## តើកសិករផលិតគ្រាប់ពូជល្អដោយខ្លួនឯងបានដោយរបៀបណា?

- ជ្រើសរើសដីស្រែដែលមានជីជាតិល្អ
- ប្រើគ្រាប់ពូជស្អាត ហើយមានគុណភាពល្អ
- ភ្ជួររាស់ ធ្វើឲ្យដីស្រែមានភក់ និងរាបស្មើល្អ ងាយស្រួលក្នុងការពិនិត្យស្មៅ និងការងារគ្រប់គ្រងទឹក
- ប្រសិនបើស្ទូង នោះអាយុកាលសំណាបដែលមានសុខភាពល្អសមស្របគឺពី១៥ ទៅ២០ថ្ងៃ ដីស្រែ ស្អាត គ្មានដុះស្មៅ ដាំ២ដើមក្នុង១គុម្ព ដោយមានចន្លោះគុម្ព២២,៥សង់ទីម៉ែត្រ គុណ នឹង ២២,៥ សង់ទីម៉ែត្រ
- ផ្តល់ជីជាតិ (អិន ប៉េ កា )ឲ្យមានតុល្យភាពដូចដែលវាត្រូការ
- មិនឲ្យមានស្មៅដុះនៅក្នុងស្រែ សត្វល្អិត និងជំងឺផ្សេងៗ
- នៅពេលស្រូវដើម និងចេញកួរអស់ ត្រូវកាត់ពូជលាយចេញ (ស្រូវណាដែលមានកម្ពស់ រូបរាង ពណ៌ និងពេលចេញកួរខុសពីគេ(មិនធម្មតា) ដើមអន់ ដើមដែលបានបំផ្លាញដោយ សត្វល្អិត និងជំ ងឺ ផ្សេងៗ និងដើមដែលមានចង្កោមកួរប្រែពណ៌ត្រូវកាត់ចោល ។
- ប្រមូលផលនៅពេលដែលវាមានកម្រិតទុំពេញលេញ (ពេលដែលគ្រាប់ស្រូវទុំពី ៨០ទៅ៨៥ ភាគរយ ឡើងពណ៌លឿង )
- បោក សំអាត សម្ងួត (ដល់សំណើម ១២ទៅ ១៤ភាគរយ) ញែក និងបិទផ្លាកសញ្ញាគ្រាប់ ដែល បាន ប្រមូលផលរួច។
- ទុកដាក់គ្រាប់ពូជ ដែលបានបិទផ្លាកសញ្ញារួចក្នុងធុងស្អាត បិទជិត នៅក្នុងបន្ទប់ត្រជាក់ ស្ងួតស្អាត

# បច្ចេកទេសដាំដុះដំណាំស្រូវ

## ១. ការរៀបចំដី



ការភ្ជួរដោយត្រាក់ទ័រ + នង្គ័លថាស ៧

ការរៀបចំដី គឺជាការអនុវត្តន៍រួមគ្នានូវការភ្ជួរ -រាស់ដី ដើម្បីធ្វើឱ្យដីមានស្ថានភាពល្អប្រសើរបំផុត សម្រាប់ដំណុះគ្រាប់ពូជ និងការលូតលាស់របស់ដំណាំ។ ដើម្បីទទួលបានលក្ខខណ្ឌនេះ គេត្រូវតែភ្ជួររាស់ដីក្នុងជម្រៅមួយ ដែលធ្វើឱ្យដំណាំអាចមានលទ្ធភាពចាក់ឫសបានល្អដើម្បីទ្រទ្រង់ដើម និងស្រូបយកសំណើមព្រមទាំងសារធាតុចិញ្ចឹមទាំងឡាយ ។ គេត្រូវតែធ្វើការបំបែក និងច្របល់ដីឱ្យបានល្អ ដើម្បីបន្ថយ ឬបង្អន់នូវការប្រជែងពីស្មៅចង្រៃ។ ផ្ទៃដីខាងលើគួរតែធ្វើ ឱ្យបានរាបស្មើល្អ ដើម្បីធ្វើឱ្យការគ្រប់គ្រងទឹក និងការកំចាត់ស្មៅចង្រៃ ដែលទើបដុះថ្មីមានប្រសិទ្ធិភាពខ្ពស់ ។ គួររៀបចំប្រព័ន្ធសម្រាប់បង្ហូរទឹកលើសពីសេចក្តីត្រូវការ ចេញឱ្យបានរហ័ស ។

*គោលបំណងនៃការរៀបចំដី:* គោលបំណងផ្សេងៗនៃការរៀបចំដីគឺដើម្បី ៖

១.បំបែកដុំដី

២.យកចេញ ឬបង្កប់ ឬកាត់ចិញ្ច្រាំសំណល់នៃដំណាំ

៣.បង្កើននូវលទ្ធភាពរបស់ដីសម្រាប់ទាំងការទទួលសំណើម ទាំងការធ្វើឱ្យស្ងួត

៤.កម្ចាត់ស្មៅចង្រៃ

៥.ច្របល់ និងបង្កប់ជីជាតិ ឬជីទ្រាប់បាតទៅក្នុងដី

៦.កម្ចាត់សត្វល្អិតចង្រៃ ពង កូនញាស់ និងសំបុករបស់វា

៧.បន្ថយការហូរច្រោះដីដែលបង្កឡើងដោយខ្យល់ និងទឹក។

ការងាររៀបចំដីជារួមគឺជាការភ្ជួររាស់ដីលើកទីមួយ (ភ្ជួរដាស់ដី) ឬលើកទីពីរ (ភ្ជួរប្រែ) ។ ការភ្ជួររាស់ដីលើកទីមួយ គឺជាការងារធ្វើដីដំបូង បន្ទាប់ពីការប្រមូលផលនៃដំណាំដែលបានដាំពីមុន ។ វាតែងត្រូវបានគេអនុវត្តឡើងជាធម្មតា នៅក្រោយពេលច្រូតកាត់ភ្លាមៗនៅដើមរដូវវស្សា គឺនៅពេលដែលដីមានសភាពសើមសមស្របឱ្យគេអាចភ្ជួរវាកើត និងមិនមានការផុងជាប់ជើងគោក្របី គោយន្ត ឬត្រាក់ទ័រ។ ប្រសិនបើមានថាមពលគ្រប់គ្រាន់ គេអាចភ្ជួរដីប្រភេទខ្លះបាន ទោះបីជានៅពេលដែលដីនោះមានសភាពស្ងួតខ្លាំងក៏ ដោយ។

ឧបករណ៍ធ្វើដីដែលគេប្រើច្រើនជាងគេបំផុតជាមួយគោក្របី គឺនង្គ័លភ្លៀង។ ស ម្រាប់ប្រភេទដីឥដ្ឋជារឿយៗ គេតែងតែធ្វើឱ្យដីស្រែស្រូបទឹកបានឆ្អែតសិន ទើបការងារភ្ជួររាស់អាចប្រព្រឹត្តទៅបាន។ សម្រាប់ប្រភេទដីដែលមានទំរង់ស្រាលជាងដីឥដ្ឋដូចជា ដីល្បាយខ្សាច់ ឬដីខ្សាច់ ការងារភ្ជួររាស់អាចប្រព្រឹត្តទៅបាន នៅពេលដែលកម្រិតសើមរបស់ ដីស្ថិតក្នុងក ម្រិតទាប ឬមិនទាន់ឆ្អែតទឹកនៅឡើយ។ ជាមួយគោយន្ត គេអាចប្រើប្រាស់

បានទាំងនង្គ័លភ្លៀង និងនង្គ័លថាស។ គេនិយមប្រើនង្គ័លថាសជាងនង្គ័លភ្លៀង ដោយសារគេអាចចំណាយកម្លាំងសម្រាប់អូសទាញនង្គ័លថាសតិចជាងនង្គ័លភ្លៀង ហើយនង្គ័លថាស អាចធន់ទ្រាំជាមួយឧបសគ្គផ្សេងៗ (ជង្គត់ឈើ ដុំថ្ម ... ) បានល្អជាងនង្គ័លភ្លៀង។ ជាមួយត្រាក់ទ័រ គេចូលចិត្តប្រើនង្គ័លថាស៣ នង្គ័លថាស៧ និងរនាស់ថាសជាងគេបំផុត។ យកល្អគេគួរប្រើប្រាស់នង្គ័លស្លាប ប៉ុន្តែគេពុំអាចមានលទ្ធភាពរកបាន ដើម្បីយកទៅប្រើប្រាស់ឱ្យបានទូលំទូលាយឡើយ។ គេក៏ពុំសូវចូលចិត្តប្រើនង្គ័លភ្លៀង ជាមួយត្រាក់ទ័រផង ដែរ ។

តាមរយៈការសិក្សាកន្លងមក របស់កម្មវិធីវិស្វកម្មកសិកម្ម នៃកម្មវិធីកម្ពុជា-អ៊ីរី-អូស្ត្រាលី និងក្រោយមកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាអាចកំណត់បានថា:

- ការភ្ជួររាស់ដី ១ ហិកតា ជាទូទៅត្រូវចំណាយពេលជាមធ្យម ៖
  - ពី ៥ទៅ៨នឹម-ថ្ងៃ ដោយប្រើប្រាស់សត្វពាហនៈ ( ៥ម៉ោងក្នុង១ថ្ងៃ)
  - ពី ៣ ទៅ ៥ ម៉ោងដោយប្រើប្រាស់គោយន្ត ជាមួយពលកម្មមនុស្ស ២នាក់
  - ពី ១ ទៅ ២ ម៉ោង ដោយប្រើប្រាស់ត្រាក់ទ័រ ១ គ្រឿង ភ្ជាប់ជាមួយនង្គ័លថាស ៦ ឬ ៧។
- ជម្រៅភ្ជួរ-រាស់ប្រែប្រួលទៅតាមប្រភេទដី និងអាស្រ័យទៅនឹងកម្រាស់នៃដីស្រទាប់លើ ។

តារាងខាងក្រោមបង្ហាញពីជម្រៅភ្ជួរ-រាស់ អាស្រ័យទៅតាមប្រភេទដីនីមួយៗ:

| ប្រភេទដី | ព្រៃខ្មែរ | ប្រទះឡាង | បាកាន | ទូលសំរោង | គោកត្រប់ | កំពង់សៀម | ក្បាលពោធិ |
|---|---|---|---|---|---|---|---|
| ជម្រៅភ្ជួរ-រាស់ គិតជាសង់ទីម៉ែត្រ | 8 - 10 | 8 - 12 | 15 - 20 | 20 - 25 | 20 - 25 | 10 - 20 | 15 - 25 |

ប្រសិនបើការភ្ជួររាស់ដីត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ៖

- អាចរក្សាភាពរាបស្មើរបស់ដីស្រែបានយូរ ហើយការពង្រាបជាថ្មីអាចនឹងត្រូវអនុវត្ត ៨ ទៅ ១០ ឆ្នាំក្រោយ
- ងាយស្រួលក្នុងការគ្រប់គ្រងទឹក និងស្មៅចង្រៃ
- មានលទ្ធភាពផ្លាស់ប្តូរពីការដាំដុះដោយវិធីដកស្ទូង មកវិធីព្រោះ ឬដាំគ្រាប់ផ្ទាល់ដោយម៉ាស៊ីន ដែលធ្វើឲ្យថយចុះពលកម្មពីប្រមាណ ៣៥ មកត្រឹម១ទៅ២នាក់ក្នុង១ថ្ងៃ ក្នុងស្រែ១ហិកតា ។





## ២. ការសាបព្រោះ

នៅបណ្ដាខេត្តភាគខាងជើងនៃប្រទេស ដែលជាតំបន់ពឹងផ្អែកលើទឹកភ្លៀង មានប្រមាណជាង ៨០ភាគរយ ដែលធ្វើស្រូវពង្រោះនេះ។ការព្រោះត្រូវបានអនុវត្តយ៉ាងទូលំទូលាយតាមតំបន់ដែលមានប្រព័ន្ធស្រោចស្រពផងដែរ។ ដោយផ្អែកលើប្រព័ន្ធក្សេត្របរិស្ថានតាមតំបន់ កសិករបានប្រើប្រាស់នូវបច្ចេកទេសខុសៗ គ្នាដើម្បីព្រោះស្រូវ។



តាមរយៈការសិក្សាកន្លងមករបស់ការិយាល័យវិស្វកម្មកសិកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានរកឃើញថា   អត្រាដំណុះគ្រាប់ស្រូវនៅក្នុងស្រែទៅតាមសភាពដី និងសភាពគ្រាប់ពូជផ្សេងៗគ្នាដូចតារាងខាងក្រោម

| វិធីសាស្ត្រដាំដុះ | ថ្នាលស្ងួតពូជស្រូវស្ងួត | ថ្នាលស្ងួតពូជស្រូវសើម | ថ្នាលសើមពូជស្រូវសើម | ថ្នាលសើមពូជស្រូវស្ងួត | ថ្នាលស្ងួតពូជស្រូវស្ងួតរាស់លុប | ថ្នាលស្ងួតពូជស្រូវសើមរាស់លុប | ក្នុងទីពិសោធន៍ |
|---|---|---|---|---|---|---|---|
| ដំណុះគ្រាប់ (%) | ៤៣.៣ | ៥២.៣ | ៦១.៣ | ៤៨.៦ | ៤៤ | ៥៣ | ៨៦.៦ |

- **ថ្នាលស្ងួតពូជស្រូវស្ងួត:** ទទួលបានអត្រាដំណុះគ្រាប់ ៤៣ .៣ ភាគរយ ប៉ុណ្ណោះ ដោយហេតុថាគ្រាប់ស្រូវមានលក្ខណៈដំណុះខ្សោយ ហើយរួមផ្សំនឹងថ្នាលដែលស្ងួតផងនោះ ធ្វើឱ្យដីពុំមាន លទ្ធភាពគ្រប់គ្រាន់ក្នុងការបញ្ជូនទឹកទៅឱ្យគ្រាប់ពូជ ហើយការប៉ះផ្ទាល់រវាងដី និងគ្រាប់ពូជទៀត សោតក៏មិនមានលក្ខណៈប្រសើរ ព្រមជាមួយនឹងការបំផ្លាញពីសំណាក់សត្វចង្រៃដែលស៊ីគ្រាប់ ពូជផង ។
- **ថ្នាលស្ងួតពូជស្រូវសើម:** ទទួលបានអាត្រាដំណុះ ៥២.៣ភាគរយ ដោយសារគ្រាប់ពូជត្រូវយក ទៅត្រាំ និងផ្អាប់ទុករហូតដុះពន្លកទើបយកទៅព្រោះ ដែលធ្វើឱ្យវាមានលទ្ធភាពដុះលូតលាស់បន្ត ដោយខ្លួនឯងបានប្រសើរជាងគ្រាប់ពូជស្ងួត។
- **ថ្នាលសើមពូជស្រូវសើម:** មានអាត្រាដំណុះ ៦១ .៣ភាគរយ ដោយសារតែគ្រាប់ពូជត្រូវបានត្រាំ និងផ្អាប់២៤ម៉ោង ដូចគ្នាមុននឹងយកទៅព្រោះ ដែលលក្ខណៈបែបនេះធ្វើឱ្យគ្រាប់ពូជអាចធ្វើការលូតលាស់កាន់តែប្រសើរនៅលើដី ដែលមានសភាពសើមស្រាប់ ហើយនោះ។
- **ថ្នាលសើមពូជស្រូវស្ងួត:** មានអត្រាដំណុះគ្រាប់ ៤៨.៦ភាគរយ ហេតុការណ៍នេះកើតឡើងដោយសារលក្ខណៈនៃគ្រាប់ពូជស្ងួត ដែលមានអត្រាដំណុះគ្រាប់ខ្សោយ តែដោយសារដីសើម ធ្វើឱ្យវាមានការប៉ះផ្ទាល់រវាងដីនិងគ្រាប់ពូជមានលក្ខណៈល្អមួយកម្រិតដែរ។
- **ថ្នាលស្ងួតពូជស្រូវស្ងួតរាស់លុប:** ទទួលបានអត្រាដំណុះ ៤៤ភាគរយ ដោយការរាស់លុបនេះ អាចការពារការបំផ្លាញពីសំណាក់សត្វស្លាប ហើយធ្វើឱ្យការប៉ះផ្ទាល់រវាងគ្រាប់ពូជនឹងដីមានលក្ខណៈប្រសើរជាងការមិនលុបផងដែរ។

- **ថ្នាលស្ងួតពូជស្រូវសើមរាស់លុប:** ទទួលបានអត្រាដំណុះគ្រាប់ ៥៣ភាគរយ ដោយសារគ្រាប់សើមដុះបានល្អ រួមផ្សំនឹងការរាស់លុបដែលធ្វើឲ្យការប៉ះផ្ទាល់រវាង ដីនឹងគ្រាប់ពូជកាន់តែប្រសើរ ជាពិសេសអាចការពារការបំផ្លាញពីសត្វចង្រៃទៀតផង។



## *លក្ខណៈសេដ្ឋកិច្ច*

នៅប្រទេសកម្ពុជាយើងមានខេត្តមួយចំនួនប៉ែកខាងលិច និយមចូលចិត្តដាំដុះនូវពូជស្ងួតលើថ្នាលស្ងួត។ ដូចនេះ បើសិនជាយើងធ្វើការប្រៀបធៀបរវាងការប្រើប្រាស់ពូជស្ងួតលើដីស្ងួត ជាមួយនឹងវិធីប្រើប្រាស់ពូជសើមលើដីសើមវិញយើងឃើញថា មានការខុសគ្នាខ្លាំង លើភាគរយនៃអត្រាដំណុះគ្រាប់ដែលមានគម្លាតពីគ្នា ១៧ភាគរយ។

ការិយាល័យវិស្វកម្មកសិកម្ម បានរកឃើញថា ៖

- វិធីសាស្ត្រដាំដុះស្រូវដោយព្រោះ ដែលប្រើប្រាស់គ្រាប់ពូជសើមលើថ្នាលសើម ទទួលបាននូវអាត្រាដំណុះខ្ពស់ជាងគេ
- ចំពោះថ្នាលស្ងួតគ្រាប់ពូជគួរតែយកទៅត្រាំ និងផ្អាប់រយៈពេលពីរថ្ងៃជាមុន ដើម្បីឱ្យវាដុះពន្លក ឫសជាមុន រួចទើបយកទៅព្រោះលើថ្នាលស្ងួត បើអាចរាស់ដីលុបកាន់តែប្រសើរ។ ការធ្វើរបៀប នេះគ្រាប់ពូជប៉ះទៅនឹងដីបានល្អធ្វើឱ្យអត្រាដំណុះក្នុងស្រែក៏កាន់តែខ្ពស់ដែរ (ថ្នាលស្ងួតទីនេះមានន័យថា ក្រោយពេលសាបព្រោះគ្រាប់ពូជហើយថ្នាលនឹងជ្រើមក្នុងពេលបន្ទាប់មក)។
- បើគ្រាប់ស្ងួត គួរដាំលើថ្នាលសើម ព្រោះវាទទួលបានផលជាងដាំលើថ្នាលស្ងួត។ ចំណែកអាត្រាដំណុះរបស់ពូជស្ងួត ទោះជាយ៉ាងណាក៏តិចជាងពូជដែលបានត្រាំដែរ។
  មិនគួរព្រោះគ្រាប់ពូជស្ងួតលើថ្នាលស្ងួតទេ ព្រោះវាមានការដុះលូតលាស់ខ្សោយជាងគេ។

## ២.១ ការព្រោះគ្រាប់នៅលើដីស្ងួត

នៅក្នុងតំបន់ដែលមានទឹកជ្រៅនិងភ្លៀងធ្លាក់ខ្លាំង គេច្រើនព្រោះគ្រាប់ពូជស្ងួតទៅលើដី ហើយក្រោយមកភ្ជួររាស់លុបវាអំឡុងពេលដីនៅស្ងួតនៅឡើយ ។ នៅក្នុងករណីមួយចំនួន (ដូចជានៅតំបន់ស្រូវឡើងទឹក) បន្ទាប់ពីព្រោះរួចគេមិនលុបគ្រាប់ពូជទេ ។

**គោលបំណងនៃការព្រោះគ្រាប់នៅលើដីស្ងួត**

- ងាយស្រួល និងធ្វើឱ្យគ្រាប់ដុះចំពេលល្អ
- កាត់បន្ថយតម្លៃពលកម្មក្នុងការធ្វើស្រែ
- ជួបប្រទះនូវបញ្ហាមិនដុះតិចតួច បន្ទាប់មកត្រូវព្រោះវាបន្ថែមទៀតនៅពេលដីសើម

**ការព្រោះស្រូវលើដីស្ងួត**

ភ្ជួររាស់រៀបចំដីឲ្យបានស្មើល្អ និងមិនមានស្មៅ ។ ដុំដីនៅក្នុងស្រែគួរតែមានទំហំតូចៗប៉ុន និងគ្រាប់ ពូជ ជាទូទៅដីស្រែមិនរាបស្មើបណ្តាលឲ្យគ្រាប់ដុះមិនល្អ ឬមិនដុះនៅកន្លែងទំនាប ហើយដុះស្មៅ និងស្រូវ មានបញ្ហានៅតំបន់ខ្ពស់។

**នៅក្នុងប្រព័ន្ធដែលមានភ្លៀងធ្លាក់ខ្លាំង**

- ជីកប្រឡាយទឹកតូចៗកាត់ស្រែដើម្បីជួយបង្ហូរទឹកចេញពីស្រែ និងការពារមិនឲ្យខ្យងបំផ្លាញស្រូវ និង ការពារមិនឲ្យមានបញ្ហាទៅលើស្រូវដែលមានទឹកដក់ ។
- ប្រើប្រាស់គ្រាប់ពូជគ្រប់គ្រាន់ដើម្បីទទួលបានដើមពី ១០០-១៥០ដើមក្នុង១ម៉ែត្រការេ ។ ជាទូទៅត្រូវ ប្រើគ្រាប់ពូជពី ១២០-១៥០ គីឡូក្រាម ក្នុង ១ ហិចតា ។ ជាធម្មតាកសិករប្រើបរិមាណ ពូជអស់ច្រើន ជាងនេះ (រហូតដល់ ១៥០ -២០០ គីឡូក្រាម ក្នុង ១ ហិ កតា ) ដោយសារការរៀបចំដីមិន បានល្អ គ្រាប់ពូជ អន់ និងគ្រាប់បាត់បង់ដោយសារសត្វស្លាប និងកណ្តុរបំផ្លាញ ។
- បាចគ្រាប់ពូជឲ្យបានស្មើល្អ ចំពោះការបាចដោយដៃត្រូវធ្វើកំណត់សំគាល់ទៅលើទទឹងដីស្រែ ៥ ម៉ែត្រសិន (ជាចម្ងាយមួយសមស្រប ដែលគ្រាប់ពូជអាចត្រូវបានពង្រាយដោយដៃបានស្មើល្អ) ដោយ បែងចែកគ្រាប់នៅក្នុងឡូត៍មួយៗឱ្យស្មើគ្នា ដើម្បីធ្វើឲ្យអ្នកសាបអាចសាបទៅមុខ និងបែរក្រោយ បានមុនពេលចូលទៅក្នុងឡូត៍មួយផ្សេងទៀត (ដូចជាសំគាល់នៅលើទទឹងស្រែប្រវែង ១០ ម៉ែត្រ) ។
- ព្រោះស្រូវរួចភ្ជួរលុបវាស្តើងៗ ត្រូវប្រុងប្រយ័ត្នកុំលុបគ្រាប់ពូជជ្រៅពេកនៅក្នុងដីតដ្ឋ(ជ្រៅបំផុត ពី ១-២សង្ទីម៉ែត្រ) ឬនៅកន្លែងដែលជាប់ទៅនឹងស្រទាប់ដីលើមានបញ្ហា ។
- បន្ទាប់ពីមានភ្លៀងធ្លាក់និងស្រូវបានដុះ ត្រូវពិនិត្យស្មៅឱ្យបានម៉ត់ចត់ ។
- ជី: ដោយសារតែភ្លៀងធ្លាក់មិនទៀតទាត់ ការដាក់ជី (ពិសេសជីអាសូត) អាចពន្យារពេលរហូត ដល់ស្រូវចាប់ផ្តើមដុះចេញ ចំពេលដែលមានទឹកនៅក្នុងស្រែ ។

**កត្តាកំណត់ផ្សេងៗ**

- ត្រូវការ ការរៀបចំដី ការគ្រប់គ្រងទឹកឲ្យបានល្អ ដើម្បីឲ្យស្រូវដុះស្មើល្អ
- ត្រូវពិនិត្យស្មៅឲ្យបានម៉ត់ចត់ ដើម្បីទទួលបានទិន្នផលស្រូវខ្ពស់
- បញ្ហាដោយសារ កណ្តុរ សត្វស្លាប សត្វកំពឹងដូង ចង្រិត និងស្រមោច ។
- ភ្លៀងធ្លាក់ខ្លាំងចំពេលដែលគ្រាប់ចាប់ផ្តើមដុះ អាចធ្វើឲ្យគ្រាប់លែងដុះ (ពិសេសចំពោះ ដីតដ្ឋ) និង ប្រសិនបើមានទឹកដក់លេចគ្រាប់ដែលដុះមិនទាន់ផុតពីដី ។
- បើប្រៀបធៀបទៅនឹងស្រូវដែលស្ទូង វាមានអាយុនៅក្នុងស្រែវែងជាងប្រហែល ១៥ថ្ងៃ
- នៅតំបន់ដីធូរ ត្រូវប្រើទឹកច្រើនពីព្រោះមានការបាត់បង់ដោយសារការជ្រាបទៅក្នុងដី ។

## ២.២ ការព្រោះស្រូវនៅលើដីសើម

ជាទូទៅការព្រោះនៅលើដីសើម គ្រាប់ពូជត្រូវធ្វើដំណុះជាមុនសិនដើម្បីព្រោះទៅក្នុងថ្នា លដែលបាន ភ្ជួររាស់ និងបញ្ចូលទឹកថ្មីៗ ឬនៅក្នុងស្រែដែលបានបញ្ចូលទឹកជាមុន ។ តាមធម្មតា ការព្រោះ គ្រាប់នៅលើដី សើមភាគច្រើនប្រើនៅក្នុងតំបន់ដែលអាចបញ្ចូលទឹកបាន ។

**គោលបំណងនៃការព្រោះគ្រាប់នៅលើដីសើម**

- ងាយស្រួល និងធ្វើឲ្យគ្រាប់ដុះទាន់ពេលវេលា
- កាត់បន្ថយតម្លៃពលកម្មនៅក្នុងការធ្វើស្រែ
- អាចកាត់បន្ថយការប្រើប្រាស់ទឹកបាន

**ការព្រោះស្រូវនៅលើដីសើម**

1. ភ្ជួររាស់ រៀបចំដីស្រែឲ្យបានរាបស្មើល្អ និងគ្មានស្មៅ
2. ព្រោះគ្រាប់ពូជនៅក្នុងស្រែ ក្នុងចន្លោះពេលពី២ទៅ៥ថ្ងៃ បន្ទាប់ពីភ្ជួររាស់រួច ។ នៅក្នុងចន្លោះពេល នេះ ដីស្រែរឹងល្មម ឬជិតរឹងសមស្របសម្រាប់ការព្រោះគ្រាប់ពូជ ចំណែកស្មៅក៏មិនទាន់មានដុះដែរ ប្រសិនបើគ្រាប់ពូជត្រូវលិចក្នុងជម្រៅជ្រៅជាង១សង់ទីម៉ែត្រ ជាទូទៅវាមានបញ្ហានៅពេលដុះពន្លក
3. នៅក្នុងស្រែដែលមានប្រព័ន្ធបង្ហូរទឹក បន្ទាប់ពីភ្ជួររាស់រួចបានរយៈពេលពី ២ទៅ៣ថ្ងៃ គេជីក ប្រឡាយតូចៗកាត់តាមស្រែដើម្បីបង្ហូរទឹកចេញពីស្រែ ហើយជៀសវាងខ្យងបំផ្លាញ និងបញ្ហាទៅ លើការដុះពន្លក របស់ស្រូវនៅក្នុងតំបន់ដែលមានទឹកដក់
4. ដំណុះគ្រាប់ជាមុន ត្រាំទឹករយៈពេល ២៤ម៉ោង រួចបង្ហូរទឹកចេញ និងផ្អាប់រយៈពេល ២៤ម៉ោងទៀត។ នៅក្នុងចន្លោះពេលនេះ ឫសនឹងដុះចេញប្រហែល ២ទៅ៣មីលីម៉ែត្រ ។ ប្រសិនបើយើងផ្អាប់ទុក គ្រាប់ឲ្យយូរជាងនេះ ឫសវាអាចប្រទាក់ប្រទាញគ្នា ធ្វើឲ្យពិបាកញែកវាចេញពីគ្នា ហើយងាយឲ្យខូច គ្រាប់ពូជនៅពេលយើងព្រោះ
5. ប្រើប្រាស់គ្រាប់គ្រប់គ្រាន់: សមស្របសម្រាប់ព្រោះដើម្បីទទួលសំណាប ពី ១០០ទៅ១៥០ដើមក្នុង១ម៉ែត្រការ៉េ ។ ជាទូទៅប្រើពូជ ៨០គីឡូក្រាមក្នុង១ហិកតា ។ ប្រសិនបើគ្រាប់ពូជ មិនបានធ្វើដំណុះវាជាមុនសិនទេ យើងត្រូវបន្ថែមគ្រាប់ពូជពីលើនេះពី ១០ទៅ ២០ភាគរយទៀត ។ ជាញឹក ញាប់កសិករប្រើពូជអស់ច្រើនជាងនេះ (រហូតដល់ ១៥០ ទៅ២០០គីឡូក្រាមក្នុង១ហិកតា) ពីព្រោះតែការរៀបចំដីមិនបានល្អ គ្រាប់ពូជអន់ និងការបាត់បង់គ្រាប់ដោយសារសត្វស្លាប និងកណ្តុរបំផ្លាញ ។
6. ប្រសិនបើមានទឹកបុិចៗនៅក្នុងស្រែបន្ទាប់ពីការរៀបចំដីលើកចុងក្រោយ យើងត្រូវសម្ងួតស្រែរយៈពេលយ៉ាងតិច២៤ម៉ោងសិន (ជាទូទៅប្រហែល៤៨ម៉ោង)មុនពេលព្រោះស្រូវ ។
7. ព្រោះស្រូវឲ្យបានស្មើល្អ: បាចគ្រាប់ពូជឲ្យបានស្មើល្អ ចំពោះការបាចដោយដៃត្រូវធ្វើកំណត់សំគាល់ទៅលើទទឹងដីស្រែ ៥ម៉ែត្រសិន (ជាចម្ងាយមួយសមស្រប ដែលគ្រាប់ពូជអាចត្រូវបានពង្រាយដោយដៃឲ្យបានស្មើល្អ) ដោយបែងចែកគ្រាប់នៅក្នុងឡូត៍មួយៗឲ្យស្មើគ្នា ដើម្បីធ្វើឲ្យអ្នកសាបអាច សាបទៅមុខ និងបែរក្រោយបានមុនពេលចូលទៅក្នុងឡូត៍មួយផ្សេងទៀត (ដូចជាសំគាលនៅលើ ទទឹងស្រែប្រវែង ១០ម៉ែត្រប្រសិនបើដីស្រែមានទទឹង ២០ម៉ែត្រ នោះយើងត្រូវចែកវាជា៤ផ្នែក ដោយ ១ផ្នែកៗមានទទឹងប្រវែង ៥ម៉ែត្រ ហើយគ្រាប់ពូជត្រូវចែកជាឡូត៍គ្រាប់ពូជ២ចំណែកស្មើគ្នា ។

8. ព្រោះគ្រាប់ពូជទៅក្នុងស្រែដែលមានទឹកកម្ពស់ពី២ទៅ៥សង់ទីម៉ែត្រ ឬទៅក្នុងស្រែដែលបានបង្ហូរទឹក ។ ប្រសិនបើស្រែត្រូវបានបង្ហូរទឹកនោះដីគួរតែធ្វើរាងដូចអក្សរវេ(V )។ នេះបង្ហាញថាដីរឹងល្អ ដែលអាចជួយគ្រាប់កុំឲ្យកប់ក្នុងដីជ្រៅពេក ។

9. អនុញ្ញាតឲ្យទឹកហូរចូលស្រែបន្ទាប់ពីបាន ២ទៅ៣ថ្ងៃ មុនពេលបង្ហូរទឹកខ្លាំងចូលស្រែ ដើម្បីរក្សាភាពសើមរបស់គ្រាប់ និងកាត់បន្ថយការក្រៀមដី (ជាពិសេស នៅក្នុងរដូវប្រាំង) ។

10. ប្រសិនបើបង្ហូរទឹកចេញពីស្រែបន្ទាប់ពីព្រោះរួច ដូច្នេះយើងត្រូវបញ្ចូលទឹកក្នុងស្រែវិញបន្ទាប់ពីស្រូវដុះបានអាយុពី១០ទៅ ១៥ថ្ងៃ។ នៅក្នុងតំបន់ធារាសាស្ត្រមួយចំនួន សំណាបត្រូវបានគេព្រោះ បន្ទាប់ពីវាដុះ ឫសបានប្រវែងចាប់ពី ១០០ទៅ ៣០០មីលីម៉ែត្រ ។

**កត្តាកំណត់ផ្សេងៗ**

- ត្រូវការរៀបចំដី ការគ្រប់គ្រងទឹកឲ្យបានល្អដើម្បីឲ្យស្រូវដុះស្មើល្អ
- ស្មៅជាបញ្ហាចម្បងបំផុតនៅក្នុងរដូវប្រាំង ក៏ដូចជានៅរដូវវស្សាដែរ
- ខ្យង (នៅក្នុងរដូវវស្សា) ហើយសត្វស្លាប និងកណ្ដុរអាចបំផ្លាញយ៉ាងខ្លាំងដែរទៅលើដើមស្រូវ
- ភ្លៀងធ្លាក់ខ្លាំងចំពេលដែលគ្រាប់ចាប់ផ្ដើមដុះអាចធ្វើឲ្យគ្រាប់លែងដុះ (ពិសេសចំពោះដីឥដ្ឋ) និងប្រសិនបើមានដក់ទឹកលេចគ្រាប់ដែលដុះមិនទាន់ផុតពីដី ។
- ដោយធៀបទៅនឹងស្រូវដែលស្ទូងវាមានអាយុនៅក្នុងស្រែវែងជាងប្រហែលពី៥ទៅ១៥ថ្ងៃ ប្រើដី និងទឹកច្រើននៅក្នុងការព្រោះលើដីស្ងួត (ដោយសារតែការជ្រាបចូលទៅក្នុងដី ជាពិសេសចំពោះប្រភេទដីធូរ) ។

## ២.៣ ការជ្រើសរើស ការរៀបចំថ្នាលសំណាប និងការសាប

**ក. ការជ្រើសរើសថ្នាលសំណាប** ទីតាំងថ្នាលសំណាបត្រូវនៅជិតប្រភពទឹក តែបើសិនជាមិនមាន ប្រភពទឹកនៅក្បែរទេ យកល្អគួរជីករណ្ដៅស្តុកទឹកនៅជាប់ថ្នាលសំណាប ដើម្បីស្រោចស្រពនៅ ពេលរាំងស្ងួតខ្លាំង។ មិនត្រូវធ្វើថ្នាលសំណាបនៅក្បែរទីកន្លែងដែលមានភ្លើងភ្លឺនៅពេលយប់ទេ ពីព្រោះពន្លឺភ្លើងទាក់ទាញ សត្វល្អិតចង្រៃដែលអាចបំផ្លាញសំណាប។

**ខ. ការរៀបចំថ្នាលសំណាប** ជាការសំខាន់ ពីព្រោះបើរៀបចំមិនបានល្អទេនោះ សំណាបដុះលូតលាស់មិន បានស្មើល្អ មានស្មៅច្រើន និងជាពិសេសគឺគ្រាប់ស្រូវដុះមួរ ដែលលាយឡំជាមួយសំណាបរបស់ពូជស្រូវដែលសាប។ ដើម្បីកាត់បន្ថយបញ្ហានេះ ដីថ្នាលសំណាបត្រូវភ្ជួរយ៉ាងតិច ឲ្យបាន ៣ ដង ដោយៈ

- លើកទីមួយគឺភ្ជួរដាស់ដី បន្ទាប់មានស្មៅ និងស្រូវដុះមួរបានពី ៥ ទៅ ១០ស.មដោយសារ មានភ្លៀងធ្លាក់ ដំបូង។ មុនពេលភ្ជួរលើកទីមួយនេះ ត្រូវដាក់ជីកំប៉ុស្ត ឬលាមកសត្វឲ្យបាន ស្មើល្អរួចសឹមភ្ជួរលុប។ ធ្វើយ៉ាងនេះ កសិករអាចកាត់បន្ថយស្មៅ និងស្រូវមួរបានមួយចំនួន។
- ភ្ជួរលើកទីពីរ គឺនៅពេលមុនសាបពី ១០ ទៅ ១៥ ថ្ងៃនៅពេលដែលគ្រាប់ស្មៅ និងស្រូវដុះមួរដែល នៅសល់ក្នុងដីថ្នាល និងជីកំប៉ុស្ត ឬលាមកគោ ដុះលូតលាស់។
- ភ្ជួរលើកទីបី គឺនៅពេលមុនសាបមួយថ្ងៃ តែបើសិនជាថ្នាលសំណាបនៅមានដុះស្មៅច្រើន ត្រូវភ្ជួរ មុន

សាបយ៉ាងតិចបំផុតឲ្យបាន ៣ ថ្ងៃ ប្រយោជន៍ឲ្យស្មៅរលួយបានល្អ ។ មុនពេលសាប ត្រូវរាស់ប្រមូលស្មៅ ចេញឲ្យបានស្អាត និងពង្រាបដីឲ្យ បានរាបស្មើល្អ។ ថ្នាលសំណាប ត្រូវឆ្វតជារង ២ ម៉ែត្រមួយ សម្រួល ក្នុងការដើរពិនិត្យថែទាំ ។

**គ. ការសាប** ត្រូវធ្វើឲ្យបានស្មើល្អ។ មុនសាបគ្រាប់ពូជត្រូវត្រាំទឹកក្តៅឧណ្ហៗរយៈពេលពី ២ ទៅ ៣ ម៉ោង ដោយស្រង់យកគ្រាប់អណ្តែតចោល។ គ្រាប់ពូជចំនួន ១ គ.ក្រ ត្រូវសាបលើផ្ទៃថ្នាល ១០ ម៉ែត្រការ៉េ ដូច្នេះបើប្រើគ្រាប់ពូជ ២០ គ.ក្រ សម្រាប់ស្ទូងលើដី ១ ហិកតានោះ ថ្នាលសំណាប ត្រូវមានទំហំយ៉ាងតូចបំផុត ២១០ ម៉ែត្រការ៉េ (រូបភាព ១)។ ត្រូវបែងចែកគ្រាប់ពូជសម្រាប់រង នីមួយៗឲ្យបានស្មើគ្នា និងសាបឲ្យបានស្មើល្អ។

**ឃ. ការថែទាំសំណាប** ត្រូវធ្វើជាប្រចាំ ដោយផ្តោតជាពិសេសទៅលើការថែទាំទឹក ការតាមដាន កត្តាចង្រៃ និងការដកស្មៅតាមចន្លោះចង្អូរ និងជាយថ្នាលសំណាប ។ ជាទូទៅ សត្វល្អិតចង្រៃដែល តែងតែបំផ្លាញសំណាបមាន មមាចត្នោត និងទ្រីប ជាពិសេសនៅពេលថ្នាលសំណាបមានទឹកតិច ឬអត់រយៈពេលយូរ។ ក្នុងករណីដែលមិនមានភ្លៀងធ្លាក់ក្នុងរយៈពេល ១ អាទិត្យទេនោះ ដាច់ខាត ត្រូវទៅពិនិត្យសំណាប រកមើលនូវវត្តមានមមាចត្នោត ឬទ្រីប ឬក៏កត្តាចង្រៃផ្សេងទៀតឲ្យបាន ច្បាស់លាស់។

**ង. អាយុកាលសំណាប** រយៈពេលវគ្គលូតលាស់របស់ពូជស្រូវនីមួយៗ ជាកត្តាសំខាន់សម្រាប់ កំណត់នូវអាយុកាលសមស្របសម្រាប់ស្ទូង ។ អាយុកាលសំណាបអាស្រ័យទៅលើរយៈពេល លូតលាស់របស់ពូជស្រូវនីមួយៗ។ ចំពោះពូជស្រូវស្រាលមិនប្រកាន់រដូវ គឺមិនត្រូវឲ្យលើសពី ២០ ថ្ងៃឡើយ។ សម្រាប់ពូជស្រូវកណ្តាល និងធ្ងន់ប្រកាន់រដូវ គឺពី ២៥ ទៅ ៣០ ថ្ងៃ។ ជាទូទៅការខ្វះ ខាតទឹកសម្រាប់ស្ទូងស្រូវវស្សា តែងតែមានជា ញឹកញាប់ បណ្តាលឲ្យកសិករពន្យាពេលវេលាស្ទូង ធ្វើឲ្យសំណាបស្រូវកណ្តាល និងធ្ងន់ខ្លះមានអាយុរហូត ដល់ ៣ ខែ។ ការពន្យាពេលស្ទូង ដោយទុកឲ្យសំណាបមានអាយុកាលវែង អាចផ្តល់ផលបានល្អ លុះត្រាតែរយៈ ពេលចាប់ពីស្ទូង រហូតដល់កំណកំណើតកួរមិនខ្លីជាង ១ខែ ហើយប្រសិនបើរយៈពេលនេះមានត្រឹមតែ ១ សប្តាហ៍ ចុះវិញនោះ មិនគួរធ្វើការដកស្ទូងឡើយ បើសិនជាមានជម្រើសផ្សេងទៀត ពីព្រោះវានឹងផ្តល់ផលតែបន្តិចបន្តួចប៉ុណ្ណោះ។

**ច. ពេលវេលាសាប ស្ទូង និងព្រោះ** ជាទូទៅ ការខ្វះខាតទឹកសម្រាប់ស្ទូងស្រូវវស្សា តែង តែមាន ជាញឹកញាប់ បណ្តាលឲ្យកសិករពន្យាពេលវេលាស្ទូង ធ្វើឲ្យសំណាបស្រូវកណ្តាលនិងធ្ងន់ខ្លះមាន អាយុរហូត ដល់ ៣ ខែ។ គំនូសបំព្រួញខាងក្រោមបង្ហាញណែនាំនូវពេលវេលាសមស្របសម្រាប់ សាប និងព្រោះ ពូជស្រូវ ទាំង ១០ ពូជ នៅក្នុងលក្ខខណ្ឌធម្មតា និងលក្ខខណ្ឌមានកូនរដូវប្រាំង។




*រូបភាព : ថ្នាលសំណាបសម្រាប់សាបគ្រាប់ពូជស្រូវចំនួន ២០ គ.ក្រ*

ក. ពេលវេលាសម្រាប់ពូជស្រូវស្រាលដាំដុះនៅស្រែលើ: សែនពិដោរ អ៊ីអ៊ែរ៦៦ និងផលសារ




ខ. ពេលវេលាសម្រាប់ពូជស្រូវកណ្ដាលដាំដុះនៅស្រែកណ្ដាល:

ផ្ការំដួល ផ្ការំដេង និងផ្ការមៀត (គំនូសពណ៌ខ្មៅ) ផ្កាច័ន្ទសែនសរ (គំនូសពណ៌ក្រហម)




គ. ពេលវេលាសម្រាប់ពូជស្រូវធ្ងន់ដាំដុះនៅស្រែក្រោម: រាំងជ័យ ខា៤ និងខា៦



**តើត្រូវធ្វើថ្នាលសំណាបខ្នាតតូចយ៉ាងដូចម្តេច ?**

- តម្រូវការគ្រាប់ពូជ: ដើម្បីស្ទូងស្រូវ ១ហិកតា ដោយក្នុង ១គុម្ព ស្ទូង២ដើម ហើយចន្លោះគុម្ពប្រវែង ២០ សង្ទីម៉ែត្រ គុណនឹង ២០ សង្ទីម៉ែត្រ ត្រូវប្រើពូជដែលមានគុណភាពល្អពី ១៨ -២៥ គីឡូក្រាម (ដំណុះគ្រាប់ទាបបំផុត៨០%)។ **ចំណាំ:** ប្រើពូជដែលមានគុណភាពល្អ ធ្វើឲ្យយើងចំណាយគ្រាប់ពូជតិច គ្រាប់ភាគច្រើនដុះស្មើគ្នា សំណាបមានកម្លាំងល្អ ជួស ឡើងវិញតិចតួច មានស្មៅតិចតួច និងទិន្នផលកើនឡើងពី៥-២០% ។
- ការរៀបចំថ្នាលសំណាប: រៀបចំថ្នាលសំណាបដែលមានក្រឡាផ្ទៃ ១០០ ម៉ែត្រការ៉េ សម្រាប់ផ្ទៃដី ស្ទូង ១ហិតកា ត្រូវប្រើដីកំប៉ុស្ត ១០០ គីឡូក្រាម ឬ ជីអាសូត ២០គីឡូក្រាម ក្នុង១ហិកតា ( ដូចជា ជី ១៥-១៥-១៥ ឬ ដេអាប៉េប្រហែល ១,៥ គីឡូក្រាម ក្នុង ១០០ម៉ែត្រការេ ) តែត្រូវភ្ជួររាស់ធ្វើដីឱ្យបានស្មើល្អ។ បន្ទាប់ពីបាន បញ្ចប់ការរៀបចំដី ត្រូវបង្ហូរទឹកចូលស្រែ ១ -២ ថ្ងៃមុនពេលសាប ដើម្បីឱ្យថ្នាលមានភាពដូចភក់ និងមានទឹក តិចៗនៅ ក្នុងថ្នាល ។
- ដំណុះគ្រាប់ជាមុន: រៀបចំគ្រាប់ពូជនៅពេលដែលយើងបានបញ្ចប់ការងាររៀបចំថ្នាលសំណាប ត្រាំគ្រាប់ពូជរយៈពេល ២៤ ម៉ោង (គ្រាប់ពូជមួយចំនួនត្រូវការពេលវេលាយូរជាងនេះ ដើម្បីដុះពន្លក ) ហើយស្រង់ មកផ្អាប់វាទុក ក្នុងរយៈពេល២៤ម៉ោងទៀត ។ នៅក្នុងរយៈពេលនេះ គ្រាប់ចាប់ផ្តើមចេញពន្លក ហើយដុះឫស បានប្រវែងពី ២-៣ មីលីម៉ែត្រ ។
- ការសាប: សាបគ្រាប់ពូជឱ្យបានស្មើដែលល្អនៅក្នុងថ្នាលដែលបានរៀបចំរួចស្រេច (ប្រហែល ១គ្រាប់ក្នុង១ សង្ទីម៉ែត្រការេ ) ។
- ការបញ្ចូលទឹកក្នុងថ្នាលសំណាប: បន្ទាប់ពីសាបបានរយៈពេលពី ២- ៣ ថ្ងៃ ឬនៅពេលដែលដី ចាប់ផ្តើមប្រេះក្រហែង ត្រូវប ញ្ចូលទឹកក្នុងថ្នាល។ នៅពេលដែលសំណាបដុះ ត្រូវរក្សាកម្ពស់ទឹកឲ្យនៅត្រឹម ២ សង្ទីម៉ែត្រពីដីរហូតដល់ សំណាបត្រូវបានជញ្ជូនយកទៅស្ទូង ។
- ការបាចឬដាក់ជី: ប្រសិនបើសីតុណ្ហភាព និងទឹកសមស្រប តែសំណាបនៅតែមានពណ៌លឿង ត្រូវដាក់ជី អាសូតប្រហែលពី ១០-២០ គីឡូក្រាម ក្នុង ១ ហិចតា (ដូចជាប្រើ ជីអ៊ុយរ៉េ ពី ០,២០-០,៤០ គីឡូក្រាម ឬ ដេអាប៉េ ពី ០ ,៧៥-១,៥គីឡូក្រាមក្នុងថ្នាលដែលមានក្រឡាផ្ទៃ ១០០ ម៉ែត្រការេ ) បន្ទាប់ពីសាប បានរយៈ ពេលពី ១០-១២ថ្ងៃ ។
- ការដកសំណាប: សំណាបមានអាយុចាប់ពី ១៥ -២០ ថ្ងៃ សមស្របអាចដកយកទៅស្ទូងបាន ។ បង្ហូរទឹកចូល ថ្នាលហើយដកសំណាបដោយប្រុងប្រយត្ន័ ដើម្បីកាត់បន្ថយការដាច់ឫស រួចចងកណ្តាប់សំណាប ហើយជញ្ជូនយកទៅដាក់ ក្នុងស្រែដែលត្រូវស្ទូង ។

**កត្តាកំណត់ផ្សេងៗ** ដំណើរការបែបនេះវាសមស្របបំផុតចំពោះតំបន់ណាដែលមានប្រព័ន្ធធារាសាស្ត្រ ។ ប្រសិនបើការស្ទូង ត្រូវបាន ពន្យារពេល សំណាបអាចខូចខាតនៅពេលយើងបំបែកវាចេញពីគ្នាដើម្បីស្ទូង ។

## ៣. ការស្ទូង

ការធ្វើស្រែនៅតំបន់អាស៊ី ការស្ទូងស្រូវដោយដៃជាវិធីសាស្ត្រដ៏សាមញ្ញបំផុត ។ សំណាបដែលសាបនៅក្នុងកូនស្រែមួយស្អាតល្អ បន្ទាប់ពីមានអាយុកាលពី ១៥ -៤០ថ្ងៃ ត្រូវបានគេដក និងជញ្ជូនទៅដាក់នៅក្នុងដីស្រែដែលបានភ្ជួររាស់ និងធ្វើដីបានរាបស្មើល្អ ។

ការស្ទូងស្រូវដោយដៃ គឺយើងមិនត្រូវការម៉ាស៊ីនមានតម្លៃថ្លៃ ហើយវាសមស្របបំផុតចំពោះតំបន់ណាដែលមានកម្លាំងពលកម្មលើស និងសម្រាប់ដីស្រែណាដែលមានទំហំតូចល្មមប៉ុណ្ណោះ ។ ការស្ទូងដោយដៃអាចធ្វើបាននៅក្នុងស្រែដែលដីមិនរាបស្មើ និងកម្ពស់ទឹកក្នុងស្រែមិនស្មើគ្នា ។ ការស្ទូងធានាបាននូវដើមស្រូវដុះស្មើគ្នា និងធ្វើឱ្យស្រូវលូតលាស់លឿនជាងស្មៅ ។ ការស្ទូងអាចធ្វើឱ្យស្រូវមានលក្ខណៈខ្លាំងក្លា ដូចជាស្រូវដែលដាំនៅក្នុងដីស្រែល្អមួយដែរ ។

<u>**ការស្ទូងស្រូវដោយដៃ**</u>

- ដកសំណាបពីក្នុងកូនស្រែសាបនៅពេលដែលវាមានអាយុកាលចាប់ពី ១៥ -៣០ថ្ងៃ រួចជញ្ជូនវាដាក់ក្នុងស្រែដែលត្រូវស្ទូង
- នៅក្នុងកូនស្រែ ឬថ្នាលសំណាប អាយុកាលរបស់សំណាបពី ១៥ -២០ថ្ងៃ គឺសមស្រប សម្រាប់យកទៅស្ទូង
- បន្ទាប់ពីដកសំណាបចេញពីថ្នាលរួច ត្រូវស្ទូងសំណាបនោះភ្លាមដៃរនៅក្នុងដីស្រែដែលបានភ្ជួររាស់ និងពង្រាបបានល្អ (បើយើងពន្យារពេលស្ទូង សំណាបនោះនឹងមិនងាយដឹងខ្លួន ឬក៏អាចបណ្តាលឱ្យងាប់)
- ស្ទូងក្នុង ១គុម្ព ពី ២ -៣ដើម ក្នុងជម្រៅរាក់ល្មម ដោយមានចន្លោះគុម្ពសមស្រប ២០ សង្ទីម៉ែត្រ x ២០សង្ទីម៉ែត្រ ឬ ២២,៥ សង្ទីម៉ែត្រ x ២២,៥ សង្ទីម៉ែត្រ
- ជញ្ជូនសំណាបដោយប្រុងប្រយ័ត្នដើម្បីធានាបានថា សំណាបទាំងនោះនឹងឆាប់ដឹងខ្លួន ហើយលូតលាស់ឆាប់រហ័ស បន្ទាប់ពីបានស្ទូងរួចភ្លាម ។

**កត្តាកំណត់ផ្សេងៗ**

- ការស្ទូងស្រូវវាមានការនឿយហត់ខ្លាំងនិងចំណាយពេលព្រមទាំងកម្លាំងពលកម្មច្រើន (៣០ នាក់ក្នុង ១ថ្ងៃ ក្នុង១ ហិកតា) ។
- អ្នកស្ទូងស្រូវអាចទទួលរងការឈឺខ្នង (គ្រោះថ្នាក់ដល់សុខភាព)
- ពិបាករកកម្លាំងឱ្យបានគ្រប់គ្រាន់ ដើម្បីស្ទូងបានទាន់ពេលវេលាកំណត់
- ពិបាករក្សាចន្លោះគុម្ពសមស្របឱ្យត្រង់ជួរ ដង់ស៊ីតេស្រូវស្មើគ្នា
- គ្រោះថ្នាក់នៅក្នុងតំបន់គ្មានភ្លៀងធ្លាក់ ដែលសំណាបពូជស្រូវទំនើបមាន អាយុចាស់ជ្រុល

## ៤. ការគ្រប់គ្រងទឹក

ស្រូវជាដំណាំដែលត្រូវការទឹកខ្លាំង ជាពិសេសនៅវគ្គបង្កបង្កើតផល (ចាប់ពីដំណាក់កាលកំណត់កំណើតកួរ រហូតដល់ដាក់ទឹកដោះ ) ។ ការធ្វើឱ្យមានទឹកដក់ជាប្រចាំនៅក្នុងស្រែ ជាមធ្យោបាយមួយដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការខាងលើ បន្ថយនូវហេតុការណ៍ទាំងឡាយ ដែលអាចធ្វើឱ្យដើមស្រូវអន់កម្លាំង និងបាត់បង់ទិន្នផល ជួយទប់ស្កាត់ការដុះលូតលាស់នៃស្មៅចង្រៃ ព្រមទាំងបង្កើនប្រសិទ្ធិភាពនៃដីក្នុងការស្រូបយកជីជាតិអាសូត ហើយនៅក្រោមលក្ខខ័ណ្ឌខ្លះវា ការពារមិនឱ្យសីតុណ្ហភាពដំណាំឡើងចុះខ្លាំង ។ កត្តាសំខាន់ៗដែលកំណត់សេច ក្តីត្រូវការទឹកសរុបនៃដំណាំមាន ៖

*ការស្រូបរបស់ដំណាំ និង រំហួត* ៖ ក្នុងវគ្គដំបូង ទឹកមួយចំនួនធំត្រូវបានដំណាំស្រូវប្រើប្រាស់ ដោយស្រូបយកចំហាយទឹកដែលភាយពីដី ឬពីផ្ទៃទឹកតាមស្លឹករបស់វា ប៉ុន្តែនៅពេលដំណាំនេះមានស្លឹកច្រើន ការប្រើប្រាស់ទឹកត្រូវបានធ្វើឡើងជាសំខាន់ដោយការស្រូបតាមឫស ហើយបញ្ចេញតាមស្លឹកមកវិញ ។ ការប្រើប្រាស់ទឹកដោយវិធីទាំង២នេះ តែងកើតមានរហូតដល់ទៅ ៨០% នៃបរិមាណទឹកដែលប្រើប្រាស់ដោយដំណាំស្រូវសរុប ។ នៅកម្ពុជា ទឹកដែលប្រើប្រាស់ដោយដំណាំស្រូវតាមរយៈបាតុភូតនេះ មានជម្រៅពី ៨០០ ទៅ ១២០០ មីល្លីម៉ែត្រ អាស្រ័យទៅនឹងលក្ខខ័ណ្ឌ រដូវកាល ដូចជាកំដៅ សំណើមបរិយាកាស ល្បឿន ខ្យល់បក់ ព្រមទាំងអាយុ ឬ រយៈកាលដាំដុះដំណាំ ។

*ការជ្រាបទឹកទៅក្នុងដី៖* បរិមាណទឹកដែលបាត់បង់តាមរយៈការជ្រាប និងហូរចុះទៅក្រោមដីផុតស្រទាប់ឫសនៃដំណាំ អាស្រ័យទៅនឹងប្រភេទដី វត្តមាននៃស្រទាប់ទប់ទឹក ឬស្រទាប់ដីរឹង ព្រមទាំងកម្ពស់ទឹកក្រោមដី។ ដីដែលមានល្បាយដីឥដ្ឋច្រើន ក្នុងកម្រាស់ក្រាស់ តែងធ្វើឱ្យការជ្រាបទឹកមានកម្រិតទាបជាង ដីប្រភេទខ្សាច់ ។ ទឹកដែលបាត់បង់ដោយជ្រាបក្នុងដីឥដ្ឋអាចប្រែប្រួលពី ២០០ ទៅ ៤០០ មីល្លីម៉ែត្រ ឯក្នុងដីខ្សាច់វិញ បរិមាណនេះអាច កើតមានរហូតដល់ទៅ ១០០០ មីល្លីម៉ែត្រ ។ ការវាយច្របល់ដី អាចជួយបង្កើតឱ្យមានស្រទាប់ដីរឹងនៅពីក្រោមស្រទាប់ដីភ្ជួររាស់ ដែលអាចជួយ កាត់បន្ថយការជ្រាបទឹក ទៅក្រោមបានមួយចំនួនធំ ។ ជាទូទៅ ស្រទាប់ដីបាតគន្លង គឺជាស្រទាប់ដីរឹងនេះហើយជាញឹកញាប់ វាត្រូវបានធ្វើឱ្យខូចខាតដោយ ការភ្ជួររាស់ដីក្នុងជម្រៅជ្រៅជាងធម្មតា ។ ក្នុងរដូវវស្សា ក ម្ពស់ទឹកក្រោមដីតែងឡើងខិតមកជិតផ្ទៃដីខាងលើ ហើយជួយធ្វើឱ្យថយចុះនូវបរិមាណទឹកប្រើប្រាស់ ជាពិសេសសម្រាប់ប្រភេទ ដីខ្សាច់ ។

*ការបង្ហូរទឹកចេញ* ៖ ការបង្ហូរទឹកចេញពីស្រែអាចជាកិច្ចការដ៏សំខាន់នៅពេលធ្វើការដាំបណ្តុះដំណាំ ពេលមានភ្លៀងធ្លាក់ច្រើន និងនៅពេលមានការយាយី ពីសំណាក់កត្តាចង្រៃមួយចំនួន ។ ស ម្រាប់វិធីដាំដុះដោយព្រោះ ឬដាំគ្រាប់ពូជផ្ទាល់ រាប់ទាំងការសាបសំណាបផង ជារឿយៗគេត្រូវតែបង្ហូរទឹកចេញពីស្រែនៅក្រោយពេលដាំ ដើម្បីបង្កើន អត្រាដំណុះដាក់ស្តែងក្នុងស្រែ ។ ទោះបីជាដំណាំស្រូវអាចទ្រាំទ្របានជាមួយនឹងការជន់លិច ក្នុងរយៈពេលមួយខ្លីក៏ដោយ ក៏ការបាត់បង់ទិន្នផលដ៏ធំមួយ អាចកើតមានឡើងបាន កាលណាដើមស្រូវត្រូវបានដួលទៅក្នុងទឹក ជាពិសេសនៅពេលដែលវាកំពុងដាក់គ្រាប់ មិនអាចបង្ហូរទឹក ចេញ ។

*អាយុកាល ឬ រយៈពេលដាំដុះ* ៖ ជាទូទៅអាយុកាល ឬរយៈពេលដាំដុះកាន់តែយូរដំណាំស្រូវត្រូវការទឹកកាន់តែច្រើន។ សម្រាប់តំបន់ដែលមានដក់ទឹកជ្រៅ គេចាំបាច់ត្រូវជ្រើសរើសស្រូវពូជធ្ងន់មកដាំ ព្រោះវាអាចលូតលាស់ និងមានកម្ពស់គ្រប់គ្រាន់ សមស្របជាមួយជម្រៅទឹកបែបនោះ ។

*ការកៀរពង្រាបដីស្រែ* ៖ សភាពខ្ពស់ទាបរបស់ដីក្នុងស្រែ តែងមានឥទ្ធិពលជាខ្លាំងដល់ការគ្រប់គ្រងដំណាំស្រូវទិន្នផល និងគុណភាពរបស់វា ។ ដីស្រែដែលពុំរាបស្មើតែងត្រូវការទឹកច្រើនជាងស្រែរាបស្មើ សម្រាប់ផ្សើមដីនៅពេល ភ្ជួររាស់ និងការដាំបណ្តុះដំណាំ ។ ជម្រៅទឹកក្នុងស្រែពុំស្មើគ្នា ធ្វើឱ្យដំណាំមាន កម្ពស់ខុសៗគ្នា មានបញ្ហាស្មៅចង្រៃ ស្រូវទុំពុំដំណាលគ្នា ហើយទិន្នផល និងទំហំគ្រាប់ពុំស្មើគ្នា ។

តាមរយៈការសិក្សាកន្លងមក កម្មវិធីវិស្វកម្មកសិកម្មនៃកម្មវិធី កម្ពុជា -អ៊ីរី-អូស្ត្រាលី និងក្រោយមក វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា អាចកំណត់បានថា ការកៀរពង្រាបដីក្នុងស្រែឱ្យបានស្មើអាចធ្វើឱ្យៈ

- ទិន្នផលស្រូវកើនឡើងខ្ពស់ជាងធម្មតាប្រមាណជា ៣០%
- បន្ថយបរិមាណស្មៅចង្រៃឱ្យតិចជាងធម្មតាប្រមាណជា ៩០ % ដែលធ្វើឱ្យថយចុះពលកម្មសម្រាប់ដកវាពី ប្រមាណ ២០ មក ៥ នាក់/ថ្ងៃ ក្នុងស្រែ ១ ហិកតា និង
- មានលទ្ធភាពផ្លាស់ប្ដូរពីការដាំដុះដោយវិធីដកស្ទូង មកវិធីព្រោះ ឬដាំគ្រាប់ផ្ទាល់ ដែលធ្វើឱ្យថយ ចុះពលកម្មពី ប្រមាណ ៣៥ មកត្រឹម ១ ទៅ ២/នាក់ថ្ងៃ ក្នុងស្រែ ១ ហិកតា ។ល។


ការកៀរពង្រាបដីដោយគោ


ក្បៀរកៀរដីសាមញ្ញ


ការកៀរពង្រាបដីដោយគោយន្ត

បន្ទាប់ពីកៀរពង្រាបបានស្មើ មានបញ្ហាមួយចំនួនដូចជាៈ

- ត្រង់កន្លែងដែលដីស្រទាប់លើត្រូវបានយកចេញ អាចកើតមានបញ្ហាខ្វះដីជាតិហ្វូស្វាត ដែលអាចដោះស្រាយបាន ដោយប្រើប្រាស់ជីដែលមានសារធាតុ ហ្វូស្វាតខ្ពស់ ហើយបញ្ហានេះតែងបាត់បង់ទៅវិញដោយ ខ្លួនឯង នៅឆ្នាំបន្ទាប់
- ការពង្រាបជាថ្មីអាចនឹងត្រូវអនុវត្តនៅ ៨ ទៅ ១០ ឆ្នាំក្រោយ ប្រសិនបើការភ្ជួររាស់ដីត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ។

## ៥. ការប្រមូលផលស្រូវ

ការប្រមូលផលរួមមានការច្រូតកាត់ ការប្រមូលកណ្ដាប់ ការហាលសម្ងួត និងការសំអាត ។ គោលបំណងនៃការច្រូតកាត់ គឺប្រមូលគ្រាប់ស្រូវដែលមាននៅក្នុងស្រែឱ្យបានច្រើន គឺធ្វើយ៉ាងណាកាត់បន្ថយ ការបំផ្លាញផលស្រូវពីកត្តាផ្សេងៗ និងការខូតខាតគុណភាពគ្រាប់។ ជាទូទៅការច្រូតកាត់ធ្វើឡើងដោយប្រើ ប្រាស់កណ្ដៀវ ម៉ាស៊ីនច្រូតពាក់កណ្ដាល ស្វ័យប្រវត្ត និងម៉ាស៊ីនប្រមូលផលរួមផ្សំគ្នា។ លទ្ធផលនៃការសិក្សា មួយបានបង្ហាញថា ការបាត់បង់ផលស្រូវយ៉ាងហោចណាស់ក៏៣០ភាគរយដែរ ក្នុងអំឡុងពេលប្រមូលផល។ ដូចនេះបើយើងអនុវត្តបច្ចេកវិទ្យាក្រោយពេលប្រមូលផលបានត្រឹមត្រូវ នោះយើងអាចបង្កើនផលស្រូវបានពី ២៥ ទៅ ៣០ភាគរយ។

ការប្រមូលផលស្រូវនៅពេលវេលាសមស្របមួយ ធ្វើឱ្យយើងទទួលបានទិន្នផលច្រើន អត្រាអង្កុរដើមច្រើន និងមានដំណុះច្រើនពេលសាបរដូវក្រោយ ។ ពេលវេលាច្រូតកាត់ មិនត្រូវគិតតែពីអាយុកាលតែ ប៉ុណ្ណោះទេ គឺគេត្រូវពិនិត្យមើលផងដែរនូវកម្រិតទុំជាក់ស្តែងរបស់ស្រូវក្នុងស្រែថែមទៀត ។ ការប្រមូលផលយឺតពេកបណ្តាលឱ្យគ្រាប់ស្រូវជ្រុះខ្ចាត់ខ្ចាយក្នុងស្រែច្រើន បើស្ងួតជ្រុលពេកក៏ធ្វើឱ្យងាយប្រេះស្រាំ និងបាក់នៅពេលកិនជាអង្ករ។ ការប្រមូលផលឆាប់ពេកអាចបណ្តាលឱ្យគ្រាប់ ស្រូវជាច្រើននៅស្ទើរ ដែលធ្វើឱ្យថយចុះនូវបរិមាណផល។វិធីសាស្ត្រសាមញ្ញក្នុងការច្រូតកាត់ស្រូវនៅតំបន់អាស៊ី គឺភាគច្រើនធ្វើឡើងដោយ ដៃ គេយកកណ្តៀវជាឧបករណ៍សម្រាប់កាត់ដើមស្រូវ ដោយបន្សល់ទុកជញ្ជ្រាំងនៅក្នុងស្រែ។ ដើមស្រូវដែលកាត់រួចហើយត្រូវបានប្រមូលចងជាកណ្តាប់ ហើយហាលនៅក្នុងស្រែប្រមាណពី ២ ទៅ ៣ថ្ងៃ។ ការច្រូត កាត់ដោយដៃទាមទាកម្លាំងពលកម្មពី ៤០ ទៅ ៨០នាក់ ក្នុងមួយហិកតា ។





ការច្រូតកាត់អាចធ្វើឡើងផងដែរ ដោយម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិ តែវាមិនត្រូវបានប្រើប្រាស់ទូលំទូលាយនៅតំបន់អាស៊ីយើងឡើយ ។ ប្រទេសមួយចំនួនគេប្រើឧបករណ៍ច្រូតបំពាក់ពីមុខត្រាក់ទ័រ និងម៉ាស៊ីនគោយន្តផ្សេងៗ ដែលធ្វើឱ្យការប្រមូលផលកាន់តែមានភាពងាយស្រួល។ ចំពោះម៉ាស៊ីនមានទទឹង ១.៥ម៉ែត្រ អាចប្រមូលផលបាន ២ ទៅ ៤ហិកតា /ថ្ងៃ។ ម៉ាស៊ីនច្រូតមួយ ចំនួនត្រូវបានគេអភិវឌ្ឍន៍កាន់តែមានភាពទំនើប និងកាន់តែងាយស្រួលក្នុងការប្រមូលផល ដោយរួមបញ្ចូលទាំងការកាត់ហើយបញ្ជូនមកម៉ាស៊ីនបោកញែក សំអាត រហូតដល់ដាក់នៅក្នុងបាវតែម្តង។ តាមការសិក្សា ស្រាវជ្រាវចំពោះការបាត់បង់ គឺមានតិចជាងការច្រូតកាត់ដៃ ។



ត្រូវបង្ហូរទឹកចេញពីស្រែឱ្យបានពី ៧ ទៅ ១០ថ្ងៃ មុនពេលប្រមូលផល ឬនៅពេលដែលពិនិត្យឃើញថាស្រូវមានភាពទុំពេញលេញដែលបានប្តូរពណ៌ពីបៃតងទៅលឿងទុំ ហើយគួរច្រូតកាត់នៅពេលស្រូវស្ងួតល្អ។ ប្រសិនបើករណីដំណាំមានភាពសើមខ្លាំង ដូចជានៅពេលមានភ្លៀងធ្លាក់ ឬនៅពេលព្រឹកព្រលឹម គឺយើងគួរតែរង់ចាំ ឱ្យវាស្ងួតទឹកអស់សិនទើបធើការចេតកាត់។

ស្រូវស្ងួតល្អ





ស្រូវទុំប្រមាណពី ៨០–៨៥ភាគរយ

## ការខាតបង់ដោយច្រូតកាត់គ្រាប់ស្រូវទុំស្ទើរ

គ្រាប់ស្រូវទុំស្ទើរ មានអំប្រឹយ៉ុងមិនទាន់ពេញរូបរាងល្អ សាច់គ្រាប់មិនទាន់មានសារធាតុចិញ្ចឹមគ្រប់គ្រាន់ ដែលធ្វើឲ្យសាច់គ្រាប់មានសភាពទន់ និងមិនថ្លាល្អតាមលក្ខណៈពូជ។ គ្រាប់ស្រូវប្រភេទនេះ នៅពេលយកទៅកិន នឹងបណ្ដាលឲ្យមានការបាត់បង់អង្ករសប្រមាណ ២ គ.ក្រ និងអង្ករដើម ប្រមាណ ៥,៥ គ.ក្រ ធៀបជាមួយគ្រាប់ស្រូវទុំល្អក្នុងបរិមាណស្រូវកិន ១០០ គ.ក្រ។

## ការខាតបង់ដោយច្រូតកាត់គ្រាប់ស្រូវទុំជ្រុល

គ្រាប់ពូជស្រូវទុំជ្រុលមានដំណុះគ្រាប់ ៨ ភាគរយ ទាបជាងគ្រាប់ពូជស្រូវទុំល្អ។ គ្រាប់ស្រូវទុំជ្រុលមានសាច់គ្រាប់ប្រេះច្រើន ហើយជ្រុះច្រើន ងាយបាក់នៅពេលបោកបែន។ គ្រាប់ស្រូវដែលមានសាច់គ្រាប់ប្រេះ ឬបាក់នេះ ថ្វីបើនៅពេលកិនបានអង្ករសក្នុងបរិមាណប្រហាក់ប្រហែលគ្រាប់ស្រូវទុំល្អមែន តែចំពោះបរិមាណអង្ករដើមវិញ គឺអាចទាបជាងគ្រាប់ស្រូវទុំល្អរហូតដល់ ៨ គ.ក្រ ក្នុងបរិមាណកិន ១០០ គ.ក្រ។ ក៏ដូចគ្នាដែរចំពោះគ្រាប់ពូជស្រូវ គឺមិនមានភាពខុសគ្នាចំពោះអត្រាដំណុះ តែចំពោះដើមស្រូវ ឬសំណាបដែលដុះលូតលាស់ល្អវិញ មានបរិមាណទាបជាងគ្រាប់ពូជស្រូវទុំល្អរហូតដល់ ១០-១៥ ភាគរយ។ នេះក៏ព្រោះតែថាសាច់គ្រាប់បាក់បណ្ដាលឲ្យដើមស្រូវ ឬសំណាប មិនមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ នាពេលដុះលូតលាស់ដំបូង។ ដោយកសិករភាគច្រើនមិនអាចគ្រប់គ្រងលក្ខខណ្ឌដាំដុះដំណាំស្រូវឲ្យបានល្អ ដូចនេះការកំណត់រយៈពេលទុំ ២៧ ថ្ងៃ បន្ទាប់ពីស្រូវចេញផ្កាស្រុះ គឺមិនសូវត្រឹមត្រូវ ទេ។ ក្នុងករណីនេះ ការកំណត់សភាពទុំល្អតាមស្ថានភាពជាក់ស្ដែង គឺជាការចាំបាច់។ ការកំណត់នេះអាចធ្វើឡើងតាមវិធីសាស្ត្រពីរយ៉ាង ទៅតាមលទ្ធភាពរបស់កសិករ ដូចខាងក្រោម:

### *ការកំណត់ដោយពិនិត្យសភាពកួរស្រូវ*

ជាទូទៅ កួរស្រូវដែលមានគ្រាប់ទុំល្អ គឺជាកួរស្រូវដែលមានគ្រាប់ចាប់ពីពាក់កណ្ដាលកួរឡើងទៅមានពណ៌លឿងទុំចាស់ និងគ្រាប់ពេញពាក់កណ្ដាលកួរចុះក្រោមមានពណ៌លឿងទុំស្រាល ហើយគ្រាប់ស្កុកវិញមានពណ៌ស្លាបសេកចាស់។ ចំពោះកួរស្រូវដែលទុំជ្រុល មានគ្រាប់ដាក់ផ្នែកខាងគល់កួរពណ៌លឿងទុំចាស់ និងគ្រាប់ស្កុកមានពណ៌លឿងទុំប្រផេះ។ ចំពោះកួរស្រូវដែលទុំស្ទើរមានគ្រាប់ដាក់ផ្នែកគល់កួរពណ៌ស្លាបសេកចាស់ និងគ្រាប់ស្កុកពណ៌បៃតងចាស់។

- **តារាងសង្ខេបការកំណត់សភាពស្រូវទុំ**

| សភាពទុំ | សំណើមគ្រាប់ (%) | ពណ៌គ្រាប់ដាក់ក្នុងកួរ | | ពណ៌គ្រាប់ស្កុកក្នុងកួរ |
|---|---|---|---|---|
| | | ពាក់កណ្ដាលខាងលើ | ពាក់កណ្ដាលខាងក្រោម | ពាក់កណ្ដាលខាងក្រោម |
| ទុំស្ទើរ | ខ្ពស់ជាង ២៥ | លឿងទុំស្រាល | ស្លាបសេកចាស់ | បៃតងចាស់ |
| ទុំល្អ | ២១-២៥ | លឿងទុំចាស់ | លឿងទុំស្រាល | ស្លាបសេកចាស់ |

| | | | | |
|---|---|---|---|---|
| ទុំជ្រុល | <២១ | លឿងទុំចាស់ | លឿងទុំចាស់ | លឿងទុំប្រផេះ |

**កំណត់សម្គាល់**

- ការកំណត់គ្រាប់ស្រូវទុំល្អ ដើម្បីច្រូតកាត់ដោយឧបករណ៍វាស់សំណើមក្តី ដោយពិនិត្យសភាពកួរស្រូវក្តី ត្រូវធ្វើច្រើនកន្លែង ទៅតាមសភាពទុំ និងទំហំដីស្រែ។
- ក្នុងករណីដែលស្រូវទុំស្រុះគ្នា ការប្រើប្រាស់វិធីសាស្ត្រកំណត់សម្រាប់កួរស្រូវទាំងអស់ គឺជាការត្រឹមត្រូវ
- ក្នុងករណីដែលកួរស្រូវទុំមិនស្រុះគ្នា ឬបណ្តើរកូន ត្រូវច្រូតកាត់នៅពេលដែលកួរស្រូវ ៨៥-៩០ ភាគរយ មានសភាពទុំល្អ ចំណែក ១០-១៥ ភាគរយទៀត មានសភាពទុំស្មើរ

**ប្រការគួរចងចាំ**

-បើសិនជាអាចធ្វើបាន ត្រូវបង្ហូរទឹកស្រែបន្ទាប់ពីស្រូវចេញផ្កាស្រុះ និងបានរយៈពេលពី ១៧-២០ ថ្ងៃ

-ចៀសវាងច្រូតកាត់ស្រូវបន្ទាប់ពីភ្លៀងរួចភ្លាមៗ

-ការហាលកណ្តាប់ក្នុងស្រែ ត្រូវចៀសវាងកុំឲ្យកណ្តាប់ត្រូវទឹក

-ត្រូវប្រញាប់បោកបែន ហាល សម្អាត និងទុកដាក់បន្ទាប់ពីច្រូតរួច

# កម្រិតជីណែនាំសម្រាប់ផលិតកម្មដំណាំស្រូវ

## ១. ការប្រើប្រាស់ជីគីមីលើដំណាំស្រូវ

**សារ**ធាតុចិញ្ចឹម N P K ជាសារធាតុដ៏សំខាន់ក្នុងចំណោមសារធាតុចិញ្ចឹមផ្សេងៗទៀត ដែល រុក្ខជាតិត្រូវការដើម្បីទ្រទ្រង់ការលូតលាស់ និងផ្តល់ផ្លែផ្ការបស់វា ។ ដីភាគច្រើននៅប្រទេសកម្ពុជា ជាពិសេស ដីសម្រាប់ដំណាំស្រូវ ពុំអាចផ្គត់ផ្គង់សារធាតុចិញ្ចឹមទាំងនេះ ឲ្យបានគ្រប់គ្រាន់តាមតម្រូវការរបស់ដំណាំឡើយ។ ដូច្នេះដើម្បីធានាបាននូវការលូតលាស់ជាប្រក្រតីរបស់ដំណាំ គេចាំបាច់ត្រូវតែបាចជីបន្ថែមឲ្យបាន ត្រឹមត្រូវទៅតាមតម្រូវការរបស់ដំណាំ និងអនុវត្តឲ្យបានខ្ជាប់ខ្ជួនតាមបទដ្ឋានបច្ចេកទេស ដើម្បីចៀសវាងនូវការខាតបង់ថវិកា ពេលវេលា និងផលប៉ះពាល់ដល់បរិស្ថាន។ ម្យ៉ាងទៀត បរិមាណជីដែលត្រូវប្រើក៏អាស្រ័យទៅនឹងប្រភេទដី ពូជដំណាំ របបទឹក និងកត្តាបរិស្ថានផ្សេងៗទៀត។ **ខាង**ក្រោមនេះគឺជាអនុសាសន៍ នៃការប្រើប្រាស់ជីគីមីលើដំណាំស្រូវ :

តារាងការប្រើប្រាស់ជីគីមីលើដំណាំស្រូវ នៅលើក្រុមដីសំខាន់

| ក្រុមដី | ស្រូវស្រាលមិនប្រកាន់រដូវ (ស្រូវប្រាំង និងស្រូវវស្សា) | | | | ស្រូវកណ្តាល និងស្រូវធ្ងន់ (ស្រូវវស្សា) | | | | |
|---|---|---|---|---|---|---|---|---|---|
| | បាចទ្រាប់បាតមុនស្ទូង ឬព្រោះ (គ.ក្រ/ហាត) | | | បំប៉ន (គ.ក្រ/ហាត) | បាចទ្រាប់បាតមុនស្ទូង ឬព្រោះ (គ.ក្រ/ហាត) | | | បំប៉នអ៊ុយរ៉េ(គ.ក្រ/ហាត) | |
| | អ៊ុយរ៉េ ៤៦-0-0 | ដេ អា ប៉េ ១៨-៤៦-0 | ប៉ូតាស្យូ 0-0-៦0 | អ៊ុយរ៉េ ៤៦-0-0 | អ៊ុយរ៉េ ៤៦-0-0 | ដេ អា ប៉េ ១៨-៤៦-0 | ប៉ូតាស្យូ 0-0-៦0 | លើកទី ១ | លើកទី ២ |
| ដីព្រៃខ្មែរ | ២0 | ២៥ | ៥0 | ២៥ | ១0 | ២0 | ៤0 | ២0 | ១0 |
| ដីប្រទះឡាង | ២៥ | ៥0 | ៥0 | ៥0 | ១0 | ៥0 | ២៥ | ២៥ | ២៥ |
| ដីបាកាន ឬអូររាំង | ៥0 | ៦0 | ៥0 | ៨0 | ២៥ | ២៥ | ២៥ | ៥0 | ២៥ |
| ដីទួលសំរោង | ៥0 | ៥0 | 0 | ១00 | ២៥ | ៥0 | 0 | ២៥ | ២៥ |
| ដីគោកត្រប់ | ៥0 | ៧៥ | ៥0 | ៧៥ | ១0 | ៥0 | ៥0 | ៤0 | ៣៥ |
| ដីកំពង់សៀម | ៥0 | 0 | 0 | ៥0 | ៣0 | 0 | 0 | ៤0 | ៣0 |
| ដីកៀនស្វាយ | ៦0 | 0 | 0 | ៦0 | ជាដីតាមមាត់ច្រាំងទន្លេ | | | | |

| | | | | | |
|---|---|---|---|---|---|
| | | | | | និងជម្រាលពីច្រាំងទន្លេសមស្របសម្រាប់ស្រូវស្រាល |
| ដីក្រគរ | ១០០ | ៥០ | ០ | ១០០ | ជាដីលិចទឹករយៈពេលយូរ ដែលកសិករធ្វើស្រូវឡើងទឹក ឬប្រដេញទឹក |
| ដីក្បាលពោធិ | ៨៥ | ០ | ០ | ៨៥ | |

## ក្រុមដីព្រៃខ្មែរ

**ដី**ប្រភេទនេះពុំសូវឆ្លើយតបខ្លាំងទៅនឹងការប្រើប្រាស់ជីទេ ហើយប្រសិទ្ធិភាពនៃជីអាសូតធ្លាក់ចុះ កាលណាគេពុំប្រើជីប៉ូតាស្យូម។ ប្រសិនមានទឹកគ្រប់គ្រាន់ ហើយតម្លៃស្រូវនៅលើទីផ្សារបានថ្លៃ នោះគេអាចប្រើជីក្នុងកម្រិត ៥០ :១០:៥០ ឬ ២៧ :១១:០០។ បើលក្ខណៈផ្ទុយពីនេះគួរកុំប្រើប្រាស់ជីប្រសើរជាង។ កម្រិតណែនាំឲ្យប្រើប្រាស់ ខាងលើនេះ គឺសមស្របសម្រាប់ពូជទំនើប ឬពូជប្រពៃណី ព្រោះវាអាចផ្តល់ទិន្នផលបានប្រហាក់ប្រហែលគ្នា។

## ក្រុមដីប្រទះឡាង

**ប្រសិទ្ធិភាព**នៃជីអាសូតធ្លាក់ចុះ កាលណាគេពុំប្រើជីប៉ូតាស្យូម ។ កាលណាមានទឹកគ្រប់គ្រាន់ផ្សំនឹងការប្រើប្រាស់ជីប៉ូតាស្យូម ហើយផលស្រូវមានតម្លៃខ្ពស់គេអាចដាក់ជីអាសូត និងផូស្វ័ររហូតដល់កម្រិត ១០០:៥០:៥០ បាន។ ប៉ុន្តែបើពុំដាក់ជីប៉ូតាស្យូមទេ ហើយស្រែពុំមានទឹកគ្រប់គ្រាន់នោះ គួរប្រើជីអាសូត និងផូស្វ័រ ក្នុងកម្រិត ៣៣ :២៣:០០ ឬទាបជាងនេះ។ បើប្រើជីក្នុងកម្រិតទាប ឬមធ្យម ពូជទំនើបនឹងផ្តល់ទិន្នផលប្រហាក់ប្រហែល ឬទាបជាងពូជប្រពៃណី។ តែបើប្រើជីក្នុងកម្រិតខ្ពស់នោះ វានឹងផ្តល់ទិន្នផលខ្ពស់ជាងពូជប្រពៃណី។ គួរចាំថាបើ ប្រើពូជទំនើបគួរដាក់ជីឲ្យបានច្រើន។

## ក្រុមដីបាកាន ឬអូរ្លង

**ចំពោះ**ក្រុមដីប្រភេទនេះ ការប្រើប្រាស់ជីអាសូត និងផូស្វ័រ តែងតែទទួលបានទិន្នផលល្អ ប៉ុន្តែចម្លើយតបទៅលើ ជីប៉ូតាស្យូម មានលក្ខណៈទាប និងមានការប្រែប្រួលទៀតផង។ ក្នុងលក្ខខណ្ឌដាំដុះមិនគាប់ប្រសើរ ចម្លើយតបទៅនឹងជីប៉ូតាស្យូម មានតិចតួច ហើយបើនៅលើដីដែលមានជីជាតិល្អនៃក្រុមដី បាកានការដាក់ប៉ូតាស្យូមពុំ ស្តែងចេញនូវប្រសិទ្ធិភាពរបស់វាទេ។ ក្នុងករណីនេះពុំគួរប្រើជីប៉ូតាស្យូមទេ ប៉ុន្តែបើលក្ខខណ្ឌនៃការដាំដុះ មានលក្ខណៈប្រពលវប្បកម្មរយៈពេលប្រហែល ៥ឆ្នាំ ការប្រើប្រាស់ជីប៉ូតាស្យូមអាចមានប្រសិទ្ធិភាព ។ ប្រសិនបើតម្លៃផលស្រូវខ្ពស់ ហើយស្រែមានទឹកគ្រប់គ្រាន់សម្រាប់ដាំ ដុះនោះគួរប្រើកម្រិតជីអាសូត និងផូស្វ័រឲ្យបានខ្ពស់នៅលើដីប្រភេទនេះ (១២០:៦០:៣០) ។ ពូជទំនើបតែងតែផ្តល់ទិន្នផលខ្ពស់ជាងពូជប្រពៃណី នៅលើដីប្រភេទនេះ ទោះបីជាដាក់ ឬមិនដាក់ជីក៏ដោយ។ កម្រិតជីណែនាំខ្ពស់គឺប្រើសម្រាប់តែការដាំដុះពូជស្រូវទំនើប ប៉ុណ្ណោះ។

## ក្រុមដីទួលសំរោង

ការប្រើប្រាស់ជីអាសូត និងជីផូស្វ័រ នៅលើដីប្រភេទនេះ ផ្តល់នូវចម្លើយតបយ៉ាងខ្លាំងសមស្របទៅនឹង

តម្រូវការ របស់ដំណាំស្រូវ។ ជាទូទៅការប្រើប្រាស់ប៉ូតាស្យូម ពុំមានប្រសិទ្ធិភាពទេ លើកលែងតែ តំបន់ខ្លះ (ដីមានពណ៌ ស្រាលជាង) ដែលដីមានលក្ខណៈហូរច្រោះខ្លាំងជាងធម្មតា។ ចំពោះដីបែបនេះ (មានការហូរច្រោះខ្លាំង) គួរប្រើប៉ូតាស្យូមមួយបាវក្នុងមួយហិ ចតា ជាមួយនឹងកម្រិតជីអាសូត និងផូស្វ័រឲ្យបានទិន្នផលខ្ពស់ជាងនេះ ដើម្បីបាន ចំណេញ (ខ្ពស់ជាង ១២០:៤០:០០ ឬច្រើនជាង ៤ បាវ ជីអ៊ុយរ៉េ និង ដេ អា ប៉េ ៦៦ គ.ក )។ ពី ៤ ទៅ ៥ ឆ្នាំ ក្រោយពីការប្រើប្រាស់កម្រិតជីខ្ពស់បែបនេះ តម្រូវការនៃជីប៉ូតាស្យូមនឹងកើនឡើងយ៉ាងច្បាស់។ ទោះជាដាក់ ឬមិនដាក់ជីក្តី ក៏ពូជទំនើបផ្តល់ផលខ្ពស់ជាងពូជប្រពៃណីដែរ។ កម្រិតណែនាំខ្ពស់ៗ គឺប្រើសម្រាប់តែពូជទំនើប តែប៉ុណ្ណោះ។

### ក្រុមដីកំពង់សៀម

ការប្រើជីអាសូត មានប្រសិទ្ធិភាពល្អ រីឯប្រសិទ្ធិភាពនៃការប្រើជីផូស្វ័រ មានការប្រែប្រួល ហើយគេសង្កេតឃើញ មានការឆ្លើយតបតិចតួចទៅនឹងការប្រើប្រាស់ជីផូស្វ័រក្នុងរដូវវស្សា តែវាពុំមានផលចំណេញទេ។ ចំណែកឯជីប៉ូតាស្យូម ពុំមានប្រសិទ្ធិភាពទេ។ ប្រសិនបើប្រើពូជទំនើបនៅរដូវប្រាំងដែលមានលក្ខខណ្ឌល្អនោះ ការដាក់ជីអាសូត និងផូស្វ័រឲ្យបានខ្ពស់ជាងនេះអាចមានផលចំណេញ (គឺ ៩៨:១៨:០០ ត្រូវនឹងជីអ៊ុយរ៉េ ២០០ គ.ក និង ជី ដេ អា ប៉េ ៣៦ គ.ក ។

### ក្រុមដីគោកត្រប់ខ្សត់ជីជាតិ

បើពុំដាក់ជីអាសូត និងជីផូស្វ័រទេនោះ ដំណាំស្រូវពុំលូតលាស់ល្អទេ។ កាលណាគេដាក់ជីអាសូត និងជីផូស្វ័រ ជាមួយគ្នានោះនឹងមានប្រសិទ្ធិភាពយ៉ាងសមស្រប។ ការដាក់ជីអាសូត តែមួយមុខទំនងជាមិនបង្កើនទិន្នផលទេ ផ្ទុយទៅវិញអាចធ្វើឲ្យទិន្នផលថយចុះថែមទៀតផង។ ពូជប្រពៃណីផ្តល់ផលបានខ្ពស់ជាងពូជទំនើប កាលណាគេពុំបានប្រើជី។ តែពូជទំនើបអាចផ្តល់ផលបានច្រើនជាងពូជប្រពៃណីកាលណាគេប្រើជីកម្រិតណែនាំខាងលើ។ បើស្រែមានទឹកគ្រប់គ្រាន់ និងស្រូវមានតម្លៃខ្ពស់នោះ គេអាចប្រើកម្រិតជីខ្ពស់ជាងកម្រិតជីណែនាំ នេះជាមួយពូជទំនើបខ្ពស់ជាង ១២២:៤៦:៤០ ត្រូវនឹងជីអ៊ុយរ៉េ ២២៥ គ.ក ជី ដេ អា ប៉េ ១០០ គ.ក និងជី ប៉ូតាស្យូម ៦៧ គ.ក

### ក្រុមដីក្បាលពោធិ

ដីក្រុមនេះមានជីជាតិល្អ ហើយមានការឆ្លើយតបទៅនឹងការប្រើជីអាសូត លើដំណាំស្រូវប្រាំង ឬស្រូវប្រដេញទឹក។ ជាទូទៅ ប្រភេទដីនេះពុំមានការឆ្លើយតបទៅនឹងការប្រើជីផូស្វ័រទេ។ បើមានទឹកគ្រប់គ្រាន់ និងស្រូវមាន តម្លៃខ្ពស់ គួរប្រើជីអាសូតក្នុងកម្រិតខ្ពស់ជាងនេះ (ខ្ពស់ជាង ១២០:០០:០០ ត្រូវនឹងជីអ៊ុយរ៉េ ២៦៣គ.ក)។ ការប្រើកម្រិតជីអាសូតខ្ពស់បែបនេះលើដំណាំស្រូវដែលមានការគ្រប់គ្រងទឹកបានល្អ អាចទទួលបានទិន្នផលខ្ពស់។ ក្នុងរយៈពេល ៤ ទៅ ៥ ឆ្នាំក្រោយពីការប្រើជីអាសូតខ្ពស់នឹងមានការឆ្លើយតបទៅនឹងជីផូស្វ័រ ជាពុំខាន (គឺ ១៨០:៤៥:០០ ត្រូវនឹង ជីអ៊ុយរ៉េ ៣៥០គ.ក និងជីដេ អា ប៉េ ១០០ គ.ក )។ នៅរដូវវស្សាពូជស្រូវប្រពៃណីដែលដាំនៅលើដីប្រភេទនេះ ច្រើនជាពូជស្រូវឡើងទឹក ហើយពុំមានការចំណេញ ពីការប្រើប្រាស់ជីទេ។

**ក្រុមដីក្រគរ**

ដីក្រុមនេះមានជីជាតិល្អ មានការឆ្លើយតបទៅនឹងការប្រើជីអាសូត និងជីផូស្វ័រ នៅលើដំណាំស្រូវប្រាំង ឬស្រូវប្រដេញទឹក។គេអាចទទួលបានផលខ្ពស់ កាលណាគេបាចជីអាសូតក្នុងកម្រិតខ្ពស់ទៅលើដំណាំ ស្រូវប្រាំង ដែលពឹងផ្អែកទាំងស្រុងលើការស្រោចស្រព។ ក្រោយពីមានការប្រើជីអាសូត ក្នុងកម្រិតខ្ពស់ អស់រយៈពេលប្រហែល ៤ ទៅ ៥ ឆ្នាំ ក្រោយមក គេនឹងសង្កេតឃើញមានការឆ្លើយតបទៅនឹងការប្រើជី (គឺ ១៨០:៤៥:០០ ត្រូវនឹងជី អ៊ុយរ៉េ ៣៥០គ.ក និងជីដេ អា ប៉េ ៥០ គ.ក ) ។ នៅរដូវវស្សាពូជប្រពៃណី ដែលដាំនៅលើដីប្រភេទនេះច្រើនជា ស្រូវឡើងទឹក ហើយពុំមានការចំណេញពីការប្រើប្រាស់ជីទេ។

**ក្រុមដីកៀនស្វាយ**

ដីក្រុមនេះមានជីជាតិល្អ ហើយមានការឆ្លើយតបទៅនឹងការប្រើជីអាសូត លើដំណាំស្រូវប្រាំង ឬស្រូវប្រដេញទឹក។ពេលវេលាសមស្របសម្រាប់បាចជីអាសូតគឺក្នុងដំណាក់កាលស្រូវបែកគុម្ពអតិបរិមា ហើយអាចទទួលបានទិន្នផលខ្ពស់រហូតដល់ ៥.០២ តោនក្នុងមួយហិកតា។

## ២. ការធ្វើជីកំប៉ុស្ត៍

ជីលាមកសត្វ ផេះ ចំបើង ស្មៅ និងស្លឹករុក្ខជាតិ គឺជាសារធាតុចិញ្ចឹមដែលត្រូវការចាំបាច់ណាស់សម្រាប់ដំណាំ។ ជី ទាំងនោះជាជីសរីរាង្គ ដើម្បីឲ្យជីងាយរលាយ និងផ្តល់នូវសារធាតុចិញ្ចឹមសម្រាប់ដំណាំ យើងត្រូវធ្វើជាជីកំប៉ុស្ត៍។

**សារៈសំខាន់នៃការប្រើជីកំប៉ុស្ត៍**

- ជួយកែលម្អជីជាតិ និងផលិតភាពដី
- ជួយឲ្យដីធូរ ងាយស្រួលដល់ការលូតលាស់របស់ដំណាំ និងខ្យល់ចេញចូលក្នុងដីបានល្អ
- ជួយដីក្នុងការចាប់យកទឹក និងជីជាតិ
- បង្កើនសត្វមានជីវិតរស់នៅក្នុងដី
- ជួយបង្កើនទិន្នផល និងគុណភាពផលិតផលដំណាំ។
- ជួយជំរុញឲ្យជីគីមី មានប្រសិទ្ធភាពនៅពេលប្រើលាយជាមួយជីកំប៉ុស្ត៍
- បន្ថយជាតិពុលនៃដី

**កត្តាជាច្រើននាំមកនូវជោគជ័យក្នុងការធ្វើជីកំប៉ុស្ត៍**

ជោគជ័យនៃការធ្វើជីកំប៉ុស្ត គឺការកើនឡើងនូវចំនួនសារធាតុចិញ្ចឹមនៅក្នុងដី ដែលសារធាតុទាំងនេះធ្វើឲ្យដំណាំលូតលាស់ល្អ និងផ្តល់ទិន្នផលខ្ពស់។ មានកត្តាជាច្រើននាំមកនូវជោគជ័យក្នុងការធ្វើជីកំប៉ុស្ត៍គឺៈ

- ធាតុផ្សំសម្រាប់ធ្វើជីកំប៉ុស្ត៍ ដូចជាលាមកសត្វ ដើមពោត ចំបើង ស្មៅ ស្លឹកឈើ និងផេះ
- ខ្យល់នៅក្នុងគំនរជីកំប៉ុស្ត៍សមស្រប
- សំណើមនៃគំនរជីសមល្មម មិនជោគពេក ហើយក៏មិនស្ងួតពេកដែរ
- សីតុណ្ហភាព



សារធាតុចិញ្ចឹមនៃជីលាមកសត្វ កាកសំណល់រុក្ខជាតិ ក្នុងនោះរាប់បញ្ចូលទាំងកាកសំណល់ពពួកសណ្តែក និងលាមកសត្វពាហនៈនៅក្នុងសារធាតុ ទាំងនោះមានបរិមាណសារធាតុចិញ្ចឹមច្រើនដែលត្រូវការដោយដំណាំ។ គួរចៀសវាងប្រើវត្ថុដែលមានសសៃៗ និងកំទេចឈើ ដូចជាដើមព្រលិត ដើមរុក្ខជាតិតូចៗដែលគេច្រើនដាំលម្អផ្ទះ ព្រោះរុក្ខជាតិទាំងនេះវាមិនងាយនឹងរលួយឡើយ។

ការដាក់ឲ្យត្រូវខ្យល់ ឬការធ្វើឲ្យមានខ្យល់ចេញចូលក្នុងគំនរជី គឺជាការចាំបាច់ក្នុងការធ្វើឲ្យជីឆាប់ផុយរលួយ ។ គំនរជីគ្មានខ្យល់ចេញចូលនាំឲ្យជីបង្កើតជាឧស្ម័នពុល និងអាស៊ីតសរីរាង្គដែលផ្តល់ឥទ្ធិពលអាក្រក់ដល់ដំណាំ។ គំនរជីកំប៉ុស្តិ៍ត្រូវតែមានបរិមាណសំណើមសមស្រប គំនរជីដែលមាន សភាពសើមពេក នាំឲ្យជីហាប់ និងស្អិត តែបើគំនរជីនោះស្ងួតពេកក៏នាំឲ្យជីមិនងាយផុយរលួយដែរ ។ សីតុណ្ហភាពសមស្រប គឺជាសារៈប្រយោជន៍មួយដែរ ក្នុងការធ្វើជីកំប៉ុស្តិ៍។កាលណាគំនរជីមានសីតុណ្ហភាពខ្ពស់ នាំឲ្យជីឆាប់ផុយរលួយល្អ ហេតុនេះវាជាការចាំបាច់ណាស់ដែរ ត្រូវរក្សាសីតុណ្ហភាពនៃគំនរជី។ ជាទូទៅកម្តៅនៃគំនរជី ត្រូវ កើនឡើងក្នុងអំឡុងពេលពី ១ ទៅ ២ថ្ងៃ កាលណាផ្នែកខាងក្នុងនៃគំនរជីមានកម្តៅ បានន័យថាភាពរលួយ នៃជី កំប៉ុស្តិ៍កំពុងដំណើរការ។

**របៀបធ្វើជីកំប៉ុស្ត**

ដំបូងត្រូវប្រមូលវត្ថុធាតុដើមជីកំប៉ុស្តិ៍ ប្រើលាមកសត្វពាហនៈ ដើម ពោត ចំបើង ស្មៅ និងស្លឹកឈើ ។ ត្រូវយកចេញវត្ថុណាដែលយើងដឹងថាមិនរលួយ ដូចជាសំបកកំប៉ុង ប្លាស្ទិច អំបែងកែវ ជាដើម។

កាប់ចិញ្ច្រាំចំបើង និងស្មៅ ដើម្បីឲ្យចរន្តខ្យល់ចេញចូលបានល្អ និងងាយរលួយ។ ត្រូវជ្រើសកន្លែងមានម្លប់ហើយទួលបន្តិចមិនដក់ទឹក និងគួរនៅជិតប្រភពទឹកផងនោះ ជាកន្លែងសមស្រប ដោតបង្គោលឫស្សីចំណាំកន្លែងលើផ្ទៃដីមានទំហំ ២ ម X ៦ ម សម្អាតផ្លាក្បែរនោះឲ្យមានទំហំប៉ុនគ្នា ព្រោះត្រូវប្រើផ្លានោះចូកត្រលប់ជីកំប៉ុស្តិ៍ ។ គរគំនរសំណល់រុក្ខជាតិឲ្យបានកម្ពស់១៥ស.ម កៀរាស់គំនរតែមិនត្រូវសង្កត់ ឬជាន់វាឡើយ ។ គំនរនេះមិនត្រូវឲ្យហាប់ពេកទេ កម្ពស់ ៥ សង់ទីម៉ែត្រពីលើគំនរសំណល់រុក្ខជាតិ បន្ទាប់មកត្រូវចាក់ផេះ ឬកំបោរកម្រាស់ ២ សង់ទីម៉ែត្រ លើលាមកសត្វ ត្រូវដាក់បន្ថែម ជីអ៊ុយរ៉េចំនួន ១ គីឡូក្រាម ឬអាម៉ូញ៉ូមស៊ុលផាត ឬក៏ស៊ុបពែផូស្វាត បន្តការរៀបគំនរដោយដាក់កាកសំណល់រុក្ខជាតិ លាមកសត្វ និងផេះ រហូតដល់គំនរនេះកម្ពស់បានពី ១ ម៉ែត្រទៅ ១,៥ ម៉ែត្រ។ ដើម្បីរក្សាសំណើម ត្រូវស្រោចទឹកលើគំនរនោះ ដោយប្រើធុងស្រោចដំណាំ។ ត្រូវស្រោចទឹកក្នុងកម្រិតមធ្យមធ្វើដូច្នេះទើប ទឹកមិនហៀរពីគំនរ។ ចូកត្រលប់កំប៉ុស្តិ៍ក្រោយរយៈពេល ៣ សប្តាហ៍ យកផ្នែកលើទៅក្រោម និងផ្នែកក្រោមទៅលើធ្វើ









ដូច្នេះដើម្បីឲ្យ  ខ្យល់ចូលបានល្អ និងអាចបង្កើតឲ្យជីឆាប់រលួយ   ។ ស្រោចទឹកបន្ថែមដើម្បីរក្សាគំនរជីឲ្យមានសំណើម។ ៥ សប្តាហ៍ ក្រោយមកត្រូវចូកជីដាក់កន្លែងដើមវិញ ដើម្បីឲ្យកាន់តែប្រសើរត្រូវគ្របគំនរជី ដោយប្រើក្រណាត់ប្លាស្ទិក ឬក៏សម្បកបាវ ត្រូវគ្របគំនរជីឲ្យជិតលើកលែងតែផ្នែកខាងក្រោមនៃគំនរជី ដើម្បីរក្សាកម្តៅ និងបន្ថយនូវរំហួតទឹក។ ទុកគំនរជីឲ្យរលួយក្នុងរយៈ  ពេល ៤ សប្តាហ៍ នៅពេលជីអាចប្រើការបាន ជាទូទៅវាមានពណ៌ត្នោតចាស់ក្រមៅ ហើយមានសភាពដូចដី នៅ ពេលនេះ អ្នកអាចេប្រើជីកំប៉ុស្តដូចជាជីសរីរាង្គ។

# ការគ្រប់គ្រងសត្វបំផ្លាញដំណាំស្រូវ

## ១. មមាចត្នោត

មមាចត្នោតជាសត្វល្អិតចង្រៃនៃដំណាំស្រូវ មានខ្លួនតូចទំហំប៉ុនគ្រាប់អង្ករ និងមានពណ៌ត្នោតនៅពេលពេញវ័យ។ នៅជាកូនតូច វាមានពណ៌សខាប់ដូចទឹកដោះគោ វដ្តជីវិតរបស់មមាចត្នោតមានរយៈពេល ៣៥ ថ្ងៃ។ មមាចត្នោតញីនីមួយៗអាចពងបានរហូតដល់ ៥០០ ពង។ មមាចត្នោតញីពងជាកញ្ចុំៗ ហើយដែលមួយកញ្ចុំៗមានពងពី ៧-៨ តម្រៀបគ្នាដូចស្និតចេកនៅក្នុងសាច់ស្រទបស្លឹកស្រូវ។ បន្ទាប់ពីពងរួចបានប្រហែលមួយអាទិត្យ កូនមមាចត្នោតនឹងញាស់។ កូនមមាចត្នោតញាស់ត្រូវឆ្លងកាត់ការសកចំនួន ៥ ដង ដែលមានរយៈពេលប្រមាណជា ១៥ ថ្ងៃ ទើបក្លាយជាមមាចត្នោតពេញវ័យ។ ជាទូទៅ មមាចត្នោតពេញវ័យមានស្លាបខ្លី ប៉ុន្តែក្នុងករណីដែលវាត្រូវការផ្លាស់ទីជម្រកថ្មី សម្រាប់ចំណី និងបន្តពូជ ពេលនោះស្លាបវានឹងដុះលូតលាស់វែងដែលអាចឲ្យវាហើរបន្លាស់ទីបាន។





### ការបំផ្លាញរបស់វា

កូនមមាចត្នោតទើបញាស់រហូតដល់ពេញវ័យ បំផ្លាញដំណាំស្រូវចាប់ពី  សំណាបដល់ទុំ ។  ប៉ុន្តែការបំផ្លាញនេះមានកម្រិតខ្លាំងក្លាចំពោះកូនមមាច  ត្នោតជិតពេញវ័យ និងពេញវ័យ។ ការបំផ្លាញដំណាំស្រូវរបស់មមាចត្នោតមានពីរបែបគឺ ទីមួយជញ្ជក់យកជ័រពីដើមស្រូវ រហូតដល់ដើមស្រូវខ្សោះ   ខ្លោចងាប់ និងទីពីរគឺជាភ្នាក់ងារចម្លងជំងឺវីរុសពីរប្រភេទគឺជំងឺតឿស្មៅ និងជំងឺតឿរួញស្លឹក។ ជាទូទៅមមាចត្នោតច្រើនតែបំផ្លាញដំណាំ    ស្រូវធ្ងន់ធ្ងរដោយជញ្ជក់យកជ័រស្រូវប៉ុណ្ណោះ។ ចំពោះជំងឺតឿស្មៅ និងតឿរួញស្លឹក ភាគច្រើនកើតមានលើគុម្ពមួយចំនួនតូចក្នុងស្រែតែប៉ុណ្ណោះ។ ក្នុងករណីដែលសង្កេតឃើញមានគុម្ព   ស្រូវដែលកើតជំងឺទាំងពីរប្រភេទនេះ ត្រូវដកវាគរដុតចោល ដើម្បីសម្លាប់វីរុស និងទប់ស្កាត់ការរីករាលដាល ខ្លាំងឡើង។



ជំងឺតឿស្មៅ



ជំងឺតឿរួញស្លឹក

## វិធានការការពារ និងកំចាត់

ខ្យល់អាកាសក្តៅសើម និងហប់នៅក្នុងស្រែ ជាលក្ខខណ្ឌប្រកបសម្រាប់មមាចត្នោត។ ដូចនេះយើងត្រូវសម្អាតស្មៅក្នុងស្រែ និងតាមភ្លឺជាប់ជាប្រចាំ ដើម្បីឲ្យមានខ្យល់ចេញចូលបានល្អ។ ត្រូវថែរក្សាកង្កែបគ្រប់ប្រភេទពីងពាង អណ្តើកមាស កន្ទុំរុយ ស្រឹងគោក រួមទាំងត្រីក្នុងស្រែឲ្យបានច្រើន ព្រោះសត្វទាំងអស់នេះវាស៊ីពងមមាចត្នោតរហូតដល់មមាចត្នោតពេញវ័យ។ ក្នុងតំបន់ដែលងាយរងគ្រោះដោយមមាចត្នោត ត្រូវប្រើពូជស្រូវដែលធន់ទៅនឹងមមាចត្នោត។ ពូជស្រូវដែលធន់ទ្រាំមធ្យមគឺ អ៊ីអ៊ែរកេសរ គ្រូ ជលសារ និង ខា១២។ ត្រូវធ្វើដី ដោយភ្ជួរលុបគល់ជញ្ជ្រាំងឲ្យរលួយបានល្អ និងមិនត្រូវផ្តល់ឲ្យដំណាំស្រូវនូវសារធាតុចិញ្ចឹមអាសូតច្រើនជ្រុលពេកទេ ទោះបីជាសារធាតុអាសូតនោះបានមកពីប្រភពជីណាក៏ដោយ ព្រោះថាដំណាំស្រូវដែលមានសារធាតុអាសូតច្រើនជ្រុលនឹងលូតលាស់ខុសប្រក្រតីធ្វើឲ្យជាលិកាស្លឹក និងដើមមានសភាពទន់ជ្រុល សមប្រកបសម្រាប់ការចាក់ជញ្ជក់យកចំណី ព្រមទាំងរុក្ខរសមានបរិមាណជាតិស្ករ និង ប្រូតេអ៊ីនខ្ពស់ ដែលជាហេតុធ្វើឲ្យមមាចត្នោតពង ញាស់ និងសកទៅជាមមាចត្នោតពេញវ័យបានច្រើន។

ទោះបីយ៉ាងណាក៏ដោយ ការចុះត្រួតពិនិត្យស្រែជាប្រចាំគឺជាការចាំបាច់ ជាពិសេសនៅលើថ្នាលសំណាប និងស្រែសន្ទូង ឬពង្រោះ ក្នុងដំណាក់កាលបែកគុម្ព រហូតដល់ដំណាក់កាលស្រូវដាក់គ្រាប់។ ការចុះត្រួតពិនិត្យ ត្រូវធ្វើយ៉ាងហោចណាស់មួយអាទិត្យម្តង ប៉ុន្តែបើសង្កេតឃើញវត្តមានមមាចត្នោតហើយនោះ ត្រូវចុះតាមដាន ២-៣ ថ្ងៃម្តង។

**ថ្នាលសំណាប** : បន្ទាប់ពីសង្កេតឃើញថាមានមេមមាចត្នោត ២-៣ ជាច្រើនកន្លែងក្នុងថ្នាលសំណាបហើយ បីថ្ងៃក្រោយមកទៀតត្រូវចុះមកតាមដានបន្ត ។ នៅពេលឃើញវត្តមានកូនមមាចត្នោតតូចៗ ដែលទើបនឹងញាស់ស្មើ ឬច្រើនជាង ១០ ពីរតឹកបូនជ្រុងជាច្រើនកន្លែងហើយ ត្រូវចាត់វិធានការជាបន្ទាន់ទៅតាមស្ថានភាពជាក់ស្តែង។ ក្នុងករណីដែលមានទឹកគ្រប់គ្រាន់ ត្រូវបញ្ចូលទឹកពន្លិចដើមសំណាបដោយទុកចុងស្លឹក ឲ្យបានរយៈពេល ៧-៨ ថ្ងៃ ដើម្បីកុំឲ្យកូន និងមេមមាចត្នោតអាចជញ្ជក់យករុក្ខរសបាន ព្រមទាំងមិនឲ្យពងរបស់វាញាស់បាន។ ក្នុងរយៈពេលពន្លិចទឹកនេះ ត្រូវឧស្សាហ៍ដើរគោះស្លឹកសំណាប ទម្លាក់កូន និងមេមមាចត្នោតទៅក្នុងទឹករួចបង្ហូរវាចេញ ដោយដាក់ស្បៃមុងត្រងយកមកជាន់កម្ទេចចោល។ ក្នុងករណីដែលគ្មានទឹក ការប្រើប្រាស់ថ្នាំពុលកសិកម្មសមស្របគឺជាការចាំបាច់។ ជាបឋម យើងត្រូវប្រើថ្នាំបាសា ដើម្បីសម្លាប់មេមមាច ត្នោត។ មួយអាទិត្យក្រោយមក យើងត្រូវប្រើថ្នាំប៊ូទីល ដើម្បីកុំឲ្យកូនមមាចត្នោតវាសកបាន ដូចនេះវានឹងងាប់។ ត្រូវចងចាំថា មិនត្រូវយកសំណាបដែលពោរពេញទៅដោយកូនមមាចត្នោតទៅស្ទូងឡើយ។

**ស្រែសន្ទូង ឬពង្រោះ :** ការតាមដានត្រូវធ្វើដូចលើថ្នាលសំណាបដែរ នៅពេលសង្កេតឃើញមមាចត្នោត និងកូនរបស់វាមានចំនួនស្មើ ឬច្រើនជាង ១០ ក្បាល ក្នុងមួយគុម្ព ឬពីរតឹកបូនជ្រុងហើយ យើងត្រូវបញ្ចូលទឹកពន្លិចដើមស្រូវទុកតែចុងស្លឹក ក្នុងករណីដែលអាចធ្វើបាន។ បន្ទាប់ពីបញ្ចូលទឹកហើយ ត្រូវឧស្សាហ៍ដើរគោះស្លឹក

ស្រូវទម្លាក់កូន និងមេមមាចត្នោត និងបញ្ចូលហ្វូងទាឲ្យចូលស៊ី។ ទន្ទឹមនឹងនោះត្រូវសម្អាតស្មៅតាមភ្លឺស្រែ និងដើរកៀរយកមមាចត្នោតដែលអណ្តែតលើទឹកមកជាន់កម្ទេចចោល។ ក្នុងករណីដែលមានមេមមាចត្នោតច្រើនត្រូវយកស្បៃមុងមកអូសជាជំនួយ។ ក្នុងករណីដែលគ្មានទឹកបញ្ចូលពន្លិចដើម យើងត្រូវបាញ់ថ្នាំបាសា ដើម្បីសម្លាប់មេមមាចត្នោត រួចមួយអាទិត្យក្រោយមកត្រូវបាញ់ថ្នាំប៊ូទីល ដើម្បីសម្លាប់កូនញាស់ដោយការពារ មិនឲ្យវាសកបាន។

ការផ្ទុះនៃមមាចត្នោត គឺជាការកើនឡើងយ៉ាងសន្ធឹកសន្ធាប់នៃចំនួនកូន និងមេមមាចត្នោតក្នុងរយៈពេលដ៏ខ្លី ។ ក្នុងករណីនេះចំនួនមមាចត្នោតអាចមានរាប់រយក្បាលក្នុងមួយគុម្ពស្រូវ ហើយវិធានការកម្ចាត់វាត្រូវប្រើវិធានការចម្រុះ ដោយរួមទាំងការបញ្ចូលទឹកពន្លិចដើមស្រូវ ការអូសស្បៃមុង និងការប្រើថ្នាំបាសា និងប៊ូទីល ក្នុងកម្រិតខ្ពស់ជាងធម្មតា។

**តារាងបង្ហាញវិធីសាស្ត្រការពារ និងកម្ចាត់មមាចត្នោត**

| វិធីសាស្ត្រការពារ និងកម្ចាត់ | ថ្នាលសំណាប | | | ស្រែសន្ទូង និងស្រែពង្រោះ | | | ការផ្ទុះឡើងខ្លាំង នូវការបំផ្លាញ | |
|---|---|---|---|---|---|---|---|---|
| | មានទឹក | គ្មានទឹក | | មានទឹក | គ្មានទឹក | | មានទឹក | គ្មានទឹក |
| ពន្លិចទឹក+គោះទម្លាក់+កៀរប្រមូល | + | – | | + | – | | + | – |
| អូសស្បៃមុង | + | – | | + | – | | + | អូសដោយប្រុងប្រយ័ត្ន |
| បញ្ចូលហ្វូងទា | + | – | | + | – | | + | – |
| បាញ់ថ្នាំបាសា ក្នុងកម្រិត* | – | ៣០ ក្រ/១ធុង | | – | ៣៥ ក្រ/១ធុង | | ៥០-៦០ ក្រ/១ធុង | ៥០-៦០ ក្រ/១ ធុង |
| បាញ់ថ្នាំប៊ូទីល ក្នុងកម្រិត* | – | ៣ ក្រ/១ធុង ** | | – | ៤ ក្រ/១ធុង ** | | ៥-៨ ក្រ/១ធុង | ៥-៨ ក្រ/១ធុង |

* ១ ធុង ស្មើនឹងទឹក ២០ លីត្រ ប្រើប្រាស់ទឹកពី ៣៦០ ទៅ ៤០០ លីត្រក្នុងមួយហិកតា

** បើប្រើលើសកម្រិតនេះវានឹងធ្វើឲ្យប៉ះពាល់ដល់សត្វមានប្រយោជន៍

\+ អាចអនុវត្តបាន - មិនអាចអនុវត្តបាន

## ២. ទ្រីបជញ្ជក់ស្រូវ

ទ្រីបគឺជាពពួកសត្វល្អិតតូចៗ ដែលពិបាកមើលឃើញដោយភ្នែកទទេ ដែលកសិករនិយមហៅក្រា នៅលើសំណាប ។ វាច្រើនកើតមាននៅលើសំណាប សន្ទូងដែលទើបនឹងស្ទូងរួច និងនៅពេលស្រូវចេញផ្កា ។ ការផ្ទុះឡើងនៃការបំផ្លាញរបស់ទ្រីប ជាធម្មតាមានកម្រិតទាប និងដោយសារវាបំផ្លាញដំណាំស្រូវតែ នៅដំណាក់

កាលដំបូង ធ្វើឱ្យដំណាំអាចដុះលូតលាស់បំពេញសងការខូចខាតនេះបាន ។ រយៈពេលរាំងស្ងួត គឺជាពេល ដែលទ្រីបចូលចិត្តបំផ្លាញបំផុត ។ នៅពេលដែលមានភ្លៀងខ្លាំង ធ្វើឱ្យទ្រីបធ្លាក់ចុះពីស្លឹកស្រូវហើយងាប់ ។

មេទ្រីបមានពណ៌ត្នោតក្រមៅ ដងខ្លួនតូចទ្រវែង ច្រើនរស់នៅរមូរចុងស្លឹក ។ ពងវាពណ៌សខាប់ដោត នៅលើផ្ទៃស្លឹក ដែលអាចញាស់ក្នុងរយៈពេល ៣ថ្ងៃ ។ ដង្កូវពណ៌លឿង ជញ្ជក់ផ្ទៃស្លឹកផ្នែកខាងលើ ។ ពេលដង្កូវ ពេញវ័យ វាឈប់ជញ្ជក់ស្លឹកស្រូវ ហើយខ្លួនវាក្លាយទៅជាពណ៌ត្នោតក្រមៅ សម្ងំក្នុងរមូរស្លឹកស្រូវ ក្លាយទៅ ជាដឹកឌឿ ។

មេ និងដង្កូវជញ្ជក់ស្លឹកស្រូវ ធ្វើឱ្យស្លឹកស្រូវស្ងួត និងរមូរចុងស្លឹក ។ ថ្នាល សំណាបដែលទទួលរងការបំផ្លាញ គេសង្កេតឃើញឡើងក្រហមហើយ ស្ងួត ដែលអាចឈានទៅងាប់ ។ចំណែកឯផ្កាស្រូវដែលរងការបំផ្លាញ អាចដាក់គ្រាប់មិនពេញលេញឬស្កកតែម្តង។កត្តាដែលនាំឱ្យកើតសត្វ នេះគឺ ភាពរាំងស្ងួត និងការប្រើ ប្រាស់ថ្នាំសម្លាប់សត្វល្អិតច្រើន ។

**គេអាចកម្ចាត់វាដោយ**

- ពន្លិចស្រូវរយៈពេល ២-៣ថ្ងៃ ដើម្បីសម្លាប់ទ្រីប ប្រើក្រមាសើម អូសនៅលើចុងស្រូវដើម្បីឱ្យទ្រីបជាប់នឹងក្រមាររួចយកទៅលាង ទឹក ដើម្បីឱ្យទ្រីបធ្លាក់ចុះទៅក្នុងទឹក
- ប្រើរំពាត់វាត់នៅលើចុងស្រូវ ដើម្បីវាយទម្លាក់ទ្រីបពីចុង ស្រូវទៅក្នុងទឹក
- ថ្នាំផ្សំពីរុក្ខជាតិ: ម្ទេស១ខាំកិនឱ្យម៉ត់ លាយជាមួយទឹក១ លីត្រ លាយសាប៊ូ១២មក្របន្ទាប់ យកវាលាយទឹកធម្មតា ៥លីត្រ និងយកទៅបាញ់។
- ផ្សំពីរុក្ខជាតិ: ម្ទេសកន្លះគីឡូ ស្ងោរជាមួយទឹក ៣លីត្រ រយៈពេល ២០នាទី លាយសាប៊ូ ៣០ក្រ បន្ទាប់យកវាលាយ ទឹកធម្មតា១០លីត្រ និងយកទៅបាញ់ ។ បើមានភ្លៀងបាញ់ ២ ទៅ ៣ដង ក្នុង ១សប្តាហ៍ និងបើគ្មានភ្លៀងបាញ់ ១ដងក្នុងមួយសប្តាហ៍ ។ បាញ់ថ្នាំ Nafaza, Naphorid, Desis







## ៣. ដង្កូវបំពងកាត់ស្លឹក

ដង្កូវបំពង់កាត់ស្លឹក គឺជាសត្វស៊ីស្រូវមួយ ដែលពុំសូវសំខាន់ទេ។ វាមានជាច្រើនប្រភេទ ប្រភេទខ្លះបំផ្លាញ នៅលើស្មៅក្នុងប្រឡាយ ឬស្រែ ។ សត្វនេះវាជាសត្វពាក់កណ្តាលទឹក វាចូលចិត្តពន្លឺភ្លើងនាពេលយប់ និងមាន វដ្តជីវិតប្រហែល៣០- ៣៥ ថ្ងៃ។ មេអំបៅវាមានពណ៌សរភ្លឺ និងត្នោតស្រាល ដោយមានចំណុចអុចៗខ្មៅ ។ មេ អំបៅភាគច្រើនលាក់ខ្លួននៅក្នុង គុម្ពស្រូវនាពេលថ្ងៃ ហើយវាទម្លាក់ពងនៅពេលយប់ ប្រ ហែល៥០០ ក្នុងមេ

មួយរយៈពេលប្រហែល ១សប្តាហ៍ ។ ពងវាមានពណ៌លឿងភ្លាវ រាងមូលសំប៉ែត រាយជាជួរនៅក្រោមផ្ទៃស្លឹក ដែលធ្លាក់សំយាកទៅនឹងទឹក ។ ដង្កូវពណ៌បៃតងថ្លា មានរោមឆ្មារៗជុំវិញខ្លួន ក្បាលវាពណ៌ត្នោតខ្ចីរស់នៅក្នុងរមូស្លឹកជាបំពង់ ។ នៅពេលដង្កូវពេញវ័យ វារុំបិទបំពង់ជិត ហើយភ្ជាប់បំពង់នេះទៅនឹងដើមស្រូវលើផ្ទៃទឹក ។ ដង្កូវទើបនឹងញាស់ បានមូរស្លឹកស្រូវធ្វើជាបំពង់រួច កាត់ទម្លាក់មកក្នុងទឹក ។ ពេលថ្ងៃដង្កូវលាក់ខ្លួនក្នុងបំពង់ បណ្តែតលើផ្ទៃទឹក ដែលវាអាចដកដង្ហើមក្នុងទឹកបានតាមរោមជុំវិញខ្លួនវា ។ ពេលយប់ឬត្រជាក់វាតោងឡើង ដើមស្រូវទាំងបំពង់ ដើម្បី ស៊ីស្លឹកស្រូវ ។ វាកោសស្លឹកស្រូវផ្នែកខាងលើ ទទឹងស្លឹកទៅមកៗ ធ្វើឲ្យមានស្នាម សរៗដូចកាំជណ្តើរ ។ វាច្រើនបំផ្លាញស្រូវនៅជាសំណាប និង សន្ទូងដែលទើបនឹងស្ទូងរួច ជាពិសេសនៅក្នុង ស្រែដែលមានដក់ ទឹកយូរ ។ បើសិនជាមានការបំផ្លាញខ្លាំង គេសង្កេតឃើមានស្នាមសរៗ និងដាច់ចុងស្លឹកស្រូវ ។

**វិធានការការពារ និងកំចាត់**

- ដោយបង្ហូទឹកចេញទុកឲ្យស្រែស្ងួតរយៈពេល ២-៣ថ្ងៃ
- ស្ទូងសំណាបចាស់
- ធ្វើថ្នាលសំណាបគោក
- បាចផេះនៅពេលល្ងាច
- សត្វមានប្រយោជន៍ មានប្រសិទ្ធិភាពក្នុងការកំចាត់សត្វនេះ
- បាញ់ថ្នាំ Abamectin

## ៤. ដង្កូវមូរស្លឹក



ដង្កូវមូរស្លឹក គឺជាសត្វស៊ីស្រូវមួយ ដែលអាចកើតមាននៅគ្រប់បរិស្ថានដំណាំស្រូវ ។ មានវដ្តជីវិតប្រហែល ៣០- ៣៥ ថ្ងៃ។ មេអំបៅវាមានពណ៌ត្នោតលឿង ដោយមានចំណុច ឆ្នូតខ្មៅៗនៅលើស្លាប ។ មេអំបៅភាគច្រើនលាក់ខ្លួននៅក្នុងគុម្ពស្រូវនាពេលថ្ងៃដើម្បីគេចខ្លួនពីពួកប្រេដាទ័រ ។ ទោះបីជាមានការរំខានវានៅពេលថ្ងៃនៅ

ពេលដែលវាទំ ខ្លួនវាមានរាងជាត្រីកោណសម័ង្ស ហើយឈ្មោលមានរូបរាងតូចជាងញី ។ វាទម្លាក់ពងនៅពេលយប់ ជាដុំៗ ប្រហែល ១០-១២ ។ ពងវាមានពណ៌សរថ្លា ទៅសរខាប់នៅពេលជិតញាស់ និងមានរាងមូលទ្រវែងរាយជាជួរ ឬ ជាកញ្ចុំ ភាគច្រើននៅក្រោមផ្ទៃស្លឹក ។ ដង្កូវពណ៌បៃតងថ្លា ខ្លួនវារាងមូរទ្រវែង រស់នៅក្នុងរមូសេក្លឹ ។ ក្រោយពេលញាស់ភ្លាម ដង្កូវវារទៅរកបណ្តូល ដើម្បីស៊ីចិញ្ចឹមជីវិត និង បន្ទាប់មក វាទៅរកស្លឹកថ្មីទៀត ។ ប្រភេទខ្លះរស់នៅក្នុងរមូស្លឹក តែដង្កូវមួយ ប៉ុន្តែប្រភេទខ្លះទៀតក្នុងរមូស្លឹកមួយមានដង្កូវពីរ ។ ដង្កូវពេញវ័យមានពណ៌បៃតងលឿង និងក្បាលពណ៌ត្នោតខ្មៅ ។

វាលោតចុះ ឬមានចលនាយ៉ាងរហ័ស នៅពេលដែលមានអ្វីរំខានវា ។ វាក្លាយជាដឹកឌឿ ដោយរុំខ្លួនវាភ្ជាប់ទៅនឹងផ្ទៃស្លឹកផ្នែកខាងលើ ឬគល់ជញ្រ្ជាំងស្រូវ ។ ដឹកឌឿមានពណ៌លឿងភ្លឺ ហើយប្រែទៅជាលឿងត្នោត នៅពេលវាជិតញាស់ ។ វាកោសជាលិកាស្លឹកស្រូវផ្នែកខាងលើ ធ្វើឲ្យមានស្នាមសរៗវែងៗ ជាច្រើននៅលើស្លឹកស្រូវ ។ នៅពេលដែលមានការបំផ្លាញខ្លាំង គេឃើញមានរមូរស្លឹក និងស្នាមសរៗ ជាច្រើននៅលើស្លឹកស្រូវ ។ វាច្រើនកើតមាន នៅក្នុងស្រែដែលនៅក្រោមម្លប់ឈើ ប្រើប្រាស់ជីអាសូតច្រើន និងស្រែដែលស្ងួតញឹកពេក។

**វិធានការការពារ និងកំចាត់**

- កុំប្រើជីអាសូតច្រើនពេក ឬប្រើឲ្យបានច្រើនដង
- កាត់ចុងស្លឹកស្រូវ នៅវគ្គលូតលាស់
- សំអាតស្រែ កុំឲ្យស្រែមានម្លប់
- ការកំចាត់ដោយសត្វមានប្រយោជន៍
- បាញ់ថ្នាំ Abamectin

## ៥. ដង្កូវស្នែង និងដង្កូវភ្នែកឆ្មារ

ដង្កូវភ្នែកឆ្មា និងដង្កូវស្នែង គឺជាសត្វស៊ីស្រូវមួយបន្ទាប់បន្សំ។ មេអំបៅដង្កូវស្នែងមានពណ៌ត្នោតក្រមៅស្លាបមុខមានស្នាមជជារង្វង់ពណ៌សរ និងពណ៌ត្នោតជាច្រើន។ សត្វនេះវាមិនចូលចិត្តពន្លឺភ្លើងនាពេលយប់ និងមាន វដ្តជីវិតប្រហែល ៥២ ថ្ងៃ ។ វាទម្លាក់ពងបានប្រហែល៥០ - ១០០ពង ក្នុងមេមួយរយៈពេលប្រហែល ២សប្តាហ៍។ ពងវាមានពណ៌បៃតងភ្លាវ រាងមូលដូចគ្រាប់អង្កាំ នៅវាយ ឬជាជួរលើផ្ទៃស្លឹកស្រូវ ។ ដង្កូវពណ៌បៃតងលឿង មានរោមឆ្មារៗជុំវិញខ្លួនពណ៌លឿងព្រលែត ។ នៅលើក្បាលដង្កូវមានស្នែង២ និងកន្ទុយវាព្រែកជាពីរ ។ ដឹកឌឿរបស់ វាពណ៌បៃតងរលោងរាងដូច គូថខ្យង ភ្ជាប់និងស្លឹកស្រូវ ។

ចំណែកមេអំបៅដង្កូវភ្នែកឆ្មា មានពណ៌ត្នោតស្រាល ប៉ុន្តែស្លាបវាមានពណ៌លឿង និងចំណុចសរៗនៅពីលើ។ វាមានសកម្មភាពនៅពេលថ្ងៃ និងសំរាកនៅពេលយប់ ។ វាពងរាយគ្នាមួយៗ បិទភ្ជាប់នៅលើស្លឹកស្រូវ និងពិបាកមើលឃើញ ។ ដង្កូវមានពណ៌បៃតង និងមានភ្នែកធំៗពណ៌ត្នោតខ្មៅភ្លឺរលោង មានសណ្ឋានដូចភ្នែកឆ្មា ។ ពេលថ្ងៃ ដង្កូវលាក់ខ្លួននៅគល់ស្រូវ ។ ដង្កូវទើបនឹងញាស់បានមូរ ឬផ្គោបស្លឹកស្រូវធ្វើជាកន្លែងពួនសំរាក ដង្កូវរុំផ្គោបខ្លួនទៅនឹងស្លឹក រួចរុំផ្គោបស្លឹកស្រូវ២ -៣ជាបំពងសំរាប់វាក្លាយទៅជាដឹកឌឿ ដែលមានពណ៌ត្នោតស្រាល ឬបៃតងស្រាល ។

ដង្កូវទាំង២នេះវាស៊ីស្លឹកស្រូវដូចគ្នា គឺស៊ីដាច់តាមបណ្តោយស្លឹកស្រូវ ។ វាច្រើនបំផ្លាញស្រូវនៅជាសំណាប និងសន្ទូងដែលទើបនឹងស្ទូងរួច ។ វិធានការដាំដុះ និងពូជធន់ពុំមានប្រសិទ្ធិភាពទេ ប៉ុន្តែសត្វមានប្រយោជន៍ មានប្រសិទ្ធិភាពបំផុតក្នុងការកំចាត់សត្វនេះ ។ គេអាចកំចាត់វាដោយបាញ់ថ្នាំ Abamectin ឬថ្នាំពុលផ្សេងទៀតមានប្រសិទ្ធិភាពល្អ ។

## ៦. ដង្កូវស៊ីរូងដើមស្រូវ

ដង្កូវស៊ីរូងដើមមានច្រើនប្រភេទនៅប្រទេសកម្ពុជាដូចជា ដង្កូវស៊ីរូងដើមពណ៌លឿង ដង្កូវស៊ីរូងដើមពណ៌ស៊ីជម្ពូ ដង្កូវស៊ីរូងដើមឆ្នូត និងដង្កូវស៊ីរូងដើមក្បាលខ្មៅ ។ ប៉ុន្តែគេប្រទះឃើញភាគច្រើន នៅក្នុងប្រទេសយើង គឺពួកដង្កូវស៊ីរូងដើមពណ៌លឿង ដង្កូវស៊ីរូងដើមក្បាលខ្មៅ និងដង្កូវស៊ីរូងដើមឆ្នូត ។

មេអំបៅដង្កូវស៊ីរូងដើម ពេលថ្ងៃលាក់ខ្លួននៅក្នុងស្មៅជិតស្រែ ឬក្នុងស្រូវ ។ ពេលយប់វាធ្វើសកម្មភាពរកស៊ី និងដោយញីឈ្មោល ហើយវាចូលចិត្តពន្លឺភ្លើង ។ វាអាចហើរបានឆ្ងាយ ជាធម្មតារហូតដល់២គម ហើយមេមួយអាចពងបានប្រហែល ២០០ ទៅ ៣០០ ពង ក្នុងរយៈពេល ៤ថ្ងៃ ។មេអំបៅដង្កូវស៊ីរូងដើមពណ៌លឿងមេមានទំហំធំជាងឈ្មោល ដែលឈ្មោលមានពណ៌ត្នោតខ្ចី មាន ចំណុចខ្មៅតូចនៅលើស្លាបម្ខាងមួយ និងមានស្នាមអុចឆ្នូតៗចំនួន ៥ នៅគល់ស្លាប និង៨ ទៅ៩ នៅខាងចុងស្លាប ។ ចំណែកមេអំបៅញីមានពណ៌ចំបើង និងមានចំណុចខ្មៅចំកណ្តាលស្លាបម្ខាងមួយ ។ មេអំបៅដង្កូវស៊ីរូងដើមក្បាលខ្មៅ និងឆ្នូតមានភាពប្រហាក់ប្រហែលគ្នា ដោយមានពណ៌ចំបើង ទៅត្នោតស្រាល និងមានចំណុចពណ៌ប្រាក់នៅលើផ្ទៃស្លាប និងចំណុចខ្មៅតូចៗនៅខាងចុងស្លាប ។ ពងវាមានពណ៌លឿងភ្លឺរលោងនៅរាយប៉ាយ ឬផ្តុំគ្នាជាសំបុកពី២០០ ទៅ ៣០០ នៅផ្នែកខាង លើផ្ទៃស្លឹក និងនៅស្រទាប់ស្លឹកស្រូវ ទៅតាមប្រភេទរបស់វា ។





ដង្កូវស៊ីរូងដើមពណ៌លឿងមានពណ៌លឿង ក្បាលវាពណ៌ទឹកក្រូច និងចូលស៊ីតែមួយក្នុងមួយដើម ។ ដង្កូវស៊ីរូងដើមឆ្នូតមានឆ្នូត៥តាមបណ្តោយដងខ្លួន ក្បាលវាពណ៌ត្នោត ។ ដង្កូវស៊ីរូងដើមក្បាល ខ្មៅមានឆ្នូត៥តាម បណ្តោយដងខ្លួន ក្បាលវាពណ៌ខ្មៅ ។ ដង្កូវស៊ីរូងដើមឆ្នូត និងក្បាលខ្មៅ ចូលស៊ីក្នុង មួយដើមពី២-៥ ដង្កូវ ។ ដង្កូវញាស់ថ្មីៗផ្លាស់ទីទៅកាន់ដើមឬគុម្ពផ្សេងទៀត តាមរយៈសរសៃសូត្ររបស់វា ។ នៅពេលដង្កូវនៅតូច វាស៊ីនៅត្រង់ចន្លោះដើម និងស្រទាប់ស្លឹក ក្នុងរយៈពេល ២ -៣ថ្ងៃ មុនពេលវាចូលទៅក្នុងដើម ។ ដង្កូវចំណាស់ស៊ីនៅក្នុងដើមនៅជិតគល់ ហើយវាអាចស៊ីរូងចូលទៅក្រោមផ្ទៃដី នៅពេលដែល វាជិតក្លាយជាដឹកឌឿ ឬល័ក្ខខណ្ឌមិនសមស្របសម្រាប់វា ។



ដង្កូវក្លាយជាដឹកឌឿក្នុងដើមស្រូវនៅជិតគល់ ឬក្រោមផ្ទៃដី២-៣ សម ។ មេអំបៅញាស់ពីសំបុកដឹកឌឿ រួចហើរចេញពីក្នុងដើមស្រូវតាមរន្ធដែលបានចោះទុក កាលវានៅជាដង្កូវ ។

## ការស៊ីបំផ្លាញ

វាស៊ីបំផ្លាញស្រូវ ដោយដង្កូវវាស៊ីរូងនៅក្នុងដើមស្រូវ ដែលអាចកាត់ផ្តាច់ចលនារបស់ទឹក និងជីជាតិ ។ វាបំផ្លាញស្រូវចាប់ពីដំណាក់កាលសំណាបរហូតដល់ស្រូវចេញផ្កា ។ ស្រូវស្វិតបណ្តូល នៅពេលដែលវាបំផ្លាញមុនពេលកកើតកួរ បណ្តូលដែលខូចខាតដោយសារដង្កូវស៊ីរូងដើម(ងាប់បណ្តូល) ងាយក្នុងការដកហូតចេញពីដើម ។ ជួនកាលនៅផ្នែកត្រង់គល់នៃស្លឹកដែលដកចេញមកគេសង្កេតឃើញមានកំទេច កំទី និងអាចម៍ដង្កូវ។ នៅពេលដែលវាបំផ្លាញក្រោយពេលកកើតកួរ គេសង្កេតឃើញកួរស ដែលបង្ហាញថាកួរស្រូវស្កុកខូច។





## វិធានការការពារ និងកម្ចាត់

គេអាចការពារ និងកំចាត់វាដោយ :

- សំអាតស្មៅជុំវិញស្រែ
- ភ្ជួរស្រែបន្ទាប់ពីប្រមូលផល
- ដាំដុះឲ្យស្របពេលគ្នា
- កុំប្រើជីអាសូតច្រើនពេក ត្រូវប្រើឲ្យបានច្រើនដង
- ប្រើពូជធន់
- ប្រមូលសំបុកពងយកមកកម្ទេចចោល
- ថែរក្សាការពារសត្វមានប្រយោជន៍
- ប្រើថ្នាំបាស៊ីដីន ១៥ ទៅ ២០ គីឡូក្រាម ទ្រាប់បាតមុនស្ទូង ។

## ៧. មូសផ្លុងលើដំណាំស្រូវ

មូសផ្លុងជាសត្វល្អិតដែលមានរូបរាងតូច ដូចសត្វមូសធម្មតាដែរ។ ចំពោះមូសផ្លុងឈ្មោលពេញវ័យ ខ្លួនរបស់វាមានពណ៌លឿងត្នោត និងមានខ្លួនតូចជាងមូសផ្លុងញី ដែលមានពោះពណ៌ក្រហម។ នៅពេលភ្លៀងចាប់ផ្តើមធ្លាក់នាដើមរដូវវស្សា មូសផ្លុងពេញវ័យហើរចេញពីស្មៅចង្រៃមករកជម្រកថ្មីដែលមានចំណី និង អាចបន្តពូជបាន។ ចំពោះមូសផ្លុងញីនិមួយៗអាចពងបានពី ១-៨ពង នៅលើស្លឹកស្រូវ និងមានជីវិតត្រឹមតែ ៤ - ៥ ថ្ងៃប៉ុណ្ណោះ ប៉ុន្តែចាប់ពីពេលពេញវ័យរហូតដល់ងាប់ទៅវិញវាអាចពងបានរាប់រយងណោះ។ ដង្កូវមូសផ្លុងដែលញាស់ចេញពីពង មានព ណ៌សស្រអាប់ ហើយ ចូលលាក់ខ្លួននៅក្នុងដើមស្រូវ និងស៊ីបំផ្លាញគល់នៃបណ្តូលស្រូវ ដែលជាហេតុធ្វើឱ្យបណ្តូលស្រូវចេញមកមូលដូចផ្លុង និងពុំអាចចេញកួរការបំផ្លាញរបស់វាមានចាប់តាំងពីនៅថ្នាលសំណាបរហូតដល់ចុងបញ្ចប់ នៃដំណាក់កាលបែកគុម្ព ។





នៅក្នុងប្រទេសកម្ពុជាយើង មូសផ្លុង មិនត្រូវបានគេចាត់ទុកជាសត្វល្អិតចង្រៃធ្ងន់ធ្ងរទេ។ មានខេត្តមួយចំនួន ដែល ទទួលរងនូវការបំផ្លិចបំផ្លាញគួរឱ្យកត់សំគាល់នោះមានដូចជាខេត្ត ស្វាយរៀង ព្រៃវែង កំពត និង កំពង់ចាម។

## ២-វិធានការការពារ



*ការបំផ្លាញរុក្ខជាតិទាំងឡាយជាជម្រក* : ធ្វើការកាប់ឆ្ការសំអាតស្មៅចង្រៃ ឬ ស្រងែ ដែលនៅជុំវិញបរិវេណស្រែ និងក្នុងស្រែ នៅពេលដាំដុះ និងក្រោយពេល ប្រមូលផល។

*ភ្ជួរស្រែបន្ទាប់ពីប្រមូលផល* : ធ្វើដីឱ្យស្អាតល្អកុំឱ្យមានរុក្ខជាតិជម្រក បន្ទាប់ពីច្រូតកាត់រួច។



*ពេលវេលាដាំដុះ* : ត្រូវពន្យាពេលដាំដុះក្នុងរដូវវស្សាឱ្យបានសមស្រប បើអាចធ្វើទៅបាន គឺធ្វើលើពូជស្រូវប្រកាន់រដូវ ដើម្បីកាត់បន្ថយវគ្គលូតលាស់ របស់ស្រូវឱ្យនៅខ្លី។ ផ្ទុយទៅវិញ ធ្វើការដាំដុះពូជស្រូវមិនប្រកាន់រដូវ ឱ្យបាន ឆាប់រហ័សនៅពេលដើមរដូវវស្សា ដើម្បីឱ្យដំណាំស្រូវបានបញ្ចប់វគ្គលូតលាស់ មុនពេលមូសផ្លុងផ្លាស់ទីមកពីរុក្ខជាតិជម្រកជាការប្រសើរ។

*ជៀសវាងការដាំដុះបន្តបន្ទាប់គ្នាឥតដាច់:* ត្រូវដាំដុះកុំឱ្យយឺតជាងស្រែជិតខាង ៣សប្តាហ៍។

*ការដាក់ជី:* ការប្រើប្រាស់ជីអ៊ុយរ៉េក្នុងកម្រិតមធ្យម ហើយត្រូវបាចវាបីលើក (ដំណាក់កាលសំណាប , បែកគុម្ព និងកំណកំណើតកួរ ) ជាវិធីដ៏ល្អក្នុងការការពារជាមួយមូសផ្លុង ដែលមានការបំផ្លាញ និងរាតត្បាត ។

*ដំណាំបង្វិល:* ការដាំស្រូវបន្តគ្នារហូត អាចធ្វើឱ្យប្រជាកររបស់មូសផ្លុងកើនឡើង។ ផ្ទុយទៅវិញការ ទុកដីស្រែនៅទំនេរ ឬការអនុវត្ត ន៍ការដាំដំណាំបង្វិលដោយការថែទាំមិនឱ្យមានស្មៅ អាចកាត់បន្ថយប្រជាករ មូសផ្លុងបានដែរ។

*ការប្រើប្រាស់ពូជធន់* : ការដាំដុះពូជធន់ គឺជាវិធានការមួយប្រកបដោយប្រសិទ្ធភាពល្អបំផុតក្នុងការ ការពារពីការបំផ្លាញរបស់មូសផ្លុង។ ការពិសោធន៍តាមដានពូជស្រូវធន់ទ្រាំទៅនឹងការបំផ្លាញរបស់មូសផ្លុង កំពុងតែប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជា។ តាមលទ្ធផលពិសោធន៍ដំបូងខាងលើនេះ គឺមានពូជប្រពៃណីកម្ពុជា មួយចំនួនដូចជា ***ឈុត្តនា នាងមិញ*** និង ***សូម៉ាលី*** ហើយនិងពូជស្រូវទំនើបដូចជា **អ៊ីអ៊ែរ៦៦ អ៊ីអ៊ែរ៤២** មាន ភាពធន់ទៅនឹងការបំផ្លាញរបស់មូសផ្លុង។

## ៣-ការកម្ចាត់

ការបាញ់ថ្នាំសម្លាប់សត្វល្អិតប្រភេទពុលខ្លាំង ដើម្បី កម្ចាត់ប្រភេទសត្វល្អិតចង្រៃណាមួយ អាចធ្វើឱ្យ មានការរាតត្បាតដោយមូសផ្លុងកាន់តែខ្លាំងឡើងថែមទៀត ។ ថ្នាំនោះបានសម្លាប់ពពួកសត្វល្អិត មានប្រយោជន៍ ដូចជា ពីងពាង ពួក ឪម៉ាល់ និង ប៉ារ៉ាស៊ីត ដែលជាសត្រូវធម្មជាតិស ម្រាប់ការសម្លាប់ មូសផ្លុង ។ ការ កម្ចាត់ មូសផ្លុងដោយប្រើថ្នាំសម្លាប់សត្វល្អិតមានការលំបាកជាទីបំផុត ព្រោះដង្កូវមូស

ផ្លុងរស់នៅក្នុងដើមស្រូវ ។ ប្រភេទថ្នាំសម្លាប់សត្វល្អិតជ្រាបចូល ដែលមានប្រសិទ្ធិភាពខ្ពស់ក្នុងការក ម្ចាត់មូសផ្លុងនោះ គឺមានតែថ្នាំ រីជែន ឬ ហ្វីប្រូនីលមួយគត់នៅក្នុងប្រទេសកម្ពុជា។ ថ្នាំនេះមានទម្រង់ពីរយ៉ាង មួយជាគ្រាប់ និងមួយទៀតជាទឹក។ ថ្នាំហ្វីប្រូនីលទម្រង់ជាគ្រាប់មានប្រសិទ្ធិភាពខ្ពស់ក្នុងការក ម្ចាត់មូសផ្លុងជាងប្រភេទថ្នាំទឹក បើសិនជានៅក្នុងស្រែ នោះមានទឹកជាអចិន្ត្រៃយ៍។ ការប្រើថ្នាំគ្រាប់ហ្វីប្រូនីលលើថ្នាលសំណាបមុននឹងយកទៅស្ទូង ក្នុងរយៈពេលពី ១ ទៅ ២ សប្តាហ៍អាចការពារការបំផ្លាញធ្ងន់ធ្ងរពីមូសផ្លុងបាន ។ សរុបមក មុនពេលស ម្រេចចិត្តប្រើប្រាស់ថ្នាំគីមីនេះ ត្រូវគិតទៅដល់សេដ្ឋកិច្ច បរិស្ថាន និងសុខភាព ជាមុនសិនថាតើគួរប្រើ ឬមិនគួរ ហើយត្រូវកំណត់ ឲ្យបានច្បាស់ជៀសវាង ការប្រើទាំងប្រថុយប្រថាន។

## ៨. ស្រឹងជញ្ជក់ទឹកដោះស្រូវ

មេស្រឹងរាងមូរទ្រវែង ពណ៌ត្នោតបៃតង និងមានក្លិនឆ្អេះ ។ ពងវារាងមូរដូចគ្រាប់អង្គុញ រាយជាជួរៗ នៅលើផ្ទៃស្លឹក ។ កូនស្រឹងដែលទើបនឹងញាស់ មានពណ៌បៃតង ។

វាជញ្ជក់គ្រាប់ស្រូវតាមចន្លោះថ្នេរនៃគ្រាប់ ។ វាជញ្ជក់យកទឹកដោះគ្រាប់ស្រូវ ធ្វើឲ្យគ្រាប់ស្រូវដាក់គ្រាប់មិនពេញស្កៀត នៅពេលដែលគ្រាប់ស្រូវចាប់ផ្តើមដាក់ម្សៅ ស្រឹងពុំអាចជញ្ជក់បានទេ ។

ការការពារ និងកំចាត់

- ដាំដុះឲ្យស្របពេលគ្នា
- បំបាត់ជម្រកនៅក្នុង និងជុំវិញស្រែ
- ប្រើថ្នាំ Pestop, Apolo 25 WP





## ៩. ការគ្រប់គ្រងកណ្តុរ



សត្វកណ្តុរដែលប្រទះឃើញសំបូរជាងគេនៅស្រែកសិករ ក្នុងតំបន់វាល ទំនាបនៃប្រទេសកម្ពុជា រួមមានពួកកណ្តុរប្រែង (កណ្តុរធំ) និងពួកកណ្តុរ ស្រែ (កណ្តុរបាយ)។ សត្វកណ្តុរបានបំផ្លាញផលិតផលដំណាំកសិករ តាម រូបភាព២យ៉ាង គឺការបំផ្លាញរបស់វានៅលើស្រែផ្ទាល់ និងការបំផ្លាញ ផលិតផលស្តុក ។ ជារៀងរាល់ឆ្នាំនៅប្រទេសកម្ពុជាយើង កសិករតែងតែ ជួបប្រទះនូវការបាត់បង់ទិន្នផលយ៉ាងសន្ធឹកសន្ធាប់ ពីពពួកសត្វកកេរជា ពិសេស

គឺសត្វកណ្ដុរ។ ការសិក្សាស្វែងយល់ពីលក្ខណៈជីវសាស្ត្រនៃសត្វកណ្ដុរ ជាចំណុចដំបូងសម្រាប់ធ្វើការរៀបចំយុទ្ធសាស្ត្រផ្សេងៗ ដើម្បីធ្វើ ឲ្យការគ្រប់គ្រងសត្វកណ្ដុរ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព។

## លក្ខណៈពិសេសផ្សេងៗនៃសត្វកណ្ដុរស្រែ

- ចំណីរបស់សត្វកណ្ដុរគឺស្រូវ សត្វល្អិត ស្មៅ បន្លែ ផ្លែឈើ និងសត្វផ្សេងៗមួយចំនួនទៀត
- សត្វកណ្ដុរចូលចិត្តកកេរដើម្បីរក្សាធ្មេញវាកុំឱ្យដុះលូតលាស់ខ្លាំង និងមុតល្អ
- ចក្ខុវិញ្ញាណរបស់សត្វកណ្ដុរខ្សោយ តែពុកមាត់របស់វាអាចប្រើជំនួសភ្នែកវាបាន
- កណ្ដុរចូលចិត្តរស់នៅជាហ្វូង ជាក្រុមទៅតាមប្រភេទរបស់វា និងធ្វើសកម្មភាពនៅពេលយប់
- សត្វកណ្ដុរបំផ្លាញដំណាំស្រូវនៅគ្រប់ដំណាក់កាលទាំងអស់។



## ជម្រកសត្វកណ្ដុរ

- សត្វកណ្ដុរធ្វើរន្ធក្នុងដី នៅតាមភ្លឺស្រែ ក្នុងគុម្ពព្រៃដីទួល
- សត្វកណ្ដុរធ្វើសំបុកនៅលើមែកឈើ
- សត្វកណ្ដុរធ្វើសំបុកនៅតាមអាគារចាស់ៗ
- សត្វកណ្ដុរធ្វើសំបុកនៅតាមគេហដ្ឋានរស់នៅ។

## កត្តាកំណត់ប្រជាករនៃសត្វកណ្ដុរក្នុងតំបន់

- ការកកើតនៃសត្វកណ្ដុរ
- អត្រានៃការស្លាប់របស់សត្វកណ្ដុរ
- ការហូរចូលរបស់សត្វកណ្ដុរពីតំបន់ផ្សេង
- ការចល័តចេញរបស់សត្វកណ្ដុរពីតំបន់




## ស្នាមបំផ្លាញរបស់សត្វកណ្ដុរលើដំណាំស្រូវ



Fig 3. Missing hills during the seedling stage
Fig 4. Cut tillers during the panicle stage.
Fig 5. Damage during maturing stage
Fig 5. Damage during maturing stage

## ការកកើតនៃសត្វកណ្ដុរតាមដំណាក់កាលដំណាំស្រូវ




➤សត្វកណ្ដុរចាប់ផ្ដើមធ្វើការបង្កកំណើតជាបន្តបន្ទាប់ចាប់ពីស្រូវបែកគុម្ពអតិបរមា រហូតដល់ពេលប្រមូលផល។

➤ការបន្តពូជអាចធ្វើឡើង៣លើកក្នុងមួយរដូវដាំដុះដំណាំស្រូវ

➤កណ្ដុរស្រែបង្កកំណើតចាប់ពីខែសីហា ដល់មិថុនា។ អត្រាបង្កកំណើតកើនឡើងខ្ពស់ក្នុងចន្លោះខែ សីហា និងកុម្ភៈ។

➤ជាការប្រសើរត្រូវធ្វើការកម្ចាត់សត្វកណ្ដុរនៅមុនពេលកណ្ដុរ

កកើតកូនចំនួនច្រើន(មុនពេលមានការបំផ្លាញ ដំណាំស្រូវ)

## កំណើននៃសត្វកណ្ដុរ




- ➢សត្វកណ្ដុរញីអាចកូនក្នុងមួយដងបានចំនួនជាមធ្យមពី៦-៨
- ➢សត្វកណ្ដុរញីមួយអាចកើតកូនជាមធ្យម ៣-៤ ដង ក្នុង១ឆ្នាំ
- ➢លទ្ធភាពនៃការបង្កើតកូនអាស្រ័យលើបរិមាណនៃចំណីអាហារ ដែលស្ថិតនៅតាមកន្លែងរស់នៅនៃសត្វកណ្ដុរ និងល័ក្ខខ័ណ្ឌបរិស្ថានរបស់វា
- ➢ រយៈពេល ១០ខែ សត្វកណ្ដុរញីមួយអាចកើតកូនចៅជាបន្តបន្ទាប់បានចំនួន ៥១០ កណ្ដុរជាមធ្យម។

## វដ្ដជីវិតនៃសត្វកណ្ដុរ




- កណ្ដុរស្រែអាចរស់បានរយៈពេលជាមធ្យមពី ៦ខែ ទៅជាង ១ឆ្នាំ
- សត្វកណ្ដុរពេញវ័យនៅអាយុ៣ខែ ហើយអាចចាប់ផ្ដើមធ្វើការបង្កកំណើតបាន
- ក្រោយពីកណ្ដុរកើតកូនភ្លាម វាអាចបន្តការបង្កកំណើតតទៅទៀតបាន
- សត្វកណ្ដុរឈ្មោល ២ -៣ អាចធ្វើការបង្កកំណើតជាមួយ កណ្ដុរញីរាប់រយនៅក្នុងតំបន់តែមួយ
- សត្វកណ្ដុរធើមក្នុងរយៈពេល ២១ថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលវាធ្វើការបង្កកំណើតជាមួយសត្វកណ្ដុរឈ្មោល។

ការគ្រប់គ្រងកណ្ដុរស្រែដោយ អង្គប់ទ្រុងធី -ប៊ី-អេស ជាវិធីសាស្ត្រការពារដំណាំស្រូវប្រឆាំងនឹងកណ្ដុរស្រែ ដែលមានលក្ខណៈជាប្រពន្ធ័មួយរួមមាន របាំង ប្លាស្ទិច អង្គប់ និងដំណាំផ្ទាក់ ។ ម្យ៉ាងទៀតវិធីសាស្ត្រនេះ គឺជាការគ្រប់គ្រងដែលទាមទារការចូលរួមពីសហគមន៍។




វិធីសាស្ត្រនេះផ្ដល់ផលប្រយោជន៍រួម ដល់សហគមន៍ទាំងមូល ក្នុងតំបន់គោលដៅមួយ ។ ប្រសិទ្ធិភាពនៃវិធីសាស្ត្រនេះ គឺវាអាស្រ័យលើការចូលរួមរបស់កសិករ ក្នុងសហគមន៍ ។ ពីព្រោះវាជាការចូលរួមចំណែកក្នុងការ រៀបចំសម្ភារៈ ការរៀបចំកូនស្រែ និងការត្រួតពិនិត្យថែទាំកូនស្រែ។ ហេតុដូចនេះ

នៅក្នុងការអនុវត្តន៍ការងារ តម្រូវ ឲ្យមានការចូលរួមយ៉ាងសកម្ម ពីកសិករនៅក្នុង សហគមន៍ ទាំងផ្នែកសម្ភារៈ និងកម្លាំង ពលកម្ម។

### *សារៈប្រយោជន៍នៃការចូលរួមរបស់កសិករក្នុងសហគមន៍*

- វិភាគទានរបស់កសិករនៅក្នុងការអនុវត្តន៍ការងារ ទាំង ផ្នែកសម្ភារៈ និងកម្លាំងពលកម្ម
- បង្កើនប្រសិទ្ធិភាព និងនិរន្តរភាពនៃការគ្រប់គ្រង
- បង្កើនស្មារតីទទួលខុសត្រូវ និងសាមគ្គីភាព
- កាត់បន្ថយនៅក្នុងការចំណាយលើការអនុវត្តន៍ការងារផ្សេងៗ



### *ការរៀបចំផែនការការងារអនុវត្តន៍លើស្រែកសិករ*

នៅដើមរដូវដាំដុះ (មុនពេលចាប់ផ្តើមដាំដុះ) តំណាងកសិករតាមភូមិនិមួយៗ ដែលទទួលរងពីការបំផ្លាញរបស់សត្វកណ្តុរ និងអាជ្ញាធរមូលដ្ឋាន ត្រូវធ្វើការប្រជុំរៀបចំផែនការសកម្មភាពការងារក្នុងការគ្រប់គ្រងសត្វកណ្តុរនៅតាមតំបន់របស់ខ្លួន។ ផែនការការងារដែលត្រូវលើកយកមកពិភាក្សានេះរួមមាន :



- កំណត់ទីតាំងទទួលរងការបំផ្លាញពីសត្វកណ្តុរ
- ជ្រើសរើសទីតាំងសម្រាប់រៀបចំកូនស្រែ ធី-ប៊ី-អេស
- កំណត់វិធីសាស្ត្រសមស្របក្នុងការជ្រើសរើស និងការរៀបចំក្រុមកសិករជាសមាជិក
- ធ្វើឲ្យមានការឯកភាពក្នុងក្រុមកសិករ និងរៀបចំផែនការសកម្មភាពក្នុងការរៀបចំក្រុម។



### ការអនុវត្តន៍ការងាររបស់ក្រុមកសិករ

ការងារសំខាន់ៗដែលកសិករត្រូវចូលរួមមាន:



- **ការរៀបចំកូនស្រែ ធី -ប៊ី-អេស ៖** ម្ចាស់កូនស្រែ ធី -ប៊ី-អេស ជាអ្នករៀបចំសំណាបសម្រាប់ស្ទូង និងរៀបចំសម្ភារៈបច្ចេកទេស ។ សមាជិក ក្រុមជាអ្នកជួយសម្រួលបន្ថែមដល់ការងាររបស់ម្ចាស់កូនស្រែ។
- **ការរៀបចំសម្ភារៈ ធី -ប៊ី-អេស :** សមាជិកក្រុមទាំងអស់ត្រូវចូលរួមក្នុងការ ចំណាយលើសម្ភារៈ ធី -ប៊ី-អេស ការតំឡើងអង្គប់ ដេររបាំងប្លាស្ទិច ក្រោមការដឹកនាំរបស់ប្រធានក្រុម។
- **ការតំឡើងសម្ភារៈក្នុងកូនស្រែ :** ក្រោយពេលស្ទូងកូនស្រែ អន្ទាក់បានពីរសប្តាហ៍សមាជិកក្រុម ត្រូវយក

ឧបករណ៍ដែលបានរៀបចំទៅតំឡើងក្នុងកូនស្រែ។

- **ការថែទាំ និងតាមដានកូនស្រែធី -ប៊ី-អេស :** សមាជិកក្នុងក្រុម ត្រូវផ្លាស់វេនគ្នា ដើម្បីធ្វើការត្រួតពិនិត្យ និងថែទាំកូនស្រែ ជាប្រចាំថ្ងៃ គឺនៅពេលព្រឹក និងពេលរសៀល។ សម្ភារៈខូចខាតត្រូវ ធ្វើការជួសជុលជាបន្ទាន់ ដើម្បីកុំ ឱ្យកូនស្រែរងការបំផ្លាញពីសត្វកណ្តុរ។
- **ការប្រមូលទិន្នន័យ:** សមាជិកក្នុងក្រុមត្រូវធ្វើការកត់ ត្រានូវចំនួនសត្វកណ្តុរ ការបំផ្លាញពីសត្វកណ្តុរលើស្រែ ជុំវិញ រួមទាំងខាងក្នុងកូនស្រែធី -ប៊ី-អេស និងចំណុចកត់សម្គាល់ផ្សេងៗ ដោយមានជំនួយពីអ្នកបច្ចេកទេស។

## ការវាយតម្លៃ និងការឆ្លុះបញ្ចាំងពីក្រុមកសិករ

ក្រោយពីបញ្ចប់ការងារគ្រប់គ្រងសត្វកណ្តុរ ដោយប្រើប្រាស់ធី-ប៊ី-អេស រួចរាល់ ក្រុមកសិករត្រូវចូលរួមប្រជុំដើម្បីធ្វើការវាយតម្លៃពីសកម្មភាពការងារ ដែលខ្លួនបានអនុវត្តកន្លងមក។ ការវាយតម្លៃនេះផ្តោតទៅលើចំណុចសំខាន់ ២ គឺ ការវាយតម្លៃពីការចូលរួមរបស់កសិករ និងប្រសិទ្ធិភាពនៃធី -ប៊ី-អេស ក្នុងការគ្រប់គ្រងសត្វកណ្តុរ ។ លក្ខណៈវិនិច្ឆ័យសំខាន់ៗ សម្រាប់ធ្វើការវាយតម្លៃនេះរួមមាន:

- កំណត់បញ្ហាជាអទិភាពលើការអនុវត្តន៍ ធី-ប៊ី-អេស
- សក្តានុពលលើការអនុវត្តន៍ការងារ ជាលក្ខណៈសហគមន៍
- រិះរកដំណោះស្រាយលើបញ្ហាដែលជាអទិភាព និងធ្វើការកែ លម្អនូវចំណុចអវិជ្ជមានទាំងឡាយ ទាំងការចូលរួមរបស់ កសិករ និងបច្ចេកទេស។

# ជំងឺលើដំណាំស្រូវ

ជាទូទៅយើងដឹងថាស្រូវមានជំងឺ ដោយសាររូបភាពខាងក្រៅផ្លាស់ប្តូខុសពីធម្មតា ។ សញ្ញាប្រែប្រួលខាងក្រៅ និងប្រតិកម្មខាងក្នុងស្រូវ ដែលបង្កឱ្យមានភាពប្រែប្រួលនោះ គឺគេហៅថា" រោគសញ្ញា " នៃជំងឺ ។

ជាទូទៅ សញ្ញាប្រែប្រួលខាងក្រៅរបស់ស្រូវ អាចបញ្ជាក់ពីលក្ខណៈនៃប្រភេទជំងឺរបស់វាបាន ។ ប៉ុន្តែការកំណត់តាមរយៈការមើលនឹងភ្នែក វាមិនប្រាកដដល់ទៅ ១០០ ភាគរយនោះទេ ។ វាអាចយកជាការបានប្រសិនបើ យើងមានបទពិសោធន៍ខ្ពស់ ឬមានការតាមដានទៅលើរោគសញ្ញា របស់វាឱ្យបានច្បាស់លាស់ត្រឹមត្រូវ ។

ជំងឺដែលបង្កឡើងដោយភ្នាក់ងារមានជីវិតដូចជា បង្កឡើងដោយពពួកផ្សិត បាក់តេរី វីរុស និងពពួកណេម៉ាតូត មានរោគសញ្ញាផ្សេងៗដូចជា រលួយគ្រាប់ រលាកស្រទបស្លឹក រលួយស្រទបស្លឹក រលួយគល់ រលួយឫស ក្រិន ដើមបែកច្រើនខុសពីធម្មតាតែគ្មានចេញកួរ រួញស្លឹកខ្លោចស្លឹក តឿដើម ថ្នាំងរេញៗ ឆ្នូតស្លឹក អុចគ្រាប់ អុចស្លឹក ក្រហមស្លឹក ប្រផេះស្លឹក ដើមធំខុសពីធម្មតា ស្រពោនស្លឹក លឿងស្លឹក ផ្ទុះគ្រាប់ តឿរួញស្លឹក ការបែកគុម្ពស្រូវ ថយចុះ រលួយបណ្តូលជាដើម ។

ជំងឺបង្កឡើងដោយភ្នាក់ងារគ្មានជីវិតដល់ដំណាំស្រូវ គឺ សីតុណ្ហភាព សំណើម ទឹកភ្លៀង ខ្យល់ ដី ការខ្វះ ឬ ការលើសសារធាតុចិញ្ចឹម ។ ជំងឺប្រភេទនេះមិនឆ្លងពីរុក្ខជាតិមួយទៅរុក្ខជាតិមួយ ឬពីតំបន់មួយទៅតំបន់មួយ ទៀតនោះទេ ។ រោគសញ្ញាសំគាល់នៃជំងឺទាំងនោះដូចជា ដំណុះគ្រាប់ខ្សោយ លូតលាស់ខ្សោយ សំណាបមាន ការប្រែពណ៌ សរីរាង្គលូតលាសមានលក្ខណៈក្រិន វាបន្ថយកម្ពស់ និងទំហំដើម ការចេញកួរមិនពេញលេញពន្យា ពេលចេញផ្កា បង្កើនចំនួនគ្រាប់ស្កក បែកគុម្ពតិច ស្រូវបង្កើនទម្ងន់ស្លឹក ដើមស្រូវដួល ការបន្តពូជពុំមានដំណើរការល្អ ។

### ១. ជំងឺអុចត្នោត

ជំងឺអុចត្នោតកើតនៅលើស្លឹក និងគ្រាប់ស្រូវ មានស្នាមអុចតូចៗព័ណ៌ត្នោត។ ជាជំងឺដែលបង្ក ឡើងដោយផ្សិត និងច្រើនកើតនៅស្រែដែលខ្វះជាតិអាសូត និងគ្មានទឹក ។ ជំងឺនេះ ជាជំងឺមួយមិនសូវបង្កឲ្យធ្ងន់ធ្ងរដល់ដំណាំស្រូវទេ ។



វិធានការការពារ និងកំចាត់

- ប្រើប្រាស់បរិមាណជីឲ្យបានសមស្រប និងមានតល្យភាពគ្នា
- កុំទុកឲ្យស្រែស្ងួតរយៈពេលយូរពេក
- កុំប្រើប្រាស់គ្រាប់ស្រូវមានជំងឺ សម្រាប់ធ្វើពូជ
- សម្អាត ឬព្យាបាលគ្រាប់ពូជ មុននឹងធ្វើការដាំដុះ
    - ត្រាំទឹកក្តៅ៥០អង្សាសេ
    - ហាលថ្ងៃ
    - ប្រឡាក់ជាមួយថ្នាំផ្សិត

## ២. ជំងឺប្លាស

ជំងឺប្លាសកើតនៅលើស្លឹក ដើមនិងកួរស្រូវ ។ មានស្នាមអុចព័ណ៌ត្នោតខ្ចីជុំវិញ និងព័ណ៌ត្នោតចំ កណ្តាល ។ ជាជំងឺដែលបង្កឡើងដោយផ្សិត ដែលច្រើនកើតនៅស្រែដែលលើសជាតិអាសូត និងជា ជំងឺបង្កឲ្យបាត់បង់ទិន្នផលធ្ងន់ធ្ងរ ។



វិធានការការពារ និងកំចាត់

- ប្រើប្រាស់បរិមាណជីឲ្យបានសមស្រប និងមានតុល្យភាពគ្នា ត្រូវបន្ថយការប្រើប្រាស់ជីអាសូត
- កុំទុកឲ្យស្រែស្ងួតរយៈពេលយូរពេក
- កុំប្រើប្រាស់គ្រាប់ស្រូវមានជំងឺ សម្រាប់ធ្វើពូជ
    - សម្អាត ឬព្យាបាលគ្រាប់ពូជ មុននឹងធ្វើការដាំដុះ ត្រាំទឹកក្តៅ៥០អង្សាសេ
    - ហាលថ្ងៃ
    - ប្រឡាក់ជាមួយថ្នាំផ្សិត
- បាញ់ថ្នាំ probenazole, tricyclazole, pyroquilon, Fuji-one 40WP, Mancozeb

## ៣. ជំងឺរលាកស្រទបស្លឹកស្រូវ



គឺជាជំងឺស្រូវម៉្យាង ដែលបង្កឡើងដោយភ្នាក់ងារចម្លងរបស់ផ្សិតជាទូទៅ យើងអាចសង្កេតឃើញរោគសញ្ញាណនៃ ជំងឺនេះចាប់ផ្តើមលេចចេញនៅដំណាក់កាលបែកគុម្ព រហូតដល់ដាក់ទឹកដោះ។ ដោយមានស្នាមអុចដាមជាប់ នៅលើស្រទបនៃដើមស្រូវដែលមានទំហំ ១-៣ស.ម រាងជារង្វង់ពងក្រពើ មានពណ៌ប្រផេះនៅលើស្លឹកកួរស្រូវមានស្នាមអុចពណ៌ប្រផេះនៅចំណុចកណ្តាល ហើយនៅគែមនៃចំណុចមានពណ៌ត្នោត។ ជំងឺនេះរាលដាលខ្លាំងនៅពេលអាកាសធាតុក្តៅ និងមានសំណើមខ្ពស់។ មិនតែប៉ុណ្ណោះការប្រើជីអាសូតលើសកម្រិត និងស្ទួង ឬព្រោះមានដង់ស៊ីតេខ្ពស់ គឺជាមូលហេតុធ្វើឲ្យជំងឺមានការរីករាលដាលខ្លាំង។

### វិធានការបង្ការ

១.ក្រោយពេលប្រមូលផលរួចចាំបាច់ត្រូវធ្វើការភ្ជួរដី និងត្រូវធ្វើការដាក់ជីកំប៉ុស្ដិ៍ទ្រាប់បាត ហើយត្រូវធ្វើការដាក់ជីគីមីឱ្យបានត្រឹមត្រូវទៅតាមកម្រិតណែនាំ នៃប្រភេទដី

២.ត្រូវធ្វើការជ្រើសរើសរកពូជដែលមានសុខភាពល្អ (ដោយអុំ, ស្ទៃ ឬ ដោយសូលុស្យុងទឹកអំបិល)

៣.បើសិនជាយើងសង្កេតឃើញមានវត្តមាននៃជំងឺរលាក់ស្រទបនៅលើគ្រាប់ស្រូវ យើងត្រូវធ្វើការប្រឡាក់ថ្នាំពុលកសិកម្ម (ថ្នាំសម្លាប់ផ្សិត) មុនពេលយកទៅសាប ឬព្រោះដោយត្រូវពិគ្រោះជាមួយអ្នកបច្ចេកទេសផ្នែកការពារដំណាំ។

៤.ត្រូវធ្វើការកាត់បន្ថយនូវចំនួនដង់ស៊ីតេដើមស្រូវនៅក្នុងស្រែឱ្យបានសមស្រប និងត្រូវធ្វើការបង្ហូរទឹកចេញពីស្រែនៅដំណាក់កាលបែកគុម្ពអតិបរិមាចំនួន២-៣ថ្ងៃ។

៥.ត្រូវធ្វើការសំអាតស្មៅស្រែជាប្រចាំឲ្យបានស្អាត

៦.បើសិនជាជំងឺនេះមានការរីករាលខ្លាំង ត្រូវធ្វើការដុតជញ្ជ្រាំងក្នុងស្រែនោះចោល តែវិធានការនេះអាចធ្វើឱ្យមានផលប៉ះពាល់ដល់មីក្រូសរីរាង្គ ដែលជាសារធាតុចាំបាច់សម្រាប់ការលូតលាស់របស់រុក្ខជាតិ។

### វិធានការកំចាត់

១.ត្រូវធ្វើការដកចោលជាបន្ទាន់នូវដើមស្រូវណាដែលទទួលរងនូវការបំផ្លាញពីជំងឺរលាកស្រទាប់។

២.ត្រូវធ្វើការបាញ់ថ្នាំពុលកសិកម្មឱ្យស្របតាមការណែនាំរបស់អ្នកបច្ចេកទេសផ្នែកការពារដំណាំ។

## ៤. កង្វះអាសូត

### តួនាទី និងចលភាពនៃអាសូត

អាសូតជំរុញការលូតលាស់យ៉ាងរហ័ស និងបង្កើនទំហំផ្ទៃស្លឹក និងចំនួនកន្សោមផ្កាក្នុងកួរស្រូវ។ ជីអាសូតមានឥទ្ធិពលទៅលើកត្តាទាំងអស់ដែលកំណត់ទៅលើទិន្នផល ។ ពណ៌ស្លឹកដែលជា ចំណុចបង្ហាញមួយនៃស្ថានភាពអាសូតរបស់ដំណាំ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធិនឹងកម្រិតនៃការ ធ្វើរស្មីសំយោគក្នុងស្លឹក និងផលិតកម្មដំណាំ ។ នៅពេលដែលអាសូតក្នុងបរិមាណគ្រប់គ្រាន់ ត្រូវ បានដាក់ទៅលើដំណាំ តម្រូវការសារធាតុផ្សេងទៀត ដូចជាផូស្វ័រ និងប៉ូតាស់មានការកើនឡើង។

### រោគសញ្ញានៃកង្វះសារធាតុអាសូត និងឥទ្ធិពលទៅលើការលូតលាស់

រុក្ខជាតិមានពណ៌លឿងខ្ចី មានលក្ខណៈក្រិន។ ស្លឹកចាស់ ឬរុក្ខជាតិទាំងមូលមានពណ៌បៃតង លឿងខ្ចី ។

### មូលហេតុនៃកង្វះអាសូត

- កម្លាំងផ្គត់ផ្គង់អាសូតរបស់ដីមានកម្រិតទាប
- ការប្រើប្រាស់ជីអាសូតក្នុងបរិមាណមិនគ្រប់គ្រាន់
- ប្រសិទ្ធិភាពទាបក្នុងការប្រើប្រាស់ជីអាសូត(ការបាត់បង់តាមរយៈហើរ អាសូតកម្ម ការដាក់ និងពេលវេលាក្នុងការប្រើប្រាស់ជីមិនត្រឹមត្រូវ ការហូរច្រោះ ឬការហូរចេញ)។

ជាទូទៅ ការផ្គត់ផ្គង់ អាសូតរបស់ដី មិនមានបរិមាណគ្រប់គ្រាន់ ដើម្បីជួយផ្គត់ផ្គង់ទៅដល់ទិន្នផល ដែលមានការកើនឡើងខ្ពស់របស់ពូជស្រូវទំនើបបានឡើយ។ ដូចនេះ កង្វះ អាសូតកើតមានឡើងជាទូទៅនៅក្នុង

តំបន់ដាំដុះដំណាំស្រូវសំខាន់ៗទាំងអស់ ។ ទិន្នផលបានកើនឡើងយ៉ាងខ្ពស់ ឆ្លើយតបទៅនឹងការប្រើប្រាស់ជីអាសូត នៅស្ទើរតែគ្រប់ដីស្រែទំនាបទាំងអស់។

### ការកើតមានឡើងនៃកង្វះអាសូត

- ដីដែលមានផ្ទុកសារធាតុសរីរាង្គតិចក្នុងដី
- ដីដែលមានការផ្គត់ផ្គង់អាសូតដែលមានស្រាប់របស់ដី ក្នុងកម្រិតខ្សោយ (ឧទាហរណ៍ ដី អាស៊ីតស៊ុលហ្វាត ដីប្រៃ ដីកង្វះផូស្វាត ដីតំបន់សើមដែលមានការច្រោះទឹកខ្សោយ)។
- ដីអាល់កាឡាំង និងដីកាល់គែរដែលមានសារធាតុសរីរាង្គតិចនៅក្នុងដី។

### ឥទ្ធិពលនៃការពន្លិចទឹកទៅលើភាពសេរី និងការស្រូបយកអាសូត

ប្រសិនបើពពួកជីអ៊ុយរ៉េ ត្រូវបានភ្ជួរលុបទៅក្នុងស្រទាប់ដីបន្ទាប់ពីការពន្លិចទឹក ជីអាសូតត្រូវបានគ្រាប់ដីស្រូបយកធ្វើឲ្យវាគ្មានចលនាជាបណ្តោះអាសន្នដោយពពួកមីក្រុបក្នុងដី និងគ្រាប់ដី ។ ជាទូទៅ ការបាត់បង់តាមជម្រាបចុះក្រោម មានបរិមាណតិចតួច លើកលែងតែនៅក្នុងដីដែល ខ្សាច់ខ្លាំង។ ជី អ៊ុយរ៉េ ដែលបានបាចបំប៉នត្រូវបានរលាយយ៉ាងរហ័ស (ក្នុងរយៈពេល ២ -៤ ថ្ងៃ ) ហើយងាយនឹង បាត់បង់ណាស់តាមរយៈការបំភាយ។ បន្ទាប់ពីពាក់កណ្តាលនៃដំណាក់កាលបែកគុម្ព នៅពេលប្រព័ន្ធឫសដ៏ក្រាស់ ដែលមានឫសរាក់ៗជាច្រើនត្រូវបានបង្កើតឡើងអត្រាដែលរុក្ខជាតិស្រូបយកជីអាសូត ដែលបានបាចទៅក្នុងទឹកនឹងអាចមានទំហំធំ ដូច្នោះការបាត់បង់តាមរយៈការបំភាយមានកម្រិតតិច តួច។

### ការគ្រប់គ្រងជាតិអាសូត

ការព្យាបាលទៅលើកង្វះអាសូតមានលក្ខណៈងាយស្រួល ហើយការឆ្លើយតបទៅនឹងជី អាសូត មានលក្ខណៈឆាប់រហ័ស។ ការឆ្លើយតបអាចត្រូវបានមើលឃើញបន្ទាប់ពីរយៈពេល ២ -៣ ថ្ងៃ (ប្រែពណ៌ ទៅជាបៃតង ការលូតលាស់មានលក្ខណៈល្អប្រសើរជាងមុន)។ ការគ្រប់គ្រងដោយផ្អែកទៅលើដី និង ទៅលើរុក្ខជាតិ ទាមទារឲ្យមានការបង្កើនប្រសិទ្ធិភាពក្នុងការប្រើប្រាស់អាសូតសម្រាប់រដូវនីមួយៗ ។

## ៥. កង្វះផូស្វ័រ

### តួនាទី និងចលភាពនៃផូស្វ័រ

ផូស្វ័រមានសារៈសំខាន់ណាស់សម្រាប់ការផ្ទុក និងការផ្ទេរថាមពលនៅក្នុងរុក្ខជាតិ។ ផូស្វ័រ មានចលនានៅក្នុងរុក្ខជាតិ ហើយជំរុញការបែកគុម្ព ការអភិវឌ្ឍ ន៍ឫស ការចេញផ្ការហ័ស និង ការទុំ។ ជាពិសេស វាមានសារៈសំខាន់ណាស់នៅក្នុងដំណាក់កាលលូតលាស់ដំបូង។

### រោគសញ្ញានៃកង្វះផូស្វ័រ និង ឥទ្ធិពលទៅលើការលូតលាស់

រុក្ខជាតិតឿមានពណ៌បៃតងក្រមៅដោយមានស្លឹកឈរត្រង់ ហើយកាត់បន្ថយការបែកគុម្ព ។

***មូលហេតុនៃកង្វះ ផូស្វ័រ***

- កម្លាំងផ្គត់ផ្គង់ផូស្វ័រ ដែលមានស្រាប់របស់ដី មានកម្រិតខ្សោយ
- ការប្រើប្រាស់ជីផូស្វ័រ ក្នុងបរិមាណមិនគ្រប់គ្រាន់

- ប្រសិទ្ធិភាពទាបនៃជីផូស្វ័រដែលបានប្រើប្រាស់ ដោយសារតែសមត្ថភាពចាប់យកផូស្វ័រនៅ ក្នុងដី ឬការបាត់បង់តាមរយៈសំណឹក (ចំពោះតែស្រូវចំការតែប៉ុណ្ណោះ) មានកម្រិតខ្ពស់
- ការប្រើប្រាស់ជីអាសូតច្រើនលើសលុប រួមជាមួយការប្រើប្រាស់ជីផូស្វ័រ ក្នុងបរិមាណមិនគ្រប់ គ្រាន់
- ភាពខុសគ្នារបស់ពូជស្រូវ ចំពោះភាពមិនធន់ទ្រាំទៅនឹងកង្វះផូស្វ័រ និងការឆ្លើយតបទៅនឹងជី ដែលមានជាតិផូស្វ័រ
- របៀបដាំដុះដំណាំ (កង្វះផូស្វ័រកើតមានច្រើន ទៅលើដំណាំស្រូវដាំដោយការព្រោះគ្រាប់ ដែលជាកន្លែងដែលដង់ស៊ីតេដំណាំស្រូវមានកម្រិតខ្ពស់ ហើយប្រព័ន្ធឫសស្ថិតនៅរាក់ៗ)។

**ពពួកដីដែលងាយប្រឈមនឹងកង្វះផូស្វ័រ**

- ប្រភេទដីសាច់គ្រើមដែលផ្ទុកបរិមាណសារធាតុសរីរាង្គតិចតួច និងផូស្វ័របម្រុងទុករបស់ដីមាន ចំនួនតិច
- ដីបាស ដីប្រៃ និងដីកាល់គែរ
- ដីភ្នំភ្លើង (ដែលចាប់យកផូស្វ័រយ៉ាងខ្លាំង) ដីមមោក និងដីអាស៊ីតស៊ុលហ្វាត។

**ការកើតឡើងនៃកង្វះផូស្វ័រ**

- ការប្រើប្រាស់ជីអាសូត ឬអាសូត+ប៉ូតាស់ ក្នុងបរិមាណច្រើនលើសលុប ដោយប្រើប្រាស់ជី ផូស្វ័រក្នុងបរិមាណមិនគ្រប់គ្រាន់

**ឥទ្ធិពលនៃការពន្លិចទឹកទៅលើភាពសេរីនិងការស្រូបយកផូស្វ័រ**

- ការពន្លិចទឹកទៅលើដីស្ងួត ធ្វើឲ្យភាពសេរីរបស់ផូស្វ័រមានការកើនឡើង។

**ការគ្រប់គ្រងផូស្វ័រ**

ផូស្វ័រទាមទាឲ្យមានយុទ្ធសាស្ត្រគ្រប់គ្រងក្នុងរយៈពេលយូរអង្វែង ។ ការប្រើប្រាស់ជី ផូស្វ័រ បានបន្សល់ឥទ្ធិពលយូរអង្វែង ដែលអាចមានរយៈពេលជាច្រើនឆ្នាំ ។ ការគ្រប់គ្រងត្រូវតែផ្តោតទៅ លើការបង្កើន និងការថែរក្សាកម្រិតផូស្វ័រសេរីរបស់ដី ឲ្យមានបរិមាណគ្រប់គ្រាន់ ដើម្បីធ្វើឲ្យប្រាកដថាការផ្គត់ផ្គង់ផូស្វ័រមិនបានកម្រិតទៅលើការលូតលាស់ ទិន្នផលគ្រាប់ និងប្រសិទ្ធិភាពនៃការប្រើ ប្រាស់ជី អាសូតឡើយ ។

## ៦. កង្វះប៉ូតាស្យូម

**តួនាទី និងចលភាពនៃប៉ូតាស់ស្យូម**

ប៉ូតាស្យូមមានតួនាទីសំខាន់ណាស់នៅក្នុងកោសិការបស់រុក្ខជាតិ ហើយមានសារៈសំខាន់សម្រាប់ការដឹកជញ្ជូនផលិតផលរស្មីសំយោគ។ មិនដូច អាសូត និងផូស្វ័រទេ ប៉ូតាស្យូមមិនមានឥទ្ធិពលខ្លាំងទៅ លើការបែកគុម្ពឡើយ។ ប៉ូតាស្យូមជួយបង្កើនចំនួនកន្សោមផ្កាក្នុងមួយកួរ ភាគរយនៃគ្រាប់ស្រូវពេញ និងទម្ងន់ ១,០០០ គ្រាប់។

**រោគសញ្ញានៃកង្វះប៉ូតាស្យូម**

រុក្ខជាតិមានពណ៌បៃតងក្រមៅ ដោយគែមស្លឹកមានពណ៌ត្នោតលាយលឿងខ្ចី ឬស្នាមអុចៗពណ៌ត្នោត ក្រមៅលេចឡើងមុនគេនៅខាងចុងស្លឹកចាស់ៗ ។ ការកើតឡើងនូវជំងឺផ្សេងៗ ច្រើននៅកន្លែងដែលគេប្រើប្រាស់ជីអាសូតច្រើនហួសប្រមាណ និងជីផូស្វ័រក្នុងបរិមាណមិនគ្រប់គ្រាន់ ។

### មូលហេតុនៃកង្វះប៉ូតាស្យូម

- សមត្ថភាពផ្គត់ផ្គង់ប៉ូតាស្យូម របស់ដីមានកម្រិតខ្សោយ
- ការប្រើប្រាស់ជីធម្មជាតិក្នុងបរិមាណមិនគ្រប់គ្រាន់
- ការប្រមូលយកចំបើងទាំងអស់ចេញពីស្រែ
- បរិមាណប៉ូតាស្យូមតិចតួច នៅក្នុងទឹកស្រោចស្រព
- ជីប៉ូតាស្យូមដែលត្រូវបានប្រើប្រាស់មានប្រសិទ្ធិភាពស្តារឡើងវិញទាបដោយសារតែសមត្ថភាព ចាប់យកប៉ូតាស្យូមរបស់ដី និងការបាត់បង់ដោយសារការហូរច្រោះមានកម្រិតខ្ពស់

### ការកើតឡើងនៃកង្វះប៉ូតាស្យូម

- ការប្រើប្រាស់ជីអាសូត  ឬអាសូត+ផូស្វ័រក្នុងបរិមាណច្រើនលើសលុប ដោយប្រើប្រាស់ជី ប៉ូតាស្យូមក្នុងបរិមាណមិនគ្រប់គ្រាន់
- នៅលើស្រូវពង្រោះ ក្នុងដំណាក់កាលលូតលាស់ដំបូង នៅពេលដែលប្រជាកររបស់រុក្ខជាតិមានចំនួនច្រើន ហើយប្រព័ន្ធឫសស្ថិតនៅរាក់ៗ
- នៅលើស្រូវអ៊ីប្រ៊ីត ដោយសារតែតម្រូវការដ៏ខ្ពស់ ក្នុងការស្រូបយកប៉ូតាស្យូម ។

### ដីដែលងាយប្រឈមនឹងកង្វះប៉ូតាស្យូម

- ដីល្បាយខ្សាច់ខ្លាំង និងពពួកដីអាស៊ីតដែលមានសមត្ថភាពបណ្តូរកាចុងខ្សោយ ហើយប៉ូតាស្យូមបម្រុងទុកក្នុងដីមាន បរិមាណតិចតួច
- ដីឥដ្ឋតំបន់ទំនាបដែលមានការចាប់យកប៉ូតាស្យូមក្នុងកម្រិតខ្ពស់
- ដីអាស៊ីតស៊ុលហ្វាតចាស់ដែលមានការហូរច្រោះ

### ឥទ្ធិពលនៃការពន្លិចទឹកទៅលើភាពសេរី និងការស្រូបយកប៉ូតាស្យូម

ការពន្លិចទឹកធ្វើឲ្យកំហាប់សូលុយស្យុងប៉ូតាស្យូមមានការកើនឡើង  ហើយបង្កើនការសាយ ភាយប៉ូតាស្យូមឲ្យទៅដល់ឫសស្រូវ ។

### ការគ្រប់គ្រងប៉ូតាស្យូមទូទៅ

ការគ្រប់គ្រងប៉ូតាស្យូម គួរតែត្រូវគិតគូរជាផ្នែកមួយនៃការគ្រប់គ្រងជីជាតិដី  ក្នុងរយៈពេលយូរអង្វែង ។ ពីព្រោះប៉ូតាស្យូមមិនងាយបាត់បង់ក្នុងរយៈពេលខ្លីឡើយ ដែលដំណើរការទាំង នេះមានឥទ្ធិពលទៅការផ្គត់ផ្គង់អាសូត។

## ៧. ការពុលជាតិដែក

ការពុលដែកបណ្តាលមកពីរុក្ខជាតិស្រូបយកធាតុដែកច្រើនពេកពីក្នុងដី ដែលសម្បូរទៅដោយដែករលាយ ។ ការស្រូបយកធាតុដែកច្រើន បណ្តាលឲ្យស្លឹកស្រូវប្រែពណ៌ទៅជាលឿងទុំ។ ការពុលដែកក៏ទាក់ទិនផងដែរទៅនឹងភាពមិនប្រក្រតីនៃសារធាតុចិញ្ចឹមច្រើនមុខ ។

## បុព្វហេតុដែលបណ្តាលឲ្យមានការពុលដែក

ការពុលដែកអាចបណ្តាលមកពីបុព្វហេតុសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- មានកំហាប់អ៊ីយ៉ុងដែកច្រើននៅក្នុងដីបណ្តាលមកពីដីមាន pH ទាប ។
- មានសារធាតុចិញ្ចឹមមិនគ្រប់គ្រាន់ និងគ្មានតុល្យភាពនៃសារធាតុចិញ្ចឹមក្នុងដី។ កង្វះសារធាតុចិញ្ចឹម ផូស្វ័រ កាល់ស្យូម មាញ៉េស្យូម ឬប៉ូតាស្យូម ។
- មានការប្រើប្រាស់កាកសំណល់ធាតុសរីរាង្គជាច្រើន ដែលមិនទាន់រលួយពេញលេញ។
- ការផ្តល់ជាបន្តបន្ទាប់នូវធាតុដែកចូលទៅក្នុងដី តាមរយៈទឹកក្រោមដី ឬការជ្រាបចេញពីភ្នំ។
- ការប្រើប្រាស់ទឹកស្អុយ ឬកាកសំណល់ឧស្សាហកម្មដែលមានផ្ទុកជាតិដែកខ្ពស់។

## រោគសញ្ញានៃការពុលដែក

រោគសញ្ញានៃការពុលដែកនេះ ដំបូងលេចចេញនូវអុចតូចៗ ពណ៌ត្នោតនៅលើផ្ទៃស្លឹកផ្នែកខាងក្រោម។ អុចតូចៗទាំងនេះ ចាប់ផ្តើមរាលដាលពីចុងស្លឹក ឬកើតពាសពេញផ្ទៃស្លឹកទាំងមូល។ បន្ទាប់មកអុចទាំងនោះក៏រាលដាលពេញផ្ទៃស្លឹកធ្វើឲ្យស្លឹកមានពណ៌លឿងត្នោត រួចក៏ងាប់ជាបន្តបន្ទាប់។ ស្លឹកមានសភាពតូច ហើយនៅតែរក្សាភាពបៃតងដដែល។ ក្នុងករណីដែលមានការពុលដែកខ្លាំង ស្លឹកទាំងឡាយប្រែជាពណ៌ត្នោតស្វាយ។ ចំពោះពូជខ្លះ ចុងស្លឹកមានពណ៌លឿងទុំហើយស្ងួត។ ការលូតលាស់ និងការបែកគុម្ពក៏ថយចុះ រីឯប្រព័ន្ធឫសស្រូវមិនដុះចេញច្រើន ហើយមានពណ៌ត្នោតចាស់ទៅក្រមៅ។ រោគសញ្ញានៃការពុលដែក អាចកើតឡើងក្នុងអំឡុងពេលពី ១-២ សប្តាហ៍ក្រោយស្ទូង ប៉ុន្តែជួនកាលវាក៏អាចកើតឡើង ២ ខែ ក្រោយស្ទូងផងដែរ អាស្រ័យទៅតាមប្រភេទដី។








## តើការពុលដែកកើតលើដីអ្វីខ្លះ?

ការពុលដែកកើតឡើងនៅលើដីច្រើនប្រភេទ ប៉ុន្តែជាទូទៅ វាកើតនៅលើដីដំណាំស្រូវនៃតំបន់ទំនាបដែលលិចទឹកជាអចិន្ត្រៃយ៍ក្នុងរដូវកាលដាំដុះ។ លក្ខណៈសម្គាល់ទូទៅនៃកន្លែងដែលមានការពុលដែក គឺដី

ដែលមានការដក់ទឹកជាប្រចាំ និងដីដែលមានបរិមាណសារធាតុចិញ្ចឹមសំខាន់ៗទាប។ ការពុលដែកកើតឡើង នៅលើដីដែលមាន pH ពី ៤-៧។

ដីដែលងាយទទួលរងនូវការពុលដែកមានដូចជា៖ ដីនៃតំបន់ជ្រលងភ្នំដែលមានការដក់ទឹកយូរ ហើយ ដែលទទួលនូវរំហូរពីដីអាស៊ីតនៃតំបន់ខ្ពង់រាប ដីអាស៊ីតតំបន់ទំនាប ឬវាលល្បាប់ខ្ពស់ដែលសម្បូរទៅដោយ សារធាតុសរីរាង្គ។

**វិធានការបង្ការការពុលដែក**

ការប្រើវិធីសាស្រ្តក្នុងការគ្រប់គ្រង និងការបង្ការការពុលដែកជាមធ្យោបាយដ៏ប្រសើរមួយ ព្រោះថាការ ព្យាបាលការពុលដែកក្នុងអំឡុងពេលដាំដុះដំណាំមានការលំបាកណាស់។

វិធានការដើម្បីបង្ការការពុលដែកមានដូចខាងក្រោម៖

- *ពូជ*: ប្រើពូជស្រូវដែលធន់នឹងភាពពុលដែក។ ពូជស្រូវទំនើបដែលមានប្រព័ន្ធ ឫសលូតលាស់ខ្លាំង ហើយ ឫសមានកម្លាំងធ្វើអុកស៊ីតកម្មខ្លាំង មានភាពធន់ទៅនឹងការពុលដែក ប្រសិនបើបាចជីបាន គ្រប់គ្រាន់។
- *គ្រប់គ្រងការដាំដុះ* : ពន្យាពេលដាំដុះដំណាំ រហូតដល់ផុតពេលដែលកំហាប់នៃដែករលាយ ឡើងដល់ កំពូល បានន័យថា គួរដាំដំណាំក្នុងរយៈពេល ១០-២០ ថ្ងៃ ក្រោយពេលដីលិចទឹក។
- *គ្រប់គ្រងទឹក*: ចៀសវាងការពន្លិចទឹកជាប្រចាំ ចំពោះដីដែលមានបរិមាណសារធាតុសរីរាង្គច្រើន និង កំហាប់ដែកខ្ពស់ ។ អនុវត្តការបង្ហូរទឹកចេញនៅពាក់កណ្តាលរដូវកាលដាំដុះ ដើម្បីជួយការកាត់បន្ថយ បរិមាណជាតិដែកនៅក្នុងដី។ នៅពាក់កណ្តាលដំណាក់កាលបែកគុម្ព (២៥-៣០ថ្ងៃ ក្រោយស្ទូង ឬ ព្រោះ) ត្រូវបង្ហូរទឹកចេញពីស្រែឲ្យអស់ ដោយគ្រាន់តែទុកដីឲ្យនៅសើមរយៈពេល ៧-១០ថ្ងៃ ដើម្បីផ្គត់ ផ្គង់អុកស៊ីសែន នៅដំណាក់កាលបែកគុម្ព។
- *គ្រប់គ្រងជីជាតិដី*: ធ្វើឲ្យមានតុល្យភាពនៃការប្រើជីជាតិអិន ប៉េ កា ឬ អិន ប៉េ កា + កំបោរ ដើម្បីចៀស វាងភាពមិនប្រក្រតីនៃសារធាតុចិញ្ចឹមរបស់ដំណាំ។ ប្រើជីប៉ូតាសឲ្យបានគ្រប់គ្រាន់ ឬបាចកំបោរទៅលើ ដីអាស៊ីត ប្រើជីអ៊ុយរ៉េប្រសើរជាងជីអាម៉ូញ៉ូមស៊ុលផាត។
- *គ្រប់គ្រងដី*: អនុវត្តការភ្ជួរដីហាលបន្ទាប់ពីប្រមូលផលរួច ។

## ៨. ការពុលជាតិប្រៃលើដំណាំស្រូវ

គឺជាបរិមាណនៃកំហាប់អំបិល ដែលកើតមានឡើងនៅក្នុងដី ។ កាលណាកម្រិតអំបិលកើនឡើងខ្លាំង នៅក្នុងដី អាចធ្វើឲ្យមានការបាត់បង់នូវតុល្យភាពរបស់សារធាតុចិញ្ចឹមក្នុងដី ជាហេតុបណ្តាលឲ្យមានការពុល សារធាតុចិញ្ចឹមចំពោះដំណាំ និងធ្វើឲ្យដំណាំពិបាកស្រូបយកទឹកពីក្នុងដី ។ បញ្ហាចម្បងនៃការពុលជាតិប្រៃលើ ដំណាំស្រូវ គឺកើតមានឡើងនៅពេលដែលដំណាំស្រូវ ស្រូបយកជាតិប្រៃដ៏ច្រើនលើសលុបពីដី ដែលកង្វះ សារធាតុប៉ូតាស្យូម និងកាល់ស្យូម ដែលជាហេតុបណ្តាលឲ្យដំណាំមានកង្វះសារធាតុប៉ូតាស្យូម និង

កាល់ស្យូមកាន់តែខ្លាំងឡើង។

**ប្រភពនៃជីប្រៃ**

ដីប្រៃកើតមានឡើងដោយកត្តាសំខាន់ៗរួមផ្សំជាច្រើនដូចខាងក្រោមៈ

- ការប្រើប្រាស់ជីគីមីពុំសមស្របតាមកម្រិតណែនាំរបស់អ្នកបច្ចេកទេសកសិកម្ម ឬពុំសមស្របតាមសេចក្តីត្រូវការរបស់ប្រភេទដំណាំ អាចបណ្តាលឲ្យមានការលើសនូវសារធាតុចិញ្ចឹមក្នុងដី
- ការប្រើប្រាស់ជីប្រភេទម្នាងសិលា អាចបណ្តាលឲ្យមានការលើសធាតុកាល់ស្យូម និងស្ពាន់ធ័រ
- ការប្រើប្រាស់កាកសំណល់ធាតុសរីរាង្គជាច្រើនដែលពុំទាន់រលាយសមស្របល្អសម្រាប់ដំណាំ
- ការផ្តល់នូវធាតុប្រៃតាមរយៈប្រព័ន្ធស្រោចស្រពដែលមានប្រភពទឹកក្រោមដី ឬទឹកជ្រាបចេញពីភ្នំ
- ការបាចអំបិលសមុទ្រ លើស្រែដាំដុះដំណាំស្រូវ ឬដីស្រែដែលមានទឹកសមុទ្រហូរចូល
- ការផ្តល់នូវធាតុប្រៃតាមរយៈនៃការពុកផុយថ្មកំបោរ ឬសិលារ៉ែមួយចំនួនក្រោមអំពើនៃការសឹករិចរឹលដោយធាតុអាកាស សារធាតុដែលបង្ករជាជាតិប្រៃនៅក្នុងដីទាំងនេះ អាចហូរចូលទៅស្រទាប់ទឹកក្រោមដីតាមរយៈការហូរច្រោះនៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង ឬការស្រោចស្រពលើសសេចក្តីត្រូវការទឹករបស់ដំណាំ។

**បុព្វហេតុដែលបណ្តាលអោយមានការពុលជាតិប្រៃ**

ការពុលជាតិប្រៃលើដំណាំស្រូវ ច្រើនកើតមានឡើងនៅតំបន់ស្រែទំនាប អាស្រ័យលើរបបទឹកភ្លៀងដែលជាប្រភេទដីខ្សាច់ ងាយស្រួលក្នុងការហូរច្រោះ និងជាប្រភេទដីដែលខ្សត់ជីជាតិ ។ ការពុលជាតិប្រៃកើតឡើងនៅពេលដែលស្រទាប់ទឹកក្រោមដី ដែលសម្បូរនូវសារធាតុប្រៃឡើងមកស្រទាប់ខាងលើនៃដី ដែលជាស្រទាប់ឫសរបស់ដំណាំ។ នៅពេលដែលពុំមានភ្លៀងធ្លាក់គ្រប់គ្រាន់ ហើយដីមានរំហួតខ្លាំងធ្វើឲ្យដីស្រទាប់លើឆាប់ស្ងួត និងឆាប់ទទួលរងនូវការពុលជាតិប្រៃ ឬសារធាតុចិញ្ចឹមផ្សេងៗទៀតដែលបង្កឡើងដោយទឹកក្រោមដី ។ ការស្រោចស្រពដំណាំស្រូវដោយប្រព័ន្ធទឹកស្ទឹង ឬទឹកបឹងមិនស្អាតដែលមានកំហាប់អំបិលខ្ពស់ ឬប្រភពពីទឹកក្រោមដី អាចជាមូលហេតុបង្ក ឲ្យមានការពុលជាតិប្រៃចំពោះដំណាំស្រូវផងដែរ។ ម្យ៉ាងទៀតការបាចអំបិលដោយផ្ទាល់ទៅលើស្រែដាំស្រូវ ការប្រើជីសរីរាង្គដែលពុំទាន់រលាយល្អ អាចបង្កឲ្យមានការកើនឡើងខ្លាំងនូវសារធាតុអាម៉ូនីញ៉ូមនីទ្រីត សូដ្យូម និងស្ពាន់ធ័រ ដែលងាយបង្កឲ្យពុលដល់ដំណាំស្រូវ។

**រោគសញ្ញានៃការពុលជាតិប្រៃលើដំណាំស្រូវ**



រោគសញ្ញាដំបូងនៃការពុលជាតិប្រៃ គឺចុងស្លឹកមានពណ៌ស កើតមាននៅលើស្លឹកចាស់ៗ រាលដាលតាមគែមៗស្លឹកបន្ទាប់មកពាសពេញផ្ទៃស្លឹកទាំងមូល រួចរាលដាលទៅកាន់ស្លឹកខ្ចីៗផ្នែកខាងលើទៀត រួចងាប់ ជាបន្តបន្ទាប់។

ក្នុងករណីមានការពុលជាតិអំបិលខ្លាំង មានការរំខានដល់ការដុះពន្លកដើមស្រូវ រំខានដល់ការលូតលាស់របស់ឫស បន្ថយនូវការលូតលាស់កម្ពស់ដើម បន្ថយចំនួនដើមបែក និងបង្កើនចំនួនគ្រាប់ស្កក។ រោគសញ្ញានៃការពុលជាតិអំបិល អាចកើតមានឡើងនៅវគ្គសំណាប វគ្គលូតលាស់ និងវគ្គបង្កើនផល។

**វិធានការគ្រប់គ្រង និងការបង្ការការពុលជាតិប្រៃ**

ដើម្បីកាត់បន្ថយការពុលជាតិប្រៃទៅលើដំណាំស្រូវ គឺត្រូវធ្វើការទប់ស្កាត់កុំឲ្យទឹកស្រទាប់ក្រោមដីឡើងមកកាន់ស្រទាប់លើ ដែលជាស្រទាប់ឫសដំណាំ និងត្រូវប្រើបច្ចេកទេសនៃការប្រើប្រាស់ដី និងការគ្រប់គ្រងជីជាតិដីឲ្យបានត្រឹមត្រូវ ។ ការប្រើវិធីសាស្ត្រគ្រប់គ្រង និងបង្ការជាមុន ជាមធ្យោបាយដ៏ប្រសើរសម្រាប់ទប់ស្កាត់ការពុលជាតិប្រៃលើដំណាំស្រូវ ពីព្រោះការបំបាត់ការពុលក្នុងអំឡុងពេលដំណាំលូតលាស់មានការលំបាកណាស់។ វិធានការទូទៅ ដើម្បីគ្រប់គ្រង និងបង្ការការពុលជាតិប្រៃមានដូចខាងក្រោម៖

- *ការគ្រប់គ្រងការដាំដុះ៖* ជាបឋមត្រូវធ្វើការគ្រប់គ្រងដីឲ្យមានស្ថេរភាពល្អ តាមរយៈការប្រើប្រាស់កម្រិតជីសមស្របទៅតាមតម្រូវការរបស់ដំណាំ និងការគ្រប់គ្រង pH របស់ដី។ ត្រូវធ្វើការកាត់បន្ថយនូវរយៈពេលនៃការទុកដីចោលទំនេរយូរ ដោយដាំដុះដំណាំឆ្លាស់ ឬដំណាំបង្វិលដើម្បីជួយបង្កើនទម្រង់ និងជីជាតិរបស់ដី។ មិនត្រូវធ្វើការភ្ជួររាស់ជ្រៅពេក ដែលអាចបណ្ដាលឲ្យមានការហូរច្រោះសារធាតុចិញ្ចឹមទៅក្នុងស្រទាប់ក្រោម និងទឹកក្រោមដីងាយឡើងមកកាន់ស្រទាប់លើ ដែលជាស្រទាប់ឫសដំណាំ។
- *ពូជ៖* ប្រើប្រាស់ប្រភេទពូជដែលមានប្រព័ន្ធឫសរាក់ វគ្គលូតលាស់របស់វាមានរយៈពេលខ្លី និងជាប្រភេទពូជស្រូវដែលធន់ទៅនឹងការពុលជាតិប្រៃ។
- *ការគ្រប់គ្រងទឹក៖* ត្រូវធ្វើការពន្លិចទឹកស្រែពី ២ ទៅ ៤ សប្ដាហ៍ មុនការស្ទូងស្រូវក្នុងស្រែ។ មិនត្រូវប្រើប្រាស់ទឹកស្ទឹង ឬទឹកបឹង ឬទឹកក្រោមដី ដែលមានកំហាប់អំបិលខ្ពស់សម្រាប់ស្រោចស្រពដីស្រែឡើយ។ បើដីមានជាតិប្រៃ ត្រូវធ្វើការពន្លិចទឹកស្រែបន្ទាប់ពីស្ទូងរួច ដើម្បីលាងជាតិប្រៃចេញពីដី។
- *ការគ្រប់គ្រងជីជាតិដី៖* ធ្វើឲ្យមានតុល្យភាពនៃការប្រើប្រាស់ជីអាសូត ជីផូស្វ័រ និងជីប៉ូតាស្យូម ដើម្បីចៀសវាងភាពមិនប្រក្រតីនៃសារធាតុចិញ្ចឹមរបស់ដំណាំ។ ការប្រើប្រាស់ជីប៉ូតាស្យូម ឲ្យបានគ្រប់គ្រាន់ គឺមានសារៈសំខាន់ណាស់ ពីព្រោះវាធ្វើឲ្យមានការកើនឡើងនូវតម្លៃសមាមាត្ររបស់ប៉ូតាស្យូមធៀបនឹងសូដ្យូម ប៉ូតាស្យូមធៀបនឹងមាញ៉េស្យូម និងប៉ូតាស្យូមធៀបនឹងកាល់ស្យូម នៅក្នុងដំណាំ។
- *ការគ្រប់គ្រងព្រៃរបោះ៖*ចៀសវាងការកាប់បំផ្លាញព្រៃរបោះដែលស្ថិតនៅតំបន់ខ្ពស់ជុំវិញវាលទំនាបដាំស្រូវ ដើម្បីការពារកុំឲ្យស្រទាប់ទឹកក្រោមដីងាយជ្រៀតឡើងមកស្រទាប់ដាំដុះ ដែលអាចបណ្ដាលឲ្យមានការពុលដល់ដំណាំស្រូវ ៕

# ឯកសារយោង


- បង្កុំបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវ រៀបចំដោយ បណ្ឌិត អ៊ុក ម៉ាការា នាយក វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ឆ្នាំ២០១១ ។
- សៀវភៅបង្កុំបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវ នាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋាន កសិកម្ម ឆ្នាំ ២០១១ ។
- ឯកសារដំណាំស្រូវ ក្នុងWebside របស់ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
- សៀវភៅគោលការណ៍ណែនាំសម្រាប់សាលារៀនស្រែកសិករលើដំណាំស្រូវ របស់កម្មវិធី វិធានការចម្រុះគ្រប់គ្រងដំណាំ ( IPM ) ឆ្នាំ ២០០៥ ៕